ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៣៧**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក រ៉ូបឺត ពើទីត *(Mr. Robert Petit)*

លោក សេង ប៊ុនឃាង

លោក ពេជ្រ សម្បត្តិ

លោក *ហ្សាធិរី ឡាំប៉ែល (Mr.Zachery LAMPEL)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃើស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Mrs. Martine Jacquin)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

# សាក្សី

## លោក ប៊ូ ម៉េង

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៥
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ........ ទំព័រ ៤៣
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ៤៥
សួរដោយ លោក សេង ប៊ុនឃាង ផ្ដើមពី ........ ទំព័រ ៥២
សួរដោយ លោក គង់ ពិសី ផ្ដើមពី ........ ទំព័រ ៥៦
សួរដោយ កញ្ញា ទី ស្រ៊ុនណា ផ្ដើមពី ........ ទំព័រ ៦២
សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្ដើមពី ........ ទំព័រ ៦៥
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី ........ ទំព័រ ៧៣
សួរដោយ លោកស្រី ម៉ារីប៉ូល កានីហ្សារ ផ្ដើមពី ........ ទំព័រ ៨០

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ប៊ូ ម៉េង | ខ្មែរ |
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន | បារាំង |
| លោក រូប៊ឺត ពើទីត | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៥:២០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាស បន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។ ហើយតាមកាលវិភាគនៃដំណើរការសវនាការនៅថ្ងៃនេះ យើងធ្វើសវនាការស្តាប់សក្ខីកម្មរបស់អ្នករស់រានមានជីវិតម្នាក់ទៀត គឺជនទីបីហើយដែលដល់ពេលជនទីបីហើយ គឺអ្នករស់រានមានជីវិតក្នុងចំណោមអ្នករស់រានមានជីវិតទាំងប្រាំបួននាក់ នៅមន្ទីរសន្តិសុខស-២១ ។

នាងមេធាវីមានបញ្ហាអីទៅ?

**លោកស្រី ស៊ីលឃីស្ទត ហ្សីនស្តី៖**

សូមជម្រាប-- សូមគោរពលោកប្រធានអង្គតុលាការ ។ ខ្ញុំសូមជូនមតិមួយចំនួន ហើយនិងសុំការបំភ្លឺមុនយើងចាប់ផ្តើមនីតិវិធីថ្ងៃនេះ និងស្តាប់សក្ខីកម្មអ្នករស់រានមានជីវិតម្នាក់ទៀតថ្ងៃនេះ ។ យើងខ្ញុំសង្កេតឃើញថា លោក ជុំ ម៉ី ពីម្សិលមិញនោះគឺថា គាត់បានទទួលរងនូវអារម្មណ៍លើសលប់ពេលដែលគាត់នឹកឃើញពីអ្វីដែលគាត់បានឆ្លងកាត់ ហើយគាត់បានយំ ហើយគាត់មិនអាចគ្រប់គ្រងអារម្មណ៍បានទៀតទេ ។ ហើយគាត់បាននិយាយថា គាត់មានជំងឺបាក់ស្បាតភ័យខ្លាច ។ ហើយអ្នករស់រានមានជីវិតម្នាក់ទៀតក៏ជាកូនក្តីរបស់ខ្ញុំ ហើយគាត់ក៏បានទទួលរងស្ថានភាពដូចគ្នានឹងអ្នករស់រានមានជីវិត ហើយនិងជនរងគ្រោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសាក្សីផ្សេងទៀតនោះដែរ ។

ខ្ញុំសូមអនុញ្ញាតលើកសំណើមួយជូនអង្គជំនុំជម្រះថា សូមឲ្យអង្គជំនុំជម្រះជូនទូវព័ត៌មានទៅដល់សាក្សីពីចំណុចចាប់ផ្តើម ប្រសិនបើគាត់ត្រូវការពេលវេលាដើម្បីគ្រប់គ្រងនូវអារម្មណ៍របស់គាត់ ។ ដូច្នេះហើយ ដើម្បីឲ្យគាត់មានភាពប្រាកដក្នុងអារម្មណ៍ ហើយឲ្យគាត់មានអារម្មណ៍ស្រួលមុននឹងគាត់ផ្តល់សក្ខីកម្ម ។ ហើយនិងផ្តល់ឱកាសឲ្យគាត់មួយថា គាត់មិនអាចបន្តបានទេ ប្រសិនបើគាត់មិនគ្រប់គ្រងអារម្មណ៍ ហើយក៏មិនអាចនឹងសួរសំណួរឲ្យគាត់រំឭកឡើងវិញបានទេ បើមិនមានការឈប់សម្រាកបន្តិចនោះ ។ ហើយនិងខ្ញុំសុំឲ្យអនុញ្ញាតឲ្យគាត់ ទាក់ទង បើគាត់យល់ថា ចាំបាច់ឲ្យទាក់ទងជាមួយខាងផ្នែកអង្គការដែលផ្តល់នូវកិច្ចការគាំទ្រចិត្តសាស្ត្រ ដើម្បីឲ្យគាត់មានអារម្មណ៍ធម្មតាឡើងវិញ ដើម្បីឲ្យគាត់ត្រលប់មកវិញនៅពេលណាមួយនៅក្នុងពេលសវនាការ ។ ធ្វើដូច្នោះ ដើម្បីឲ្យយើងទទួលបានអត្ត-

ប្រយោជន៍ជាពិសេស សាក្សីដែលជាជនរងគ្រោះ នឹងត្រូវផ្ដល់សក្ខីកម្មជូនតុលាការនូវព័ត៌មានឲ្យបានច្បាស់ដែលគាត់អាចនឹកឃើញបាននៅពេលនេះ ដែលគាត់យល់ថា ត្រឹមត្រូវដើម្បីឲ្យគាត់មានលទ្ធភាពដើម្បីនិយាយហើយនិងប្រាប់រឿងរ៉ាវរបស់គាត់បានល្អ ។

[០៩:០៩:១៥]

ខ្ញុំសូមការបំភ្លឺពីអង្គជំនុំជម្រះផងដែរ ហើយខ្ញុំចង់លើកចំណុច ខ្ញុំចង់បានព័ត៌មានដូចខាងក្រោមនេះពីអង្គជំនុំជម្រះ ដើម្បីសុំឲ្យបញ្ជាក់ថា ចំពោះពេលវេលាដែលយើងខ្ញុំមានចំពោះភាគីទាំងអស់ ដូចជាសាមសិប ឬសែសិបមីនុតនោះ ។ ក្នុងពេលនេះយើងចាប់ផ្ដើមរាប់តែ តែពេលនៃការសួរសំណួរទៅជនអ្នកជំនាញ ឬក៏សាក្សីតែប៉ុណ្ណោះ ។ ហើយហេតុការណ៍ផ្សេងទៀត ដូចជាចំណុចដែលថាសាក្សីគាត់យំ ហើយគាត់មានគ្រប់គ្រងអារម្មណ៍មិនបាន ដោយខ្លួនគាត់នោះ ហើយគាត់មានអារម្មណ៍ដែលថាភ័យខ្លាច ឬក៏ដោយមានជម្ងឺផ្លូវចិត្តមិនធម្មតានោះ ។ អ៊ីចឹង យើងមិនត្រូវរាប់ចំណុចរយៈពេលនោះទេ ដូចជាការពិភាក្សាលើបញ្ហាអង្គច្បាប់ ឬអ្វីផ្សេងទៀតដែលមិនទាក់ទងផ្ទាល់ទៅនឹងផ្នែកនៃការសួរទេ សូមអង្គជំនុំជម្រះមិនបាច់រាប់ទេ ដូចថាបើសិនជាសាក្សីគាត់មានសម្ពាធខ្លាំង ។ អ៊ីចឹងហើយខ្ញុំសូមស្នើការបំភ្លឺពីអង្គជំនុំជម្រះ ដើម្បីឲ្យយើងដឹងច្បាស់ថា ពេលដែលរាប់ហ្នឹង គឺរាប់តែពេលដែលសួរនោះទេ ។ នេះជាសេចក្ដីសង្កេតមួយ ហើយខ្ញុំសូមថ្លែងអំណរគុណ ប្រសិនបើអង្គជំនុំជម្រះអាចផ្ដល់ការបំភ្លឺនេះដើម្បីជួយសម្រួល ដើម្បីឲ្យយើងខ្ញុំអាចនឹងធ្វើការងារបានល្អ ជាពិសេសក្នុងការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងសាក្សីនៅថ្ងៃនេះ ។

ហើយខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះផងដែរ ដើមបណ្ដឹងរដ្ឋប្បវេណីថ្ងៃនេះ គាត់មានចំណុចរឹងមាំល្អ ប៉ុន្តែ ក្នុងចំណុចខ្លះនៅក្នុងរឿងរ៉ាវរបស់គាត់ គាត់ក្លាយទៅជាមនុស្សខ្សោយវិញ គឺថាអារម្មណ៍ចិត្តសាស្ត្ររបស់គាត់ គឺថាអាចនឹងទន់ជ្រាយដោយអារម្មណ៍អតីតកាលរបស់គាត់ ។ ហើយគាត់បញ្ជាក់ថាគាត់មានសេចក្ដីរីករាយនឹងផ្ដល់សក្ខីកម្ម ។ ប៉ុន្តែ ពេលនេះគប្បីតែបង្កើតបរិយាកាសមួយដើម្បីឲ្យគាត់មានអារម្មណ៍ធូរស្រាយ បើសិនជាគាត់តានតឹង ទុកឲ្យគាត់សម្រាក ដើម្បីឲ្យគាត់មានអារម្មណ៍សម្ដែងបាន ។ សូមអរគុណ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមជម្រាបថា លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី បាននិយាយក្នុងនាមក្រុមខ្ញុំផងដែរ ។ សូមអរគុណ ។

[០៩:១២:២៨]

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវីដែលបានធ្វើការកត់សម្គាល់បញ្ហាអស់ទាំងនេះ ។ ហើយទីមួយ យើងគិតថា បញ្ហាទាំងអស់ទាំងនេះ អង្គជំនុំជម្រះបានកំណត់ជាក់លាក់ហើយ ហើយក៏មានការចាប់អារម្មណ៍ និងមានវិធានការដូចអ្វីដែលលោកស្រី លោកមេធាវី ដែលបានលើកឡើងដែរ ។ បញ្ហាទីមួយ អំពីពេលវេលា ដែលបានកំណត់ គឺអង្គជំនុំជម្រះបានកំណត់ពេលវេលាសម្រាប់ភាគីនេះ ដោយដកចេញនូវបញ្ហាផ្សេងៗទៀត ដែលអាចកើតឡើងដោយយថាហេតុ ដូចជាការជំទាស់ ឬក៏ដូចជាការអាក់ខានដោយមូលហេតុផ្សេងទៀត នោះគឺយើងមិនគិតនៅក្នុងអំឡុងពេលនៃការកំណត់ថិរវេលា សម្រាប់ភាគីនៅក្នុងការសួរទៅសាក្សី ឬក៏ដើម្បីរដ្ឋប្បវេណីនោះទេ ។ យើងគិតតែនៅក្នុងអំឡុងពេលនៃការសួរដេញដោលសុទ្ធសាធប៉ុណ្ណោះ នេះយើងគិតតាំងពីដើមមក ។ អ៊ីចឹងបញ្ជីនៅក្នុងតារាងទាំងអស់របស់ចៅក្រមមានការតាមដាន អំពីអំឡុងពេលនៃការចាប់ផ្ដើម ហើយនិងបញ្ហាដែលជួបប្រទះនូវឧបសគ្គផ្សេងៗដែលនាំឲ្យមានការអាក់ខាន ហើយត្រូវបំពេញបន្ថែម ។ អ៊ីចឹងហើយបានជាពេលវេលានៃការធ្វើសវនាការមិនជាក់លាក់ថា ពីម៉ោង ០២:០០ រហូតដល់ ០២:១០ នាទី ហើយពីម៉ោង ០២:១០ នាទី រហូតដល់ម៉ោង ០២:២០ នាទីនោះទេ វាអាចឈានរហូតដល់ទៅ០២:០៣នាទី អ៊ីចឹងន៎ ។ ហើយក្រោយមករហូតដល់១០ ឬក៏ ២០, ២៥ នាទី បានចាប់ផ្ដើមទៀត ដោយសារមានការអាក់ខានពេលវេលា ។

យើងគិតថា ការប្រឹងប្រែងរបស់អង្គជំនុំជម្រះ គឺជាការត្រឹមត្រូវ មិនមានបញ្ហាអីទេ ។ ពីម្សិលមិញគឺមានបញ្ហាតិចតួច ប៉ុន្តែមិនមែនភាគីខាងដើមបណ្ដឹងរដ្ឋប្បវេណីទេ ដែលនាំឲ្យមានបញ្ហារំជួលចិត្តនោះ គឺរំជួលចិត្តដោយខាងភាគីអយ្យការដែលសួរ ។ អ៊ីចឹងការរំជួលចិត្តរបស់គាត់ យើងបានរំងាប់ឡើងវិញ គឺរយៈពេលតិចតួច ហើយអយ្យការក៏មិនបានប្រើពេលវេលាគាត់ ពេញអស់នូវពេលវេលាដែលត្រូវផ្ដល់ឲ្យគាត់ដែរ ។

យ៉ាងណាមិញ គឺខាងមេធាវីការពារក្ដីដូចគ្នា យើងកត់សម្គាល់ឃើញថាពេលវេលាដែលយើងដាក់ឲ្យ គឺអត់អស់ទេ ។ ប៉ុន្តែ យើងមិនអាចកាត់បន្ថយពេលវេលាដែលអស់ ។ ភាគីការពារក្ដីមិនឲ្យអស់លោក ដោយសារមូលហេតុគាត់អត់សួរទេ ព្រោះជាសិទ្ធិការពារខ្លួន យើងអត់ដឹងថាតើគាត់ប្រើពេលប៉ុន្មានទេ ។ អ៊ីចឹងការគណនាពេលវេលាឲ្យទៅខាងមេធាវីការពារក្ដីត្រូវសមស្រប ។ នេះជារឿងយើងគណនា មិនមែនយើងគណនាថា អ្ហែ!គាត់និយាយតិច ត្រូវឲ្យតិច មិនអ៊ីចឹងទេ ។ សិទ្ធិការពារក្ដី

ឲ្យពេញលេញពេញសមត្ថភាព ដែលអាចការពារបាននៅក្នុងករណីចាំបាច់ ។

[០៩:១៤:៥៦]

បញ្ហាមួយទៀត លើបញ្ហាជនរងគ្រោះ អ្នករស់រានមានជីវិតតែងតែមានបញ្ហាពុះកញ្ជ្រោលនៅក្នុងអារម្មណ៍របស់គាត់ ។ បញ្ហាកន្លង មកនេះយើងបានធ្វើគ្រាន់តែ ក៏មានកម្រិតដែរ។ អ៊ីចឹងបញ្ហានេះគឺយើងនឹងធ្វើតទៅទៀត ព្រោះពីម្សិលមិញយើងបានត្រួតពិនិត្យមើល អំពីលទ្ធភាពនៅក្នុងការផ្គត់ផ្គង់ដល់គាត់ ថាតើនៅពេលដែលគាត់មានបញ្ហាហ្នឹង តើមានអ្នកគាំទ្របុគ្គលិកមកខាងពី *វីស៊ូ (WESU)* ដែលទទួលបន្ទុកកិច្ចការនេះត្រូវអមគាត់ ឬក៏ជាគ្រូពេទ្យដែលនៅនេះអមគាត់ដែរអត់ ដើម្បីឲ្យគាត់មានលទ្ធ-ភាព ។ ប៉ុន្តែ ការធ្វើអារម្មណ៍របស់គាត់ដែលទៅឃើញថា គាត់អាចបន្តការដំណើរការសវនាការបានតទៅទៀត ទើបយើងមិនផ្តល់លទ្ធភាពនៅក្នុងបញ្ហាដែលថា ត្រូវតែសម្រាកដើម្បីឲ្យគាត់ធ្វើសតិអារម្មណ៍ នោះ ព្រោះទម្ងន់នៃបញ្ហាហ្នឹងវាមិន ធ្ងន់ធ្ងររហូតដល់គាត់បាត់បង់លទ្ធភាពក្នុងការឆ្លើយ ក្នុងការស្តាប់នូវរបស់អង្គជំនុំជម្រះនោះទេ ។ អ៊ីចឹង អង្គជំនុំជម្រះបានគិតជាមុនបញ្ហានេះ ។ ហើយទន្ទឹមជាមួយនេះគឺ ភាគីដែលជាមេធាវីការពារក្តីក្នុងការការពារកូនក្តីរបស់ខ្លួនហ្នឹង គឺក៏មានសិទ្ធិក្នុងការលើកឡើងបញ្ហានេះដែរ ។ បើសិនជាជួបបញ្ហានេះ ហើយបើយល់ឃើញថា ត្រូវតែសម្រាកក្នុងអំឡុងពេលប៉ុន្មាន ដើម្បីឲ្យគាត់មានអារម្មណ៍ធូរស្រាលឡើងវិញគឺអស់លោក លោកស្រីជាមេធាវីការពារកូនក្តីរបស់ខ្លួនមានសិទ្ធិពេញទីនៅក្នុងការកត់សម្គាល់បញ្ហានេះ ។ ប៉ុន្តែ គឺមិនមែនរហូតដល់ពេលឲ្យរំខានការងារនោះទេ ឥឡូវ សុំឈប់កន្លះថ្ងៃដើម្បីឲ្យធ្វើសតិអារម្មណ៍របស់គាត់ បានន័យថាកាលវិភាគរបស់តុលាការក៏គ្រោងខុសដែរ ប្រសិនបើឈប់ដល់កន្លះថ្ងៃ ឬឈប់ដល់មួយថ្ងៃនោះអ៊ីចឹងកម្មវិធីវាត្រូវខុសបាត់ហើយ ។ អ្វីដែលយើងដាក់ផែនការកម្មវិធីសម្រាប់សវនាការឲ្យឆាប់រហ័សហ្នឹងគឺលែងមានន័យទៀតហើយ ។ អ៊ីចឹង អង្គជំនុំជម្រះបានគិតគូរពីបញ្ហានេះ ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏បានដាក់នូវអ្នកជំនាញផ្នែកខាងចិត្តសាស្ត្ររួចមកហើយនៅក្នុងបញ្ហានេះអ៊ីចឹងជាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការការពារកូនក្តីរបស់ខ្លួនក្នុងករណីចាំបាច់ ។ ហើយបញ្ហាមួយទៀត បើសិនយើងដឹងអ៊ីចឹងហើយ ក៏យើងគួរប្រឹងប្រែងបញ្ចៀសនៅក្នុងការសំណួរសួរឲ្យគាត់រហូតចំណុចណាដែលគាត់ទ្រាំមិនបាន យើងកាន់តែជ្រុំខ្លាំងដើម្បីឲ្យគាត់កាន់តែពុះកញ្ជ្រោល កាន់តែមានទុក្ខសោកសម្តែងនូវការទុក្ខសោកកាន់តែខ្លាំងនោះទៅទៀត ។ ចិត្តសាស្ត្រក្នុងការសួរគេអាចចង់ដឹងហើយ តែមិនចង់ដឹងជ្រៅពេករហូតធ្វើឲ្យគាត់យំស្រែក ឲ្យគាត់ពុះកញ្ជ្រោលរំឭកឃើញឡើងវិញ ជាអចិន្ត្រៃយ៍ក្នុង

ជីវិតរបស់គាត់ ធ្វើឲ្យគាត់ខូចសតិអារម្មណ៍អីចឹងនោះបានទេ ។ នេះជាបញ្ហាដែលយើងត្រូវគិតគូរពីបញ្ហានេះ ។

អ៊ីចឹងខ្ញុំសរុបមកវិញទីមួយ គឺពេលវេលាគឺអង្គជំនុំជម្រះបានគិតគូរពីបញ្ហានេះ យ៉ាងត្រឹមត្រូវ ។ អង្គជំនុំជម្រះគិតកន្លងមកមិនដែលឲ្យខ្វះទេ មានតែលើសគ្រាន់តែវាលើសតិច មិនលើស ច្រើនទេ ។ ប៉ុន្តែមិនអាចគណនា មិនដែលគណនាពេលវេលា សម្រាប់ជំទាស់ សម្រាប់អីចេញទេ ។ អ៊ីចឹងហើយបានជាយើងគណនាពេលវេលាវាអាចនៅសល់ គ្រោងសម្រាប់មានការជំទាស់ និងដោះស្រាយបញ្ហាជំទាស់ផ្សេងៗ ភាគីនៅក្នុងការតទល់គ្នានេះ នៅក្នុងការសួរដេញដោលនេះ ។ អ៊ីចឹងបញ្ហាទីពីរនេះ គឺរឿងដែលមានការសម្តែង ឬការទុក្ខព្រួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏យើងទទួលយកពីបញ្ហានេះពីព្រោះក្នុងនាមជាមនុស្សជាតិក៏យើងត្រូវគិតពីបញ្ហានេះដែរ ។ ប៉ុន្តែ គឺប្រសិនបើចាំបាច់គឺភាគីមេធាវីខ្លួនឯង ដែលជាអ្នកការពារកូនក្តីខ្លួនឯងហ្នឹងត្រូវចេះលើកពីបញ្ហានេះដោយខ្លួនឯង ដើម្បីសុំការអនុញ្ញាតការចាប់អារម្មណ៍ពីអង្គជំនុំជម្រះ ព្រោះការយល់ឃើញខុសគ្នា អង្គជំនុំជម្រះយល់ឃើញថា ជារឿងបន្ទាប់បន្សំទេ គ្រាន់តែអប់រំគាត់ឲ្យគាត់ពង្រឹងសតិអារម្មណ៍ឲ្យគាត់ពង្រឹងស្មារតីទៅ បន្តិចទៅឃើញគាត់និយាយបានច្បាស់ឡើងវិញ អាចល្អឡើងវិញ ហើយគាត់និយាយពាក្យសម្តីអត់ខុសសោះ យើងក៏អាចបន្តទៅដើម្បីកុំឲ្យខាតពេល ។

មន្ត្រីតុលាការនាំអ្នករស់រានមានជីវិត ប៊ូ ម៉េង ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សីចូលមកកាន់បន្ទប់សវនាការ]*

[០៩:២០:៤៦]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំឈ្មោះអីទៅអ៊ំ?

**ឆ៖** ឈ្មោះ ប៊ូ ម៉េង ។

**ប្រធានអង្គជំនុំ៖**

អ៊ំអាចអង្គុយចុះ នៅរយៈពេលវែងណាស់ អ៊ំអាចស្តាប់សក្ខីកម្មរបស់អ៊ំរហូតដល់មួយថ្ងៃឯណោះ។ អ៊ីចឹងអង្គជំនុំជម្រះអនុញ្ញាតឲ្យអ៊ំអង្គុយណ៎ា ទីមួយ ។ ទីពីរ អ៊ំមុននឹងឆ្លើយអ៊ំចាំមើលក្បាល មីក្រូដែលមានភ្លើងក្រហម ចាំពេលដែលមានភ្លើងក្រហម សឹមអ៊ំចាប់ផ្តើមនិយាយ ។ កាលណាអ៊ំ និយាយមិនទាន់មានភ្លើងក្រហម សំឡេងហ្នឹងអត់បានទៅដល់អ្នកបកប្រែទេ។ អ៊ីចឹង អ្នកបកប្រែអត់អាចបកប្រែ

បានទេ អ៊ីចឹងខាងភាគីអន្តរជាតិដែលបានចូលរួមនៅក្នុងអង្គសវនាការស្តាប់អត់បាន អត់យល់អីទាំងអស់ ។ ហើយទីបី តាមការកត់សម្គាល់ និងរបាយការណ៍របស់ក្រឡាបញ្ជីបានកត់សម្គាល់ថា អ៊ុំមានបញ្ហាត្រចៀក អ៊ីចឹងអង្គជំនុំជម្រះសូមជម្រាបអ៊ុំអ៊ីចេះថា នៅពេលណាអ៊ុំស្តាប់សំណួរៗ ហើយបើសិនស្តាប់សំណួរយល់ អ៊ុំនៅស្ងៀម ហើយអ៊ុំចាំមើលភ្លើងក្រហម សឹមអ៊ុំឆ្លើយ។ តែបើសិនជាអ៊ុំស្តាប់មិនយល់ទេ គឺអ៊ុំពេលដែលឃើញភ្លើងក្រហម អ៊ុំអាចនិយាយមកវិញថា សំណួរហ្នឹងស្តាប់មិនយល់ទេ សុំឱ្យតាំងសំណួរសាជាថ្មីម្តងទៀត ដើម្បីអង្គជំនុំជម្រះ ឬក៏ភាគីដែលមានបំណងចង់សួរអ៊ុំគាត់អាចតាំងសំណួរសួរអ៊ុំសាជាថ្មីឱ្យច្បាស់ ស្តាប់យល់ច្បាស់ហើយ សឹមអ៊ុំឆ្លើយណាអ៊ុំ ។

**សួរដោយប្រធានអង្គជំនុំ៖**

អ៊ុំមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ឆ្នាំនេះ ៦៨ ។

**ស៖** អ៊ុំមានទីលំនៅសព្វថ្ងៃនៅឯណាដែរ?

**ឆ៖** សព្វថ្ងៃ ខ្ញុំលំនៅបច្ចុប្បន្ននេះ នៅឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល។

**ស៖** អ៊ុំប្រកបមុខរបរអ្វីដែរសព្វថ្ងៃនេះអ៊ុំ?

**ឆ៖** *(ឮមិនច្បាស់)* គ្រប់បែបយ៉ាងតាំងពីជំនាន់ជាប់គុកទួលស្លែងហ្នឹងមក គឺត្រចៀកក៏មិនឮ ភ្នែកក៏ងងឹត កម្លាំងពលំក៏ថមថយ ។

**ស៖** អ៊ុំខ្ញុំរំឭកអ៊ុំម្តងទៀត អ៊ុំកុំអាលឆ្លើយលឿនពេក អ៊ុំចាំមើលភ្លើងសិន អ៊ុំឱ្យយឺតបន្តិចណ៎ា អ៊ុំចាំ មើលភ្លើងទាល់តែខ្ញុំបិទរបស់ខ្ញុំបានៗឃើញភ្លើងនុ៎ង បើខ្ញុំបើករបស់ខ្ញុំខាងណាអត់មានភ្លើងទេ ។ អ៊ីចឹង តែកាលណាប្រញាប់ពេកវានេះ បង្អង់បន្តិចអ៊ុំណ៎ា។ អ៊ុំសព្វថ្ងៃមានប្រពន្ធដែរឬទេអ៊ុំ?

**ឆ៖** បាទ ខ្ញុំសព្វថ្ងៃ ខ្ញុំមានប្រពន្ធក្រោយមួយទៀតបាទ ។

**ស៖** ប្រពន្ធក្រោយរបស់អ៊ុំឈ្មោះអ្វីទៅ?

**ឆ៖** *(ឮមិនច្បាស់)* អាយុ៤៨ ឆ្នាំ ។

**ស៖** ចុះប្រពន្ធមុនរបស់អ៊ុំឈ្មោះអ្វី?

**ឆ៖** បាទ, ប្រពន្ធមុនជាប់គុកទួលស្លែងហ្នឹង ឈ្មោះ ម៉ា យឿន ហៅ មិត្តធី ។

**ស៖** អ៊ុំបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តើនៅចំពោះមុខអង្គជំនុំជម្រះពេលនេះអ៊ុំប្តឹងទាមទារសំណងនេះដោយខ្លួនឯង ឬក៏អ៊ុំទុកនាទីនេះជូនទៅមេធាវីតំណាងរបស់អ៊ុំ ដើម្បីប្តឹង

ទាមទារជំនួសអ៊ំ?

**ឆ៖** បាទ, សូមជម្រាបលោកប្រធាន ខ្ញុំទុកនាទីនេះទៅឲ្យមេធាវីរបស់ខ្ញុំ ជាអ្នកទាមទារផ្នែកខាងផ្លូវច្បាប់ ។

[០៩:២៥:៤៣]

**ស៖** ក្នុងការដែលអ៊ំសម្រេចចិត្ត តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តើអ៊ំមានទំនាក់ទំនងយ៉ាងម៉េចទៅនឹងអង្គហេតុ ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទនៅក្នុងរឿងក្តីនេះ?

**ឆ៖** បាទ, លោកប្រធាន ខ្ញុំដូចជាមិនទាន់យល់សូមលោកបញ្ជាក់ឲ្យ វាដូចថាតាមពាក្យសាមញ្ញបន្តិចមកដើម្បីឲ្យខ្ញុំយល់ ។

**ស៖** អង្គជំនុំជម្រះចង់ដឹងថា តើអ៊ំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងប្តឹងទាមទារ តើអ៊ំមានពាក់ព័ន្ធជាមួយអង្គហេតុណា នៃការចោទប្រកាន់ទៅលើជនជាប់ចោទ ដូចជាអង្គហេតុស-២១ ឬក៏អង្គហេតុព្រៃស? គុកទួលស្លែងបច្ចុប្បន្ននេះណ៎ា អង្គហេតុស-២១ ឬក៏ព្រៃសទីមួយ ។ ទីពីរគឺអ៊ំហ្នឹងទទួលរងគ្រោះដោយខ្លួនឯងផ្ទាល់ ឬក៏ញាតិសន្តានផ្សេងទៀត ដូចជាប្រពន្ធកូនរបស់អ៊ំ ដែលត្រូវទទួលរងគ្រោះនៅក្នុងទួលស្លែង ឬក៏ព្រៃស? ឬក៏ទាំងពីរ ទាំងអ៊ំផង ទាំងគ្រួសាររបស់អ៊ំផងដែលត្រូវរងគ្រោះដែលជាជនរងគ្រោះនៅក្នុងគុកទួលស្លែង ដោយអំពើរបស់ខ្មែរក្រហមជំនាន់នោះ?

**ឆ៖** បាទ, សូមជម្រាបលោកប្រធាន! នេះគឺខ្ញុំប្តឹងអំពីបញ្ហាខ្លួនខ្ញុំផ្ទាល់ ដែលត្រូវទទួលរងគ្រោះយ៉ាងទារុណកម្ម យ៉ាងខ្លាំងក្លាជាទីបំផុត បែកខ្ទេចអស់ហើយខ្នង វ៉ៃធ្វើបាបខ្ញុំ ហើយព្រមទាំងប្រពន្ធខ្ញុំបាត់ ខ្លួនមកទល់ថ្ងៃនេះ មិនដឹងជានាងត្រូវទទួលទារុណកម្មបែបណាទេក្នុងសម័យនោះ?

**ស៖** នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើអ៊ំរស់នៅទីកន្លែងណា? ប្រកបមុខរបរអ្វីដែរ?

**ឆ៖** ១៩៧៥ ខ្ញុំបានចូលព្រៃម៉ាគី ដើម្បីរំដោះទឹកដី រំដោះសម្តេច ព្រះនរោត្តម សីហនុ ។

**ស៖** ចូរអ៊ំនិយាយរៀបរាប់ ជូនដល់អង្គសវនាការស្តាប់អំពីបទពិសោធន៍ និងអ្វីៗដែលអ៊ំបានជួបប្រទះបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីពេលក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ។ តើអ៊ំបានជួបប្រទះរឿងរ៉ាវយ៉ាងម៉េចខ្លះ?

**ឆ៖** ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំអង្គការបានឲ្យមកធ្វើការនៅសាលាបច្ចេកទេសឫស្សីកែវ ។ ខាងគូររូបភាពគំនូរផ្សេងៗ ធ្វើជាឯកសារឲ្យសិក្ខាកាមពួក ប៉ុល ពត រៀនសូត្រ នៅសាលាបច្ចេកទេសឫស្សីកែវ ។

[០៩:៣០:០៩]

**ស៖** អ៊ំអាចនិយាយរៀបរាប់ហូរហែតាំងពីឫស្សីកែវហ្នឹង ទៅរហូតដល់ពេលអ៊ំត្រូវបានរួចខ្លួនចេញពីគុកទួលស្លែង នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ បើអ៊ំអាចនិយាយរៀបរាប់បាន អ៊ំអាចនិយាយរៀបរាប់ បើអ៊ំមិនអាចនិយាយបានទេ ទុកលទ្ធភាពអង្គជំនុំជម្រះ នឹងសួរអ៊ំតាមដំណាក់កាលនីមួយៗ ។

**ឆ៖** សូមជម្រាបលោកប្រធាន! កាលពីក្នុងអំឡុងដែលខ្ញុំបម្រើការងារនៅក្នុងសាលាបច្ចេកទេសឫស្សីកែវមក ។ ខ្ញុំធ្វើការអស់រយៈពេលប្រហែលជាមួយឆ្នាំ ទេមិនដឹង ខ្ញុំភ្លេចខ្លះ ចាំខ្លះ សូមលោកប្រធានអនុគ្រោះអធ្យាស្រ័យចំពោះរូបខ្ញុំបាទផង ពីព្រោះការទារុណកម្មហ្នឹង ធ្ងន់ធ្ងរពេកធ្វើឲ្យខ្ញុំបាត់បង់អស់ស្មារតី ។

ក្នុងឆ្នាំ១៩៧៦ហ្នឹង អង្គការចាប់ប្រធានខ្ញុំឈ្មោះ ហាក់ នៅសាលាបច្ចេកទេសឫស្សីកែវ ។ រំលងមកប្រហែលជាពីរបីខែក៏ស្រាប់តែពួកនិរតីចូលទៅកាន់កាប់នៅកន្លែងនោះ ក៏ស្រាប់តែខ្ញុំត្រូវគេផ្លាស់មកសហករណ៍តាឡី ។ នៅក្នុងឃុំដង្កោ ស្រុកដង្កោ ខេត្តកណ្តាល ។ ជាសហករណ៍មួយលត់ដំក្តៅជាទីបំផុត។ ពេលនោះអង្គការបង្ខំឲ្យខ្ញុំជីកប្រឡាយកាត់តាមពីភូមិតាឡីទៅរហូតទល់គ្នានឹងផ្លូវទៅគុកព្រៃសលើកទំនប់ ជីកប្រឡាយយ៉ាងក្តៅគគុក ធ្វើទារុណកម្មខាងកម្លាំងកាយនោះវាហួសនិស្ស័យ ។

ទោះបីយ៉ាងណាក៏ដោយខំបម្រើអង្គការនុ៎ង ដូចថាវាអស់ពីចិត្តពីថ្លើមហើយ ខ្ញុំមិនដែលជួបប្រទះទេទារុណកម្មកម្លាំងកាយធ្ងន់ធ្ងរបែបហ្នឹង ។ ក្រោយមកទៀត ក៏អង្គការឲ្យខ្ញុំទៅខាងក្រុមពូៗធ្វើនង្គ័ល ធ្វើរនាស់ៗ ចាំងឈូសជាមួយប្រធានធ្វើនង្គ័ល រនាស់នោះក៏ឈ្មោះថា ប៉ាក ប៉ុន្តែមិនដឹងអី ប៉ាកទេ ឮគេហៅថា បងប៉ាកៗ នៅសហករណ៍តាឡីហ្នឹង ។

ក្រោយមកទៀត បានគេឲ្យខ្ញុំទៅដាំបន្លែម្តង ។ កំពុងតែដាំបន្លែ កំពុងតែធ្វើដី ចម្រាស សំអាតដាំបន្លែ ដាំត្រប់ ធ្វើរង ដាំស្ពៃ ស្រោចស្ពៃ ជី គេហៅថា ជីលាមកមនុស្សជីលេខមួយនោះ ។ ហើយក៏ស្រាប់តែមានថ្ងៃមួយនោះ មានពួកអាវខ្មៅបើកឡានៗហ្ស៊ីប អ៊ីចេះមិនដឹង កាត់ៗចិនអ៊ីចេះមិនដឹង ខ្ញុំមិនដឹង ខ្ញុំភ្លេច ។ ស្រាប់ដល់ខ្ញុំកំពុងតែដាំត្រប់ គេថា នែ៎! អង្គការឲ្យរៀបចំខោអាវពីរនាក់ប្តីប្រពន្ធហ្នឹងដើម្បីទៅបង្រៀនក្មេងនៅឯសាលារចនា ។ ខ្ញុំនឹកថា អ! ចំណុចដែលខ្ញុំ មុខងារជំនាញរបស់ខ្ញុំហើយខ្ញុំក៏អរ ។ អរនោះសែនថាអរ នឹកថាអញបានទៅក្នុងមុខអាជីពរបស់ខ្លួនហើយ ។ តែអកុសលអីពេលនោះ ខ្ញុំក៏ជិះឡានមកពីរនាក់ប្រពន្ធខ្ញុំ ឡានហ្ស៊ីបហ្នឹង ។ ស្រាប់តែនាំខ្ញុំដល់មកកន្លែងផ្លូវគីរីរម្យបត់ចូលវ៉ឹងមកខ្ញុំថា អ្ហាក! ដូចខុសផ្លូវទៅសាលារចនា ។ ជឿក្នុងចិត្តហើយ នឹកក្តុកក្តួលក្នុងចិត្ត ភ័យផងអីផង

ចង់ខ្យល់ចាប់ភ្លាម ។ ស្រាប់តែប្រហែលជាកន្លះម៉ោងស្រាប់មកដល់កន្លែងមួយ ខ្ញុំមិនទាន់ស្គាល់ទេ មិនដឹងកន្លែងស្អីទេ ។ ស្រាប់តែថា អើ! ឈប់ហ្នឹង ចូលក្នុងផ្ទះមួយនៅក្បែរគុកទួលស្លែងហ្នឹងមន្ទីរសន្តិសុខ ស-២១ ហៅ “គុក ទួលស្លែង” ហ្នឹង នៅមុខហ្នឹង មានផ្ទះមួយគេរៀបកៅអីពីរជួរ ហើយហៅប្រពន្ធខ្ញុំក៏ចុះពីលើឡានពីរនាក់ខ្ញុំហ្នឹងទៅអង្គុយនៅក្នុងកៅអីហ្នឹង ហើយមានម្នាក់នុ៎ងមកដល់ មើល៍! ដាក់ដៃទៅខាងក្រោយទៅ ។ ពីរនាក់ប្ដីប្រពន្ធដាក់ដៃទៅខាងក្រោយ ។ ស្រាប់តែគេយកខ្នោះមកដាក់គ្រឹប ប្រពន្ធខ្ញុំស្រែកយំហ៊ូ ។ បងខ្ញុំខុសអី? ខ្ញុំពីរនាក់ប្ដីប្រពន្ធជាកូនកំព្រា ខ្ញុំនឹកអាណោចអាធ័មចិត្តប្រពន្ធ ពេលនោះស្រាប់តែគេយកកំណាត់ខ្មៅ មកចងភ្នែកខ្ញុំទាំងពីរនាក់ប្ដីប្រពន្ធ ។ ស្រាប់តែបណ្ដើរចូលក្នុងមន្ទីរសន្តិសុខ ស-២១ ហ្នឹង ហៅ “គុកទួលស្លែង” ហ្នឹង បានខ្ញុំដឹងខ្លួនថា អ្ហូ! កន្លែងនេះកន្លែងគុកហើយ ។

[០៩:៣៧:១៧]

ចាប់ពីនឹងទៅបានគេចាប់ផ្ដើមឲ្យខ្ញុំចូលទៅក្នុងបន្ទប់មួយ ហើយគេថតរូប ។ ថតរូបប្រពន្ធខ្ញុំហើយថតរូបខ្ញុំ ។ វាចៃដន្យអីសព្វថ្ងៃហ្នឹង ខ្ញុំមានតែរូបប្រពន្ធខ្ញុំនឹងមួយទេ តែរូបខ្ញុំបាត់បង់កាល៧ មកវាហ្នឹង មិនដឹងជាអាតាត់អាតាយទៅណាអស់ទេ នៅសល់តែរូបប្រពន្ធខ្ញុំមួយ ខ្ញុំទុកបង្ហាញអង្គចៅក្រមនៅពេលនេះ ។

ថតហើយគេបណ្ដើរខ្ញុំទៅអគារ “C” អគារ “គ” ហើយប្រពន្ធខ្ញុំមិនដឹងគេបញ្ជូនទៅខាងណាទេ អគារមួយណាទេ ខ្ញុំអត់ដឹង បែកគ្នាតាំងពីហ្នឹងមករហូតទាល់ពេលបច្ចុប្បន្ននេះ ។ យកទៅដាក់ក្នុងមន្ទីរឃុំឃាំងបន្ទប់រួមហ្នឹង នៅជាន់ខាងលើអគារ “C” ហ្នឹង, អគារ “គ” ហ្នឹង ។ រយៈប្រហែលជាប្រាំខែអ្ហែ! ដូចភ្លេចហើយ មួយឆ្នាំជាងមិនដឹងប្រាំខែជាងមិនដឹង ដល់មកគេធ្វើទារុណកម្មទីមួយ គេថា អ្ហែង! គេយកទៅបកស្បែក ខ្ញុំក៏មិនដឹងថាបកស្បែករបៀបម៉េច? តែមានម្នាក់ដែលដេកជិតខ្ញុំនុ៎ង គេប្រាប់ខ្ញុំថា គេយកទៅវាយសួរចម្លើយ ។ ខ្ញុំនឹកក្ដុកក្ដួលក្នុងចិត្តភ័យណាស់ ស្អុតអស់ហើយក្នុងខ្លួន ខ្ញុំនឹកថា ខ្ញុំមានកំហុសអី? ខំធ្វើការបម្រើអង្គការអស់ពីចិត្តពីថ្លើមហើយ ។ ហើយស្រាប់តែចុងបំផុតខ្ញុំមានទោសពៃរ៍អ៊ីចឹង ខ្ញុំនឹកមិនអស់ចិត្តសោះ ។ ខ្ញុំចេះតែដេកសង្ឃឹមនៅក្នុងគុកនោះ គេដោះខោអាវអស់ហើយនៅតែខោខ្លីមួយហ្នឹង អាវក៏ដោះនៅតែខោខ្លី ដេកនៅលើកំរាលឥដ្ឋហ្នឹង ។ យូរខែឆ្នាំដែរ យូរខែដែរ បានគេចាប់ផ្ដើមទៅសួរចម្លើយ វាយសួរចម្លើយ ។ ទៅកន្លែងសួរចម្លើយនៅក្រៅបរិវេណគុកទួលស្លែងហ្នឹង មានផ្ទះមួយនៅចំក្រោយអគារ “A”, អគារ “ក” ហ្នឹង ។

មុនហ្នឹងគេដាក់ខ្នោះខ្ញុំ ហើយគេឲ្យខ្ញុំដេកផ្កាប់មុខ ហើយម្នាក់ហ្នឹងយករំពាត់ផ្ដៅ រំពាត់ឫស្សី

ពុះប្រហែលពីរផ្ទាប់ប៉ុនមេដៃមួយកង មកទម្លាប់ប្រាវនៅមុខខ្ញុំ ។ គេសួរមើលស្រឡាញ់មួយណា? ខ្ញុំថា មួយណាក៏សុទ្ធតែរំពាត់ត្រូវធ្វើទារុណកម្មវាយចំពោះខ្ញុំ ខ្ញុំស្រេចតែមិត្តបង វ៉ៃមួយណា យកស្រឡាញ់មួយណា ខ្ញុំស្រេចតែមិត្តបងទៅ ខ្ញុំមិនប៉ានអាកាត់ទេរឿងហ្នឹង ។ ម៉ម ណៃ ស្ទុះភ្លែតចាប់រំពាត់វ៉ៃខ្ញុំ វ៉ៃមួយផ្អែតមួយផ្អន់ បានម្នាក់មកវាយទៀត ។ វ៉ៃហើយ ម៉ម ណៃ ថារាប់! ម៉ម ណៃ ហៅ ចាន់ ហ្នឹង ចាន់ សម្រែងពេញខ្លួននោះ ។ កាលនោះ គាត់ពពាលពេញខ្លួន រួចដូចកូនកណ្តុលទើបតែកើតអ៊ីចឹង ក្រហាមមុខគាត់ ។ គាត់ថា រាប់! ហើយខ្ញុំរាប់ គាត់វាយដប់ ខ្ញុំរាប់បានដប់ គាត់អ្ហែ! អញទើបតែវាយបានមួយ អ្អែងរាប់ដប់ម៉េច! តែហ្នឹងហើយភាសាគេហ្នឹងគេនិយាយថា វ៉ៃដប់រាប់មួយក្តួយ លោកប្រធាន ។

[០៩:៤១:៣៧]

ខ្ញុំឈឺចុកចាប់ណាស់ ។ ដំបៅពេញខ្នងបែកខ្នងខ្ទេចហើយ លើកម្រាលឥដ្ឋដែលខ្ញុំដេកផ្កាប់មុខហ្នឹង គឺសុទ្ធតែឈាមពេញឥដ្ឋអស់ហើយ ខ្សែតី រំពាត់ផ្តៅក៏មាន ។ ពេញទ្រនុំង ខ្ញុំស្លុត *(សាក្សីរន្ធត់ចិត្ត)* ។ ពេលវាយម្តងៗគេសួរខ្ញុំ សួរអ្អែងចូល *សេអ៊ីអា* ថ្ងៃណា? ខែណា? ឆ្នាំណា? អ្នកណានាំចូល? ឈ្មោះអី? អ្នកនាំចូល ។ ខ្ញុំមិនដឹង ខ្ញុំឆ្លើយថា មិនដឹង ។ គេមកវ៉ៃលើកទីមួយ ខ្ញុំមិនដឹង បើលើកទីពីរក៏ខ្ញុំមិនដឹង លើកទីបីក៏ខ្ញុំឆ្លើយថា មិនដឹង ។ គេចេះតែវ៉ៃៗទាល់តែបែកអស់ហើយខ្នង ដំបៅខ្ទេចហើយ វ៉ៃលើដំបៅហ្នឹងទៀត ។

ខ្ញុំរកនឹកមិនឃើញនូវកំហុសរបស់ខ្លួនឃើញ ហើយខ្ញុំក៏មិនដែលបានចូលស្អីឯណាសោះ មិនដឹង *សេអ៊ីអា* យ៉ាងម៉េច? *កាហ្សេបេ* ហ្នឹងយ៉ាងម៉េច? ខ្ញុំអត់ដឹង ។ ហើយឆ្លើយថា មិនដឹង គេចេះតែវាយវាយខ្ទេចខ្ទីអស់ហើយខ្នងខ្ញុំ ។ ខ្ញុំមានសម្លាកខ្នងពេញខ្នងជាភស្តុតាង ។ ខ្ញុំនឹកក្នុងចិត្តថា អ! គុណទឹកដោះអ្នកម្តាយថ្លៃ សូមឲ្យខ្ញុំរួចរស់មានជីវិត ហើយខ្ញុំក៏អរគុណ ។ អ! បានរួចរស់មានជីវិតមកទាល់ពេលនេះបានមកជួបមុខអង្គសវនាការមែន ។ ខ្ញុំមានចិត្តរីករាយណាស់ បានអង្គសវនាការជំនុំជម្រះវិសាមញ្ញហ្នឹង ក្នុងតុលាការកម្ពុជានេះជួយរកយុត្តិធម៌ឲ្យខ្ញុំ ខ្ញុំសប្បាយចិត្តជាអនេក ។ ខ្ញុំនឹកថា បានយុត្តិធម៌ហើយ ។ បើមិនបានមួយរយភាគរយក៏ត្រឹមតែថាហាសិប ឬហុកសិបភាគរយដែរ ថាអ៊ីចឹងចុះ ។ ដូចគោលបំណងខ្ញុំបានប្តេជ្ញាពីក្នុងគុកថា ខ្ញុំគ្មានកំហុសអីទេ ។ ខ្ញុំនឹកមើលសព្វគ្រប់អស់ហើយថាគ្មានកំហុសអីទេ សូមឲ្យខ្ញុំរួចរស់មានជីវិត បានមានជីវិតមែន ។

[០៩:៤៥:០០]

**សៈ** អ៊ំម៉េងអាចពង្រឹងសតិអារម្មណ៍ ធ្វើអារម្មណ៍ឲ្យបានល្អ ហើយឲ្យបាននឹងន ដើម្បីមានឱកាសពីព្រោះអ៊ំអំមិញបានមានប្រសាសន៍ហើយថា អ៊ំទន្ទឹងរង់ចាំឱកាសដើម្បីអ៊ំបានសម្ដែងនូវអ្វីដែលអ៊ំបានជួបប្រទះនូវអ្វីដែលបានទទួលរងពីអំពើអយុត្តិធម៌ អំពើធ្វើទារុណកម្មដ៏ឈឺចាប់ ដ៏ធ្ងន់ធ្ងរដោយពួកខ្មែរក្រហមដែលប្រព្រឹត្តមកលើអ៊ំ មកលើភរិយារបស់អ៊ំ ។ ហើយបំណងនេះ វាលុះត្រាតែអ៊ំហ្នឹងធ្វើសតិអារម្មណ៍ឲ្យបាននឹងន ឲ្យបានល្អ ដើម្បីបង្កលក្ខណៈអ៊ំសម្ដែងនូវការបង្ហាញនៃអ្វីដែលពួកគេបានធ្វើមកលើអ៊ំនោះ ។ ដើម្បីឲ្យអង្គជំនុំជម្រះ ក៏ដោយជាសាធារណជនចូលរួមនៅទីនេះ ឬក៏ប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស និងមនុស្សជាតិនៅលើពិភពលោកគេបានស្ដាប់ បានយល់អំពីអំពើរបស់ពពួកខ្មែរក្រហមប្រព្រឹត្តមកលើអ៊ំ ហើយក៏បានសម្ដែងអាណិតអាសូរចំពោះដែរ ដែលទទួលរងនូវអំពើដ៏ឃោរ-ឃៅដ៏អមនុស្សធម៌ពីក្រុមទាំងនោះ ។ ប្រសិនបើអ៊ំបណ្ដែតបណ្ដោយឲ្យអារម្មណ៍មនោសញ្ចេតនារបស់អ៊ំហ្នឹងអណ្ដែតអណ្ដូងជ្រៅពេករន្ធត់ចិត្តពេកនោះ អ៊ំបាត់បង់នូវឱកាសនៅក្នុងការនិយាយនៅក្នុងការរៀបរាប់នូវទុក្ខសោកវេទនាដែលអ៊ំបានជួបប្រទះកន្លងមកជូនដល់អង្គជំនុំជម្រះ ក៏ដូចជាសាធារណជនហើយ ។ អ៊ំៗ យល់ទេ អ៊ំម៉េង?

[០៩:៤៧:១៥]

**ផៈ** បាទ, យល់លោកប្រធាន បាទៗ ។

**សៈ** អ៊ំៗធ្វើសតិអារម្មណ៍ឲ្យបានល្អ ហើយអារម្មណ៍ដើម្បីអ៊ំ វាជាឱកាស ពីព្រោះជាឱកាសនេះមួយថ្ងៃនេះគឺទុកឱកាសជូន អ៊ំដើម្បីអ៊ំបានបកស្រាយ បាននិយាយរៀបរាប់អំពីអ្វីដែលជាទុកសោករបស់អ៊ំ ជូនដល់អង្គជំនុំជម្រះឲ្យបានយល់ ។ ប្រសិនបើអ៊ំបាត់បង់នូវសតិអារម្មណ៍ ធ្វើឲ្យរំជួលចិត្តខ្លាំងមិនមានឱកាសនិយាយទេ ហើយប្រហែលជាអង្គសវនាការមិនមានពេលវេលាថ្ងៃផ្សេងទៀតទេសម្រាប់អ៊ំនោះ ពីព្រោះកម្មវិធីថ្ងៃផ្សេងៗទៀតហ្នឹង មានអ្នកផ្សេងទៀតដែលត្រូវមកនិយាយ មានករណីមួយចំនួនដូចអ៊ំដែរ ។ គេឆ្លងកាត់ទុក្ខវេទនាដូចអ៊ំអ៊ីចឹង នៅក្នុងហ្នឹងរស់រានមានជីវិតពីស-២១ ឬខ្លះគេរស់រានមានជីវិតពីស-២៤ (ព្រៃស) ។ ហើយនិងអ្នកខ្លះទៀត គឺមិនទទួលរងផ្ទាល់ ប៉ុន្តែគ្រួសាររបស់គាត់ជាប្ដីជាឪពុកជាម្ដាយរបស់គាត់ដែលត្រូវទទួលមរណភាពទាំងអំពើអយុត្តិធម៌ និងអមនុស្សធម៌នៅទីនោះ ។

[០៩:៤៨:២១]

អ៊ីចឹងគឺក៏មានលក្ខណៈខុសៗគ្នាទៅមុខទៀត អ៊ីចឹងសូម អ៊ំបន្តទៀត ។ អ៊ំបន្តនៅអ្វីដែលអ៊ំបានទទួលរងនៃអំពើអយុត្តិធម៌ អំពើអមនុស្សធម៌ទាំងឡាយដែលកើតមានចំពោះអ៊ំនៅក្នុងអំឡុងពេលដែល

អ៊ំជាប់ឃុំឃាំងរហូតដល់ថ្ងៃអ៊ំបានចេញរួចពីនោះ ដោយសារកងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា ដែលមានការគាំទ្រពីកងទ័ពវៀតណាមហ្នឹង បានរំដោះនៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ នោះ ។ អ៊ំអាចបន្តបានទេ?

**ឆៈ** បាទ, ខ្ញុំអាចបន្តបានលោកប្រធាន។ ខ្ញុំសូមថយក្រោយបន្តិច កាលនិយាយថយក្រោយនេះ ខ្ញុំភ្លេចនិយាយអំពីការហូបចុកនៅក្នុងគុករួមហ្នឹង ។ អគាររួមនុ៎ង បន្ទប់រួមគឺមានមនុស្សប្រហែលជាសាមសិប-សែសិបនាក់នៅជ្រុងជញ្ជាំងម្ខាងនុ៎ង ខ្ញុំឃើញជនបរទេសខ្ពស់ ភ្នែកស សក់-- នៅកៀនជ្រុងជញ្ជាំងគុកនុ៎ងដែរ ក្នុងគុករួមនុ៎ង ជាមួយខ្ញុំ ជាប់ជាមួយខ្ញុំនុ៎ង ហុតទឹកបបររាវៗដូចខ្ញុំអ៊ីចឹង ។ អត់មានកាកទេ កាកមួយៗទឹកបបររាវៗ មួយវែកៗដួសឲ្យហូប ហើយខ្ញុំស្កមៗនៅតែកដៃប៉ុនដងវែក អស់ហើយកម្លាំងស្គមមែនទែន សឹងថា សិនបើលើកព្រនង់តដៃគេ ក៏តមិនកើតដែលពេលនុ៎ង ។

កាលពីខ្ញុំឡើងទៅលើគុក គេនាំខ្ញុំទៅ ហ៊ឹម ហ៊ុយ គេជិះកខ្ញុំតាំងពីជាន់ក្រោយរហូតទៅលើ ហើយខ្ញុំចំពប់នឹងកាំជណ្តើរស៊ីម៉ង់ត៍អគារនុ៎ងឡើងរលាត់ក្បាលជង្គង់ដំបៅ អ៎! ស្នងជើង អូ! ខ្ញុំនឹងទៅវាឈឺចាប់ណាស់ ។ ក្នុងមួយថ្ងៃហ្នឹងវៃស្ទួរចម្លើយ ហៅទៅវៃស្ទួរចម្លើយពីរដង ព្រឹកម៉ោងប្រាំពីរទាល់ម៉ោងដប់ពីរ ឬក៏ម៉ោងមួយ ហ្នឹងព្រឹក ។ ល្ងាចចាប់ពីម៉ោងពីររហូតដល់ម៉ោងប្រាំមួយ ប្រាំពីរយប់ ឬម៉ោងប្រហែលជាម៉ោងប៉ុណ្ណឹង បានចាប់ផ្តើមបានមកដល់កន្លែងវិញ ។

អ្នកដែលវៃ គឺស្ទួរចម្លើយខ្ញុំនុះ ខ្ញុំមើលឃើញខ្ញុំចំណាំមុខ ហើយឮស្ទួរគេហៅគ្នាគេហ្នឹង ខ្ញុំក៏ចាំឈ្មោះតាមគេហៅគ្នាគេនុ៎ង មួយឈ្មោះ ម៉ម ណៃ, ហ៊ី, ហ៊ឹម ហ៊ុយ, ប៉េង, ទិត ទាំងអស់មានប្រាំនាក់ ។ អ៊ីចឹង ខ្ញុំសូមជម្រាប អានេះខ្ញុំនិយាយមកថយក្រោយបន្តិចវិញ សូមលោកប្រធានអធ្យាស្រ័យ ។

[០៩:៥២:០៨]

**សៈ** អ៊ំធ្វើអារម្មណ៍ឲ្យបាននឹងន សម្រួលឲ្យបានល្អ ដូចខ្ញុំបានជម្រាបអ៊ំអ៊ីចឹងថា អ៊ំបានទន្ទឹងឱកាសនេះយូរហើយ ។ ហើយឥឡូវនេះឃើញថា អ៊ំមានការរំជួលចិត្តហើយមិនអាចរៀបរាប់បានអស់ទេ នូវអ្វីដែលជាទុក្ខសោករបស់អ៊ំដែលអ៊ំបានជួបប្រទះនូវដែលរំលោភបំពានមកលើអ៊ំ ដោយអយុត្តិធម៌ ដោយអមនុស្សធម៌នោះ គិតទាំងប្រពន្ធរបស់អ៊ំផង ។ ឥឡូវនេះអង្គជំនុំជម្រះតាំងសំណួរអ៊ំវិញ ដើម្បីអ៊ំស្តាប់ហើយនឹងអ៊ំឆ្លើយនឹងសំណួរ ណាអ៊ំ ។

នៅពេលដែលមានរថយន្តមួយគ្រឿងទៅនាំយកអ៊ំពីសហករណ៍តាឡី ស្រុកដង្កោមកកាន់សាលារថនានោះ តើគេបានចង ឬក៏ដាក់ខ្នោះអ៊ំនិងប្រពន្ធរបស់អ៊ំដែរឬទេ?

**ផ៖** សូមជម្រាបលោកប្រធានចៅក្រមជាតិនិងអន្តរជាតិ! គឺថាពេលនុ៎ង គឺឃើញឡានមួយគ្រឿង ទៅដាក់ខ្ញុំអ៊ីចឹងមែន ប៉ុន្តែអត់ឃើញមានខ្នោះទេ ។ គេឲ្យរៀបខោអាវដាក់មួយសាក់ការដូវធំ ហើយខោអាវខ្ញុំកាលនុ៎ងវា ចេះតែប្រមូលពីនេះពីនោះនៅជយភណ្ឌក្នុងក្រុងភ្នំពេញហ្នឹង ដល់អ៊ីចឹងទៅយកទៅចាកចោលនៅកន្លែងគុកទួលស្លែងហ្នឹងហើយ ពេលនុ៎ង ។

**ស៖** ពេលគេនាំអ៊ំហ្នឹងមកដល់ចូលគុកទួលស្លែងភ្លាម ឬក៏ចូលទៅកន្លែងណាមួយសិន ដើម្បី--ដែលមានអ៊ំរៀបរាប់អំមិញថា មានកន្លែងមានកៅអីអីហ្នឹង! កន្លែងហ្នឹងជាកន្លែងក្នុងគុកទួលស្លែង ឬក៏ខាងក្រៅទេ?

[០៩:៥៤:៣៣]

**ផ៖** បាទ,ហ្នឹង ខាងក្រៅគុកទួលស្លែង នៅមុខគុកទទួលស្លែងហ្នឹង មានផ្ទះមួយហើយគេរៀបកៅអីពីរជួរ តុកណ្ដាលវែង ចូលទៅកន្លែងហ្នឹង ។ គេឲ្យចូលទៅកន្លែងហ្នឹងហើយ គេឲ្យខ្ញុំពីរនាក់ប្ដីប្រពន្ធហ្នឹងដាក់ដៃមកក្រោយ ។ ដាក់ដៃមកក្រោយ គេក៏យកខ្នោះមកដាក់ទាំងពីរនាក់ប្ដីប្រពន្ធហ្នឹង ។

**ស៖** នៅពេលនោះ អ៊ំ ពេលដែលគេបង្គាប់ឲ្យ អ៊ំដាក់ដៃទៅក្រោយ ពីរនាក់ប្រពន្ធដាក់ដៃទៅក្រោយ ហើយគេដាក់ខ្នោះនុ៎ង តើពួកគេមានបានប្រាប់ថា គេចាប់អ៊ំ ខ្លួនអ៊ំនិងប្រពន្ធរបស់អ៊ំហ្នឹងដោយពីមូលហេតុអីទេ? នាំឲ្យគេចាប់ អ៊ំ ដែរទេ? និងប្រពន្ធ អ៊ំ ដែរទេ? គេមានប្រាប់មូលហេតុទេ?

[០៩:៥៥:៣១]

**ផ៖** បាទ, លោកប្រធានពេលនោះ គេមិនបានប្រាប់ពីមូលហេតុខ្ញុំមានកំហុសអីទេ ។ ខ្ញុំទេ ខ្ញុំសួរគេថាខ្ញុំមានកំហុសអី? ប្រពន្ធខ្ញុំក៏ឆ្លើយដូខ្ញុំអ៊ីចឹងដែរ ។ ខ្ញុំជាកូនកំព្រា ខ្ញុំជាអ្នកកំព្រើកព្រាក់សត់ណាស់ ។ ខ្ញុំមានកំហុសអី? ហើយខ្ញុំក៏ឆ្លើយដូចគ្នា ហើយគេក៏ថា “អ្វេ! អ្អែងដឹងទេ? អង្គការភ្នែកម្នាស់ មានកំហុសមិនមានកំហុស បើមនុស្សមានកំហុសបានជាគេចាប់មក មនុស្សគ្មានកំហុសគេមិនចាប់មកទេ” ហើយខ្ញុំនឹកឆ្ងល់ចេះតែនឹកក្នុងចិត្តខ្លួនឯង ពីរនាក់ប្ដីប្រពន្ធទៅស្ទូងដករាល់ថ្ងៃប្រពន្ធខ្ញុំ ។ ហើយខ្ញុំនៅកម្លាំង គេហៅថា កម្លាំងតាៗ បងៗ ពូៗ នៅធ្វើនង្គ័ល ធ្វើរនាស់មួយក្រុមអ៊ីចឹងទៅក្នុងសហករណ៍នុ៎ង ហើយប្រពន្ធខ្ញុំទៅស្ទូងទៅដករាល់ថ្ងៃ រកនឹកកំហុសមកទាល់នឹងថ្ងៃនេះមិនឃើញលោកផងទាន ។

**ស៖** អ្នកដែលបង្គាប់ឲ្យអ៊ំហើយនិងប្រពន្ធអ៊ំ ដាក់ដៃទៅក្រោយហើយយកខ្នោះមកដាក់ដៃអ៊ំនិងប្រពន្ធរបស់អ៊ំហ្នឹង អ្នកដែលទៅនាំអ៊ំពីតាឡីមក ឬក៏មនុស្សផ្សេង?

[០៩:៥៧:១៩]

**ឆ៖** សូមជម្រាបលោកប្រធាន! គឺថានេះគឺជាអ្នកផ្សេងមិនមែនអ្នកទៅដឹកខ្ញុំមកទេ ។ អ្នកនៅប្រចាំការនៅផ្ទះ នៅមុខគុកនុ៎ង នៅក្នុងនុ៎ង គេត្រៀមចាំស្រេច ។ ខ្ញុំចូលទៅដល់នឹងគេឲ្យអញ្ជើញអង្គុយអីត្រឹមត្រូវអ៊ីចឹង ដល់ក្រោយមកបានគេប្រាប់ដូចខ្ញុំនិយាយអំមិញអ៊ីចឹង ។ ខាងដើមអំមិញអ៊ីចឹង ដាក់ដៃមកក្រោយមក ប្រពន្ធខ្ញុំយំតែម្ដង មិនដឹងកំហុសរបស់ខ្លួនថាខុសរឿងអី? បើថានៅផ្ទះខ្ជិលធ្វើការ នៅតែដេកស្ងៀមៗទៅហ្នឹងដឹងថាកំហុសខ្លួនខុស អត់សោះ! រកនឹកកំហុសខ្លួនឯងមកទាល់ថ្ងៃនេះរកមិនឃើញសោះ ។ នឹកមិនឃើញ គេឲ្យធ្វើអី អង្គការឲ្យធ្វើអីធ្វើនុ៎ង ចាត់តាំងធ្វើអីធ្វើនុ៎ង ។

**ស៖** អ៊ំចាំទេ? ថ្ងៃដែលគេចាប់ខ្លួនអ៊ំ មកដាក់នៅគុកទួលស្លែងហ្នឹងថ្ងៃខែឆ្នាំណាដែរអ៊ំ? ច្បាស់ទេ? ឬក៏ចាំតែឆ្នាំ?

**ឆ៖** បាទ, សូមជម្រាបលោកប្រធាន! ឆ្នាំខ្ញុំចាំ ក្នុងឆ្នាំ១៩៧៧ ហ្នឹងចូលមកក្នុងសន្តិសុខស-២១ ហ្នឹង គុកទួលស្លែងហ្នឹង ។ ប៉ុន្តែ ខែខ្ញុំស្រពេចស្រពិល ពីព្រោះថាពេលនោះវាគ្មានថ្ងៃខែកាឡង់ឌីយេណាមើលទេ ក្នុងនុ៎ងគ្មាន ។ អ៊ីចឹងតាមការស្មានប្រហែលជាខែប្រាំ ឬខែប្រាំមួយ ក្នុងឆ្នាំ១៩៧៧ ហ្នឹង ពីព្រោះអ៊ីចេះ! បានជាខ្ញុំចាំអ៊ីចឹង ខ្ញុំគេវ៉ៃធ្វើដំទារុណកម្មឆ្អែតឆ្អន់ណាស់ បានថ្ងៃមួយហ្នឹងមានក្មេងម្នាក់អាយុប្រហែលជា ១៦-១៧ឆ្នាំ ទៅស្រែកប្រកាស ។ ប្រកាសថា មើលបន្ទប់នេះមានអ្នកណាចេះគូររូបដូចទេ? ខ្ញុំក៏លើកដៃឡើង ខ្ញុំចេះគូរ ។

គេប្រើម្នាក់ថា ឥឡូវចាក់សោ ដោះគាត់មក ដោះវាមក ដោះមកដាក់ច្រវាក់ជើងម្ខាង បណ្ដើរពីលើអគារ “គ” ហ្នឹង អគារ “C” ហ្នឹង ចុះមកក្រោយទៅជួបនឹងលោក ឌុច ។ បានជាខ្ញុំស្គាល់ពីព្រោះកាលខ្ញុំនៅគូរគំនូរ ប៉ុល ពត ហ្នឹង គាត់នៅអង្គុយក្បែរខ្ញុំហ្នឹង គងអន្ទាក់ខ្លា មើលខ្ញុំគូររូប ប៉ុល ពត ហ្នឹង ហើយមិនមែនតែគូររូប ប៉ុល ពត ទេ គូរច្រើន រូប ម៉ៅ សេទុង ក៏មាន, ហ្វាគូហ្វុង ក៏មាន ។

[១០:០០:៣៥]

**ស៖** ឥឡូវអ៊ីចេះអ៊ំ ដល់អំមិញអង្គជំនុំជម្រះបានឲ្យអ៊ំរៀបរាប់ ដល់អ៊ំរៀបរាប់មើលទៅ ដូចជាអ៊ំរកពាក្យអ្វីនិយាយរៀបរាប់អត់បានទេ ។ ឥឡូវហ្នឹងអ៊ំចាំស្ដាប់ចម្លើយ សំណួររបស់អង្គជំនុំជម្រះវិញ ហើយអង្គជំនុំជម្រះនឹងសួរអ៊ំជាក់លាក់ ។ បានន័យថា សួរតាំងពីកាលប្បវត្តិនៃការចាប់ខ្លួន ការចូលដល់ការទារុណកម្ម ការដែលអ៊ំត្រូវដកឲ្យគេធ្វើអីៗរហូតដល់ហ្នឹងអ៊ំចេញថ្ងៃ៧ មករា ហ្នឹងអ៊ំនឹងសួរអ៊ីចឹងចាំដល់ដំណាក់កាលមួយៗសុំអ៊ំធ្វើការឆ្លើយបំភ្លឺ ដើម្បីឲ្យអ៊ំហ្នឹងបានល្អិតល្អន់ ព្រោះអ៊ំបាននិទានរៀបរាប់អំមិញដូចជាមានការភ្លេចភ្លាំងច្រើន ។ ដោយសារអ៊ំមានអារម្មណ៍មិនល្អ អ៊ីចឹងអង្គជំនុំជម្រះដូរវិធីវិញ

សួរអ៊ំវិញណ៎ា ។ អ៊ីចឹងអ៊ំអាចចាំឆ្លើយនឹងសំណួរ ពាក់ព័ន្ធនឹងសំណួរដែលអង្គជំនុំជម្រះនឹងសួរអ៊ំណ៎ា ។ ពេលដែលអ៊ំ គេចាប់មកដល់ទួលស្លែងហ្នឹងនៅវេលាម៉ោងប្រហែលជាប៉ុន្មានទៅ ពេលថ្ងៃឬក៏ពេលយប់?

**ផ៖** បាទ, ជម្រាបលោកប្រធាន! ពេលនុ៎ងគឺថាប្រហែលជាម៉ោង--គេទៅហៅខ្ញុំពីសហករណ៍តាឡីហ្នឹងនៅប្រហែលជាម៉ោង ប្រហែលជាម៉ោងប្រាំបួន ម៉ោងដប់អ៊ីចឹងមិនដឹង ខ្ញុំភ្លេចហើយ ហើយមកដល់គុកទួលស្លែងហ្នឹង ក៏មិនបានជាមើលម៉ោងមើលពេលដែរ ពេលនុ៎ង ប៉ុន្តែថានៅពេលថ្ងៃ មិនមែនយប់ទេ ។

**ស៖** ពេលដែលគេដាក់ខ្នោះអ៊ំ និងប្រពន្ធអ៊ំរួច មុននឹងបណ្តើរពីកន្លែងដែលប្រគល់ទទួលហ្នឹងចូលទៅក្នុងគុកទួលស្លែងហ្នឹង គេមានយកក្រណាត់រុំមុខដែរទេ?

**ផ៖** ហើយគេចងមុខ គេចងមុខហើយ បានគេបណ្តើរចូលក្នុងគុកទួលស្លែងហ្នឹង ។

**ស៖** អំមិញអ៊ំបាននិយាយរៀបរាប់ថា ពេលដែលចូលទៅដល់ហ្នឹង គឺមានការថតរូប តើមុននឹងថតរូបអ៊ំ និងប្រពន្ធអ៊ំហ្នឹង គេមានសួរអំពីជីវប្រវត្តិរបស់អ៊ំ និងប្រពន្ធអ៊ំទេ? មុននឹងគេថតរូប ឬក៏ក្រោយពេលគេថតរូបនោះ?

**ផ៖** ដូចជាភ្លេចខ្លះចាំខ្លះលោកប្រធាន ។ ខ្ញុំសូមអនុគ្រោះ ប្រហែលជាឯកសារទួលស្លែងមានពីព្រោះប្រធានមន្ទីរនៅនុ៎ងឈ្មោះឌី ។ ប្រហែលជាមានកត់ ហើយខ្ញុំភ័យស្លន់ស្លោពេក ភ័យថាមិនដឹងរឿងអីគេចាប់មក ដល់អ៊ីចឹងវាភ័យមិនបានគិតគូរ មិនដឹងជាបានសរសេរ ឬមួយយ៉ាងម៉ាទេ ឬក៏ប្រវត្តិរូបគេផ្ញើមកមុនក៏មិនដឹង ។ ខ្ញុំភ្លេច ។

[១០:០៣:៤៣]

**ស៖** ពេលគេថតរូបអ៊ំ ហ្នឹង អំមិញអ៊ំ គេបណ្តើរចូលមក ជាមួយប្រពន្ធហ្នឹងគេចងមុខ ។ ពេលដែលគេថតរូបហ្នឹងតើគេនៅចងមុខដដែលឬក៏គេស្រាយក្រណាត់ដែលរុំមុខចេញរួចបានគេ ទើបគេថត?

**ផ៖** បាទ,សូមជម្រាបថា គេបណ្តើរចូលកន្លែងថតហ្នឹង គេស្រាយៗក្រណាត់ចងមុខចេញអស់ហើយ ហើយគេឲ្យខ្ញុំអង្គុយថត ។ ថតខ្ញុំហើយ បានគេថតប្រពន្ធខ្ញុំ ។

**ស៖** ចុះចំណងៗ ឬក៏ខ្នោះដែលគេដាក់ដៃហ្នឹងគេដោះទេ នៅក្នុងអំឡុងពេលដែលគេថតរូបនោះ?

**ផ៖** ប្រហែលជាគេដោះក៏មិនដឹង ឬមិនដោះក៏មិនដឹងទេ គេខ្លាចខ្ញុំរត់ខ្ញុំអីណ៎ា អាហ្នឹងខ្ញុំមិនដឹងទេ ភ្លេចហើយអាត្រង់ហ្នឹង ត្រូវភ្លេច មិនដឹងគេដោះមិនដឹងគេដាក់អ៊ីចឹងក៏មិនដឹង ប៉ុន្តែចាំថាគេថត

ហើយ គេចងមុខវិញៗបណ្ដើរឡើងទៅលើអគារ សេ "C", អគារ "គ" ។

**ស៖** ចុះគេ អ៊ំបាននិយាយថា គេបានដោះសម្លៀកបំពាក់វែងរបស់អ៊ំចេញ បានន័យថា ខោវែង និងអាវចេញ ទុកតែខោខ្លីទេ ។ តើគេដោះសម្លៀកបំពាក់អ៊ំចេញហ្នឹងក្រោយពេលថតរូបមុនពេលជូនអ៊ំឡើងទៅអគារ "គ" ឬក៏ទៅដល់អគារ "គ" ហើយបានដោះសម្លៀកបំពាក់ចេញ?

**ឆ៖** បាទ,កន្លែងហ្នឹងដូចជាដោះសម្លៀកបំពាក់នៅក្រោមហើយក៏មិនដឹង ពីព្រោះថាខ្ញុំភ្លេចភ្លាំងដែរកាលហ្នឹង មិនដឹងឡើងទៅដល់អគារខាងលើបានគេដោះមិនដឹង ខ្ញុំភ្លេចត្រង់ហ្នឹង ។ ប៉ុន្តែ ដឹងៗថា គេថតគេចងមុខវិញ ។ ចងមុខហើយបានគេបណ្ដើរឡើងទៅលើ ហើយប្រពន្ធខ្ញុំមិនដឹងគេបណ្ដើរទៅអគារណាទេ ខ្ញុំអត់ដឹង ។

**ស៖** អ៊ំពេលទៅដល់អគារហ្នឹងជាអគារឃុំឃាំងរួម បានន័យថា មានមនុស្សច្រើននាក់ ឬក៏ជាអគារឃុំឃាំងដាច់ដោយឡែក បានន័យថាអគារហ្នឹងមានតែម្នាក់អ៊ំទេ ដែលកន្លែងឃុំឃាំងនោះ?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកប្រធាន! គឺថាពេលនោះគឺបន្ទប់រួមធំណាស់ បន្ទប់ធំហ្នឹងវាមានគ្នាម្ភៃ-សាម-សែសិបនាក់ ឃើញមុខមនុស្សក្នុងគុកនុ៎ងហាក់ដូចជានរកឋានកណ្ដាល ។ ភ្នែករូងៗ ហើយខ្លះសក់ៗប៉ប្រះស្មាអ៊ីចឹង ។ មនុស្សប្រុសសោះ ប៉ុន្តែសក់វែងៗណាស់ ស្រពឹងស្រពោងដូច-- ខ្ញុំចូលទៅខ្ញុំខ្យល់ចាប់ ខ្ញុំភ័យស្លុត វង្វេងវង្វាន់ ភ្លេចភ្លាំងអស់ហើយ ។

[១០:០៧:១០]

**ស៖** អ៊ំៗ ពេលដែលទៅដល់ហ្នឹង គេដាក់ខ្នោះអ៊ំហ្នឹងគឺជាស្ទួជាមួយអ្នកដទៃ ឬក៏ដាក់ខ្នោះដោយឡែកតែម្នាក់ឯងទេ ហើយបើដាក់ស្ទួតើមួយស្ទួ ក្នុងមួយស្ទួដែលអ៊ំ គេដាក់ខ្នោះជាមួយហ្នឹងមានគ្នាប៉ុន្មាននាក់ ហើយស្ថាននៃស្ទួហ្នឹងគេដាក់យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺថាគេចាប់ដាក់បន្ទប់រួមហ្នឹងមានគ្នាច្រើន មួយស្ទួហ្នឹងមួយរនងហ្នឹង គេហៅថាខ្នោះឃ្នាង ហៅឃ្នាងមានដាក់កងជើងសងខាងពីរ ហើយគេស៊កនរនងដែកថ្នាំងអំពៅហ្នឹងក្រោមកែងជើងហ្នឹងរហូតទៅប្រហែលជាគ្នាប្រាំនាក់ ដប់នាក់ មួយអាររនងៗ វែងៗប្រហែលពីនេះទៅកន្លែងនោះ ដែកហ្នឹង ។ ហើយដេកទល់ក្បាលគ្នា ។ ខ្ញុំដេកជើងមកកើត មានខ្លះដេកក្បាល ជើងមកខាងលិច ខ្ញុំដេកជើងទល់កើត ជញ្ជាំងខាងកើត ។

**ស៖** អ៊ំអាចងើបង្គុយបានទេ បើដាក់ជើងទាំងពីរអ៊ីចឹង អាចងើបអង្គុយបានដែរទេ?

**ឆ៖** ទៅហ្នឹងគឺខ្ញុំងើបអង្គុយបាន ប៉ុន្តែ បត់ជើងបត់ដៃអីទាល់តែសុំច្បាប់គេ ។ ឈឺបត់ជើងបត់ដៃនៅកេះគ្រាប់ខាងចុងជើងហ្នឹង កែសគ្រាប់ ហ្នឹងបត់ជើងធំ បត់ជើងតូចមានប៊ីដុងមួយប្រហែលជាចំណុះប្រាំលីត គេដាក់នៅចុងជើងហ្នឹង ។ ទឹកនោមផ្សេង លាមកផ្សេង ។

**ស៖** ហើយអ្នកណាជាអ្នកយកលាមក ឬក៏ទឹកទោមចាក់ចោលអ៊ំ ឬមួយក៏ទុកអ៊ីចឹងរហូត?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកប្រធាន! គឺថាពេលនុ៎ងគឺមានអ្នកធ្វើការនៅហ្នឹង នៅក្នុងអគារបន្ទប់រួមហ្នឹងគឺមានក្មេងហ្នឹងអាយុប្រហែលជា១៥-១៦ឆ្នាំ យើញរែកលាមកហ្នឹង ហើយនិងទឹកនោមហ្នឹងចុះមកក្រោម មិនមែនអ្នកទោសទេ អ្នកទោសនៅដេកក្នុងគុកគិតតែពីដេកតែម្តង ។ មួយថ្ងៃៗដេកក្តៅខ្នងអស់ហើយ នៅលើឥដ្ឋ ។

**ស៖** របបហូបចុកអំមិញអ៊ំនិយាយហើយថា មានបបរាវៗ ហើយមានគ្រាប់អង្ករហ្នឹងមួយគ្រាប់ៗ ហើយជួនការហ្នឹងមានសម្លដែលមានទឹកសុទ្ធ ហើយមានត្រកួន ឬក៏បន្លែតិចតួចប៉ុណ្ណោះ ។ សំណួរសួរថា ពេលដែលគេផ្តល់របបឲ្យហូបហ្នឹង គេផ្តល់យ៉ាងម៉េចទៅ? របៀបក្នុងការផ្តល់ឲ្យហូបគេយកកាតូ ឬក៏មែល ឬក៏ដួសចានមកឲ្យអ៊ំ? ដួសពិសាអ៊ីចឹង ឬក៏គេចាត់វិធីយ៉ាងម៉េចនៅក្នុងការផ្តល់អាហារ? ហើយអាហារហ្នឹងគេផ្តល់មួយថ្ងៃប៉ុន្មានពេល? ប្រហែលជាម៉ោងប៉ុន្មាន?

[១០:១០:៥២]

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺថាពេលអាហារហូបចុកហ្នឹងគឺថា នៅពេលម៉ោងដប់ពីរក៏មាន ម៉ោងដប់មួយកន្លះ ដល់ដប់ពីរ ម៉ោងមួយ ហ្នឹងពេលថ្ងៃ ។ ពេលល្ងាចគឺច្រើននៅម៉ោងប្រាំ ឬម៉ោងប្រាំមួយ មិនទៀងទេ ។ គេរែកយកមក គេដាក់នៅកន្លែងហ្នឹង ហើយអ្នកណាមាត់ចេកចាចចុះឡើងប្រកែកគ្នាអី គេលេងដងរែកពីលើស្មាហ្នឹងវ៉ៃតែម្តងធឹង១១ វ៉ៃអ្នកទោសដែលប្រកែកគ្នា ដែលនិយាយគ្នា ដែលគេហាមមិនស្តាប់នោះ ។ ហើយខ្ញុំនឹងអាណោចក្នុងចិត្តថា អ៎!ធ្វើបាបមនុស្សដូចសត្វដូចធាតុ គ្រាន់តែជជែកគ្នាបន្តិចបន្តួច និយាយគ្នាបន្តិចបន្តួចមិនបាន ។

**ស៖** បបរហ្នឹងគេដាក់មក គេចែកឲ្យ ឬក៏អ្នកទោសហ្នឹងចែក នាំគ្នាចែកខ្លួនឯង ដួសយកដោយខ្លួនឯង? ឬក៏ខាងឆ្មាំគុកហ្នឹងគេដួសឲ្យ ហើយដួសដាក់ចាន មានស្លាបព្រា មានអីហូបស្រួលបួលទេ?

**ឆ៖** បាទ, អាហ្នឹងគេចែក គេដួសឲ្យលោកប្រធាន គេដួសឲ្យគ្រប់គ្នា ហើយស្លាបព្រាគឺឲ្យគ្រប់គ្នាអ៊ីចឹង ដល់ហូបហើយ គេប្រមូលទៅវិញអស់ហើយ គេមិនប៉ានទុកទេរបស់របរ ដែលធ្វើអត្តឃាតខ្លួនឯងកើតនោះ តាមខ្ញុំយល់ ។ យប់ៗគេមកវាវ ដេកមួយឆ្អឹះកៀនកោះក្បែរខ្លួនខ្ញុំដេកហ្នឹង ។

មិនដឹងគេរាវឆ្កឹះរកអីគេទេ គេខ្លាចមានដែកស្រួចដែកអីនៅក្បែរហ្នឹងអី តាមខ្ញុំយល់ ។

**ស៖** ចុះអ៊ំពេលស្រេកទឹកអី អ៊ំធ្វើម៉េច ពេលស្រេកទឹក?

**ឆ៖** ពេលស្រេកទឹកទាល់តែសុំច្បាប់គេ ខ្ញុំ បងខ្ញុំសុំហូបទឹក គេឲ្យហូបទៅ ។

**ស៖** អ៊ីចឹងបានន័យថានៅក្នុងបន្ទប់ឃុំឃាំងហ្នឹងគឺមានឆ្មាំគុកនៅទីនោះអចិន្ត្រៃយ៍អ៊ីចឹងតែម្តង? អ៊ំចាំឆ្លើយនៅពេលដែលភ្លើងក្រហមមានណាអ៊ំណា ។

**ឆ៖** ពេលដែលខ្ញុំត្រូវការហូបទឹកអី ខ្ញុំសុំច្បាប់គេ គេឲ្យហូប ។

**ស៖** *(ឮមិនច្បាស់ដោយសារមីក្រូហ្វូន)* អ្នកយាមអ៊ំៗ អ្នកយាម អ៊ំមិញអ៊ំអត់ទាន់ឆ្លើយទេ អ៊ំឆ្លើយអត់មានបើកមេក្រូ បានន័យថា នៅកន្លែងបន្ទប់ដែលឃុំឃាំងអ៊ំហ្នឹង ព្រោះអ៊ំថាឲ្យតែស្រេកទឹក អ៊ំសុំគេ អ៊ំបត់ជើងបត់ដៃអ៊ំត្រូវសុំគេ ។ សំណួរសួរថា តើមានវត្តមានអ្នកយាម ឆ្មាំគុកយាមនៅទីនោះអចិន្ត្រៃយ៍ទាំងយប់ទាំងថ្ងៃដែរឬទេ? ហើយបើមាននៅក្នុងបន្ទប់អ៊ំហ្នឹងមានអ្នកឆ្មាំគុកហ្នឹងប៉ុន្មាននាក់?

**ឆ៖** អាហ្នឹងតាមខ្ញុំយល់នៅយាមដើរខាងក្រៅហ្នឹង ដើរចុះដើរឡើងហ្នឹងច្រើនណាស់ ។ ចូលក្នុងហ្នឹងគេចាក់សោខាងក្រៅ លោកប្រធាន ។ ចាកសោខាងក្រៅហើយ ឃើញគេដើរតាមយ៉ខាងមុខហ្នឹង ចុះឡើងៗហ្នឹង ។

[១០:១៤:៣៤]

កាលណាត្រូវបត់ដៃបត់ជើងអី អាហ្នឹងដូចជានេះទេ ពីព្រោះថា នៅចុងជើងយើងហ្នឹងយើងត្រូវការនោមយើងនោមទៅ បត់ជើងតូច បត់ជើងតូចទៅ ត្រូវការបត់ជើងធំ បត់ជើងធំទៅ វាខ្នោះនៅជាប់ដដែល ។ ខ្ញុំវាភ្លេចភ្លាំងដែរអាត្រង់ហ្នឹង អារឿងសុំច្បាប់ផឹកទឹក ឬក៏ហូបទឹក ឬក៏បត់ជើងតូច ឬក៏បត់ជើងធំអីហ្នឹង អាហ្នឹងខ្ញុំមិនច្បាស់លាស់ទេ ប៉ុន្តែថាជើងនេះជាប់ខ្នោះ ។

[១០:១៥:១៥]

**ស៖** បញ្ហាអ៊ីចេះទេ ព្រោះបញ្ហាបត់ជើងបត់ដៃនោះ មានកែសគ្រាប់ មានប៊ីដុងទឹក ដែលគេទុករួចហើយ បញ្ហារបបហូប ខ្ញុំសួរហើយអ៊ំមិញ ប៉ុន្តែទឹក វាអត់មានពាងទឹក ឬក៏ប៊ីដុង ដបទឹកសម្រាប់ដាក់ទុកឲ្យអ្នកទោសផឹកទេ ហើយមនុស្សតែងតែស្រេកទឹក ។ អ៊ីចឹងបានយើងសួរថា ពេលស្រេកទឹកហ្នឹងធ្វើម៉េច? អាហ្នឹងបានអ៊ំបានឆ្លើយអ៊ំមិញថា បើសិនជាស្រេកទឹក យើងស្រែកសុំគេ ។ ហើយការស្រែកហ្នឹងបានន័យថាបើគេដើរខាងក្រៅ ទាល់តែយើងស្រែកឲ្យឮ តែបើគេនៅខាងក្នុងយើងអាចនិយាយតិចក៏គេឮដែរ ។ ព្រោះអ្នកដែលយាម ឆ្មាំគុកនៅខាងក្នុង ។ ប៉ុន្តែ អ៊ំនិយាយមិញថានៅខាងក្រៅ

ហើយសុំគេ ។

សំណួរមួយទៀត ចុះងូតទឹកនៅក្នុងអំឡុងពេលដែលអ៊ំជាប់ឃុំឃាំងនៅទីនោះ ព្រោះអ៊ំជាប់យូរ តាំងពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់៧៩ ជាងមួយឆ្នាំឯណោះ អ៊ីចឹងអ៊ំជាប់នៅទីនោះយូរជាងគេ សំណួរសួរថា ហើយចុះការដែលងូតទឹកវិញ តើយ៉ាងម៉េចដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺថាពេលងូតទឹកគឺស្រាតខោទាំងអស់គ្នា ស្រាត ហើយពន្លូតតាមខ្នោះក្រោមជើង ខ្នោះកងហ្នឹង ពន្លូតតាមហ្នឹងទៅ ។ ស្រាតជើងម្ខាងចេញសិន ហើយ ដល់ម្ខាងទៀត តាមជើងម្ខាងនេះទៀត ដោះជើងម្ខាងទៀតហើយតែម្តង ។ អាហ្នឹងឈោង *(ស្តាប់មិន បាន)* បាញ់ពីក្រៅទៅ ពីបង្អួច ពីក្រៅទៅ បាញ់ទុយោស្រោចអ៊ីចឹង ។ ខ្លះជោក ខ្លះមិនជោកអ៊ីចឹងទៅ ហើយយកខោអាវហ្នឹងផ្តិតទឹកហ្នឹង ដាក់ពូតនឹងកែសគ្រាប់ហ្នឹង ច្របាច់ពូតដាក់ក្នុងកែសគ្រាប់ហ្នឹង ទឹក ផ្តិតទឹកហ្នឹង ។ វេទនាណាស់ការងូតទឹកម្តងៗបាញ់សាចដូចស្រោចជ្រូក ស្រោចគោ ស្រោចក្របីអ៊ីចឹង គ្មានទឹកដាក់នៅហ្នឹងកន្លែងហ្នឹងសម្រាប់ហូប សម្រាប់អីអត់ទេ ។ ពេលសុំទឹកហូប អាហ្នឹងទាល់តែសូម គេហើយ ។ ធម្មតាតែងមានអ្នកយាមខាងក្នុង មានយាមខាងក្រៅលោកប្រធាន ។

[១០:១៧:៣៦]

**ស៖** អ៊ំ ចុះអ៊ំមិញអ៊ំនិយាយថា ស្រាតខោ ហើយយកមកផ្តិតទឹកហ្នឹង មានន័យថា ម៉េចទៅ ផ្តិតទឹកដើម្បីធ្វើអី?

**ឆ៖** ទឹកវាសើមនៅកន្លែងដេក សើមនៅកន្លែងឥដ្ឋហ្នឹង ផ្តិតពូតៗឲ្យជ្រះទៅ ឲ្យស្ងួតទៅ ហើយ ដេកលើឥដ្ឋហ្នឹងឡើងវិញ ទាល់តែឥដ្ឋហ្នឹងវាស្ងួតខ្លួនវាទៅ ផ្តិតហ្នឹងផ្តិតដោយវា កុំឲ្យវាពោរពេញច្រើន ពេក ផ្តិតឲ្យវាអស់ខ្លះ កុំឲ្យវាល្អាចល្អឹមពេក ។

**ស៖** អ៊ីចឹងគោលបំណងនៃស្រាតខោហ្នឹងគឺយកទៅផ្តិតទឹក ពេលដែលគេបាញ់ទឹកចូលហ្នឹង ក្នុង បំណងឲ្យកន្លែង ទឹកន្លែងដែលដេកហ្នឹងវាស្ងួត ដើម្បីអាចមានលទ្ធភាពដេកបាន ឬក៏វាឆាប់ស្ងួត ហើយ ងាយក្នុងការដេក អ៊ីចឹងទេ?

**ឆ៖** បាទៗ ត្រូវហើយលោកប្រធាន ។

**ស៖** ហើយប៉ុន្មានថ្ងៃទៅគេបាញ់ទឹក ដើម្បីឲ្យបានងូតរបៀបនេះ ដូចនេះម្តង?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ប្រហែលជាមួយអាទិត្យ ឬមួយក៏កន្លះខែមិនដឹងទេ ខ្ញុំភ្លេចហើយ មិនបានចាំអស់ ពីព្រោះវាយូរពេលហើយ រយៈសាមសិបប្លាយឆ្នាំហើយ ។ ប៉ុន្តែ គ្រាន់តែ

ដឹងថា ពេលងូតទឹកម្តងៗស្រាតននលកក ខ្ញុំថាមើលទៅដូចនរក ទាំងគេទាំងខ្ញុំទាំងអស់គ្នា ដល់មែនទែន វាសើចចំអកលេងសើច ខ្ញុំនិយាយខមាទោស តិចថា "អានេះតូចតែខ្លួនទេវើយ! អានេះខ្លួនធំដូចឃ្លោក!" ហ្នឹងក្មេងតូចៗអាយុ១៦-១៧ វានិយាយអ៊ីចឹង វានៅយាមនៅខាងក្នុង ។

**ស៖** នៅក្នុងអំឡុងពេលដែលអ៊ំជាប់ឃុំហ្នឹង ក្រៅពីការដោះខ្នោះអ៊ំនាំទៅសួរចម្លើយសួរថា តើមានការដោះលែងក្នុងករណីធម្មតា ដូចជាដោះលែងឲ្យហាត់ប្រាណអីអ៊ីចឹងដែរទេ ឬក៏អត់សោះទេ?

**ឆ៖** ខ្ញុំដូចជាភ្លេចដែរ ពីពេលនុ៎ងគឺថា ការហាត់ប្រាណអីដូចជាមិនដែលទេ ក្នុងបន្ទប់ខ្ញុំ ឬក៏ហាត់ដែរ ខ្ញុំភ្លេចក៏មិនដឹងលោកប្រធាន ពីព្រោះវាយូរពេកហើយ ។

**ស៖** នៅពេលដែលគេនាំអ៊ំទៅសួរចម្លើយ សួរថា របៀបក្នុងការដែលនាំអ៊ំយកទៅសួរចម្លើយ គេធ្វើយ៉ាងម៉េច?

**ឆ៖** គេសួរចម្លើយម្តងៗគេដាក់ខ្នោះ ហើយគេបណ្តើរទៅ បណ្តើរទៅក្រៅបរវេណគុកហ្នឹង ។ មិនដែលគេយកចម្លើយក្នុងគុកទេខ្ញុំ ។ បរិវេណគុកហ្នឹងចេញតាមរបងហ្នឹងចេញតាមរបងហ្នឹង កាច់មកក្រោយអគារ "A", អគារ "ក" ។ ខ្ញុំមើលផ្ទះមួយនៅកន្លែងនោះ ប៉ុន្តែឥឡូវគេនៅហើយ ។ ស្លាកស្នាមពីមុននុ៎ងបាត់អស់ហើយ ។ ឥឡូវ វាពិបាកយល់ ពិបាក សឹងថានាំភ្ញៀវទៅមើលកន្លែងហ្នឹងមិនកើតទេ សុទ្ធតែផ្ទះគេនៅអស់ទៅហើយ ។

[១០:២១:២៥]

**ស៖** គេដោះខ្នោះជើងអ៊ំ អាដោះរនងអ៊ំមិញហ្នឹង គេដោះខ្នោះជើងចេញរួច បានដាក់ខ្នោះដៃអ៊ំ ឬក៏គេដាក់ខ្នោះដៃអ៊ំរួច បានគេដកខ្នោះជើង?

**ឆ៖** សូមជម្រាបលោកប្រធាន! គឺថាគេបណ្តើរទៅសួរចម្លើយហ្នឹង ទៅដល់កន្លែងបន្ទប់មួយ ផ្ទះមួយហ្នឹង ឡើងទៅខាងលើ ។

**ស៖** អត់ទេអ៊ំ អត់ទេ ។ សួរពេលដែលដោះ ដោះអ៊ំ អ៊ំនៅក្នុង-- មិននៅកន្លែងគេឃុំឃាំង? ឃុំឃាំងគេមិនដាក់ខ្នោះជើង?

**ឆ៖** បាទៗ ។

**ស៖** ឥឡូវមនុស្សគេត្រូវការអ៊ំនាំយកទៅសួរចម្លើយ សួរថាពេលដែលគេចាប់ផ្តើមនាំអ៊ំ ព្រោះអ៊ំ កំពុងតែជាប់ខ្នោះជើង សួរថាតើគេដាក់ខ្នោះអ៊ំ ដាក់ខ្នោះដៃរួច បានគេដោះខ្នោះជើង ឬក៏គេដោះខ្នោះជើងចេញរួចរាល់ហើយ បណ្តើរអ៊ំចេញមកដល់ខាងក្រៅអគារ កន្លែងបន្ទប់ឃុំឃាំងបានគេដាក់ខ្នោះអ៊ំ

បានគេបណ្តើរចេញ?

**ឆ៖** គេដាក់នៅក្នុងនុំង ។ គេដោះខ្នោះជើងពីឃ្នាង កងពីរដាក់ជើងសងខាងហ្នឹង គេដោះអាហ្នឹង ហើយ បានគេដាក់ខ្នោះ ដាក់ខ្នោះហើយបានគេបណ្តើរចេញមកក្រៅចុះទៅកន្លែងក្រៅបរិវេណគុកទួលស្លែងហ្នឹង ។

**ស៖ មាន** អំឡុងពេលដែលគេបណ្តើរចេញហ្នឹងមានរុំមុខទេ? រុំ ?

**ឆ៖** បាទ, ចងមុខហើយបានគេបណ្តើរចេញក្រៅ ។

**ស៖** អ៊ំនិយាយអំពីពេលដែលទៅដល់កន្លែងគេត្រូវសួរចម្លើយ របៀបក្នុងការរៀបចំកន្លែងសួរចម្លើយហ្នឹង គេប្រព្រឹត្តចំពោះអ៊ំយ៉ាងដូចម្តេច?

**ឆ៖** គេហៅសុទ្ធតែអ្លែង សុទ្ធតែអា ហើយគេ-- ចូលទៅគេដោះខ្នោះ-- ដាក់ខ្នោះជើងហើយ ដាក់ឃ្នាង អាឃ្នាងខ្លីៗសម្រាប់ម្នាក់ៗ ប្រវែងប្រហែលមួយម៉ែត្រ ប្រវែងប្រហែលប្រាំពីរ ប្រាំបីតឹក ល្មមតែដាក់ជើងពីអ៊ីចឹង គេដាក់ចាប់ច្របាច់សោគ្រឹប ហើយគេបិទទ្វារបន្ទប់អស់ហើយ ហើយចាប់ផ្តើមបិទបង្អួច បិទបន្ទប់អីៗ-- ទេ! បង្អួចធម្មតាទេ គេមានចម្រឹងដេកគេ ។ អ៊ីចឹងអាចមើលឃើញថា នេះអគារ “A” អគារអីអ៊ីចឹងដែរ ។ ដល់នុំងបានគេចាប់ផ្តើមដាក់ខ្នោះ ដាក់នទងខ្លីហ្នឹងហើយ បានគេដោះខ្នោះដៃចេញ ហើយបានគេស្រាយមុខ ។ គេស្រាយមុខ គេចាប់ផ្តើមវ៉ៃសួរចម្លើយ ។ គេសួរថា ខ្ញុំចូល *សេអ៊ីអា,ការហ្បេប* ខ្ញុំមិនដឹងឆ្លើយថាម៉េច បើខ្ញុំអត់ដែលឃើញ អត់ដែលដឹង អត់ដែលអ្នកនាំសោះ ធ្វើការសុខៗហើយគេហៅមក គេចោទថាខ្ញុំចូល *សេអ៊ីអា* ថ្ងៃណា? ខែណា? អាណានាំចូល? ហើយខ្ញុំមិនដឹងឆ្លើយថាម៉េច និយាយដដែលៗ គេវ៉ៃអើយវ៉ៃ ។

[១០:២៤:៤៤]

ខ្ញុំថ្ងៃមុនឮលោក ឌុច និយាយដែរថា មានអ្នកខ្លះមិនហៅ មិនឆ្លើយ គេចេះតែវ៉ៃទៅ ។ វ៉ៃមែនវ៉ៃខ្ទេចខ្ទីអស់ខ្លួនខ្ញុំ រកសាច់កំណើតមិនឃើញទេ ។

**ស៖** អ៊ីចឹងក្នុងអំឡុងពេលគេសួរហ្នឹង មុននឹងសួរ គេនាំទៅដល់ដាក់ខ្នោះ ដាក់ឃ្នាងៗអ៊ំណាបានន័យថា ខ្នោះជើង អាខ្នោះជើងធ្វើអំពីឈើហ្នឹង អាប្រហោងៗហ្នឹង ស៊កអាហ្នឹងដាក់រួច ហើយអ៊ំអង្គុយផ្ទាល់ ឱ្យអង្គុយផ្ទាល់ឥដ្ឋ ហើយបានគេដោះខ្នោះដៃចេញ ហើយនិងដោះក្រណាត់រុំមុខចេញ ហើយអ៊ីចឹងបានសួរ ហើយពេលសួរហ្នឹងគឺ ក្នុងករណីមិនឆ្លើយតាមបំណងគេ ថាអី *សេអ៊ីអា* ឬ *ការហ្បេប* ហ្នឹងបានគេធ្វើទារុណកម្មដោយវាយអ៊ំនឹងរំពាត់ អ៊ីចឹងអ៊ំ?

**ឆ៖** ពេលនោះគេចាប់ផ្តើមដោះមុខ ស្រាយមុខ ដោះខ្នោះ ដាក់ឃ្នាង ដេកផ្កាប់មុខ គេឲ្យដាក់ដេកផ្កាប់មុខ ដេកផ្កាប់មុខហើយគេចាប់ផ្តើមវ៉ៃ ។ វ៉ៃមួយឆ្អែតអ៊ីចឹងគេសួរ គេសួរថា "អ្អែងចូល *សេអ៊ីអា* ថ្ងៃណា? ខែណា? ឆ្នាំណា? អ្នកណានាំចូលឈ្មោះអី?" ហើយខ្ញុំមិនដឹងឆ្លើយថាម៉េច ពីព្រោះមនុស្សធ្វើការសុខៗ មិនដែលទៅចូល *សេអ៊ីអា* ឯណា ខំបម្រើអង្គការពេលនោះហ្នឹង ការចាត់តាំងរបស់អង្គការហ្នឹងវា ដូចថាវាគ្មានពេលណានឹងដឹងខ្សែរយៈឯណា ចូលឯណា ខ្ញុំអត់ដឹង *សេអ៊ីអា* ហ្នឹងយ៉ាងម៉េចផង ។

**ស៖** អ៊ំមានប្រសាសន៍មិញថា គេដាក់ឃ្នាងជើងរួច ឲ្យផ្កាប់មុខ ដូចពិបាកយល់ ព្រោះខ្នោះជើងវាដាក់ខ្នោះអ៊ីចឹងអាចអង្គុយបាន ព្រោះវាជាឈើធំអ៊ីចឹង ឃើញទេ? ហើយមួយម៉ែត្រហ្នឹងយើងដាក់ឈើអ៊ីចេះអាចអង្គុយបាន ដល់ពេលយើងផ្កាប់មុខវិញ ទាល់តែផ្កាប់មុខរួចបានដាក់ខ្នោះជើង អ៊ីចឹងអត់អាចងើបអង្គុយបានទេ ។ អ៊ំគិតមើល ឥឡូវខ្នោះៗវាមានកម្ពស់-- វាឈើប្រហែលមួយអំមិញទេ? កាលណាបើយើងដាក់ខ្នោះហើយអង្គុយៗវាបនឹងឥដ្ឋ ហើយយើងរុញជើងចូលទៅដាក់ខ្នោះ អាហ្នឹងយើងអាចដាក់បាន ដល់ពេលយើងផ្កាប់មុខ ផ្កាប់ម៉េច វាទាល់តែត្រលប់ខ្នោះ ។ ក្រឡាប់ខ្នោះទេបានយើងអាចដាក់-- បានអាចអង្គុយ ដេកផ្កាប់មុខបាន? ឬមួយក៏គេដាក់ឲ្យអ៊ំដេកផ្កាប់មុខ ដោយសារដាក់ជាប់ឃ្នាងហ្នឹងរួចម្តងហើយ ធ្វើទារុណកម្មវ៉ៃរួច បានគេដោះឃ្នាងទៀត ត្រលប់មកដាក់ខ្នោះជើងវិញហើយអ៊ំ ឲ្យអ៊ំក្នុងស្ថានភាពអង្គុយវិញ? ឬក៏យ៉ាងម៉េច? អ៊ំពន្យល់ចំណុចនេះបន្តិចមើល ។

[១០:២៧:៤០]

**ឆ៖** បាទ,សូមជម្រាបលោកប្រធាន! មិនមែនខ្នោះឈើទេ ឃ្នាងហ្នឹងវាដេកថ្នាំងអំពៅវែងប្រវែងហ្នឹង ដាក់សម្រាប់តែម្នាក់ហ្នឹង ជើងពីរដាក់អ៊ីចឹងទៅ បានគេដោះខ្នោះខ្ញុំ ដែលបណ្តើរចេញពីគុកហ្នឹងណា ហើយបានគេដាក់ហើយ-- ដាក់ឃ្នាងហ្នឹងហើយ ដែកថ្នាំងអំពៅប្រវែងហ្នឹង ហើយមួយខាងណោះគេច្របាច់សោគ្រឹបជាប់ហើយ ហើយអាខាងនេះក្រមោងៗអ៊ីចឹង វាស៊កមកអ៊ីចឹង ក្រោមកែងជើងហ្នឹងហើយគេឲ្យយើងត្រលប់ដេកផ្កាប់មុខ ដើម្បីឲ្យគេវ៉ៃខ្នង ។ គេវ៉ៃ ទារុណកម្មវ៉ៃលើខ្នង ។ មិនមែនឈើទេដែកអាចបង្វិលអ៊ីចេះបាន ក្រឡាប់អ៊ីចេះបាន ។

**ស៖** អ៊ំត្រូវគេនាំទៅសួរចម្លើយហ្នឹងចាប់តាំងពីពេលដំបូងដែលអ៊ំមកដល់ ហើយឃុំខ្លួនបានមួយយប់ ឬក៏មួយពេលហ្នឹង គេនាំទៅសួរចម្លើយធ្វើទារុណកម្មអ៊ំតែម្តង ឬក៏យកមកឃុំឃាំងអ៊ំក្នុងរយៈពេលយូរដែរបាននាំទៅសួរចម្លើយ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកប្រធាន! គឺថាយកមកដាក់គុកយូរដែរ នៅក្នុងបន្ទប់រួម ហ្នឹងយូរណាស់ យូររហូតដល់ប្រហែលជាពាក់កណ្ដាលឆ្នាំ១៩៧៧ ខែ៥ ខែ៦ រហូតដល់នេះគេវៃសួរ ចម្លើយ ប្រហែលជាបួនប្រាំខែគ្រាន់តែនៅក្នុងគុកហ្នឹង នៅជាប់ខ្នោះហ្នឹង នៅបន្ទប់រួមហ្នឹង ។ ហើយ បានគេវៃសួរចម្លើយឆ្អែតឆ្អន់ហើយ បានថ្ងៃមួយហ្នឹងដូចខ្ញុំនិយាយខាងដើមបកទៅខាងដើមវិញបន្តិច គេ អំពាវនាវរកអ្នកចេះគូរ ។

**ស៖** អ៊ំរកនឹកឡើងវិញមើល ថាតើដែលមុននឹងបុគ្គលិកនៃមន្ទីរស-២១ ហ្នឹងនាំអ៊ំទៅសួរចម្លើយ ហើយធ្វើទារុណកម្មដដែលៗហ្នឹងប៉ុន្មានលើក ប៉ុន្មានសាដែរ? ហើយប្រភេទគេធ្វើទារុណកម្មលើអ៊ំហ្នឹង ដដែលឬក៏មានការផ្លាស់ប្ដូរប្រភេទនៃការធ្វើទារុណកម្មលើអ៊ំ?

**ស៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ដែលគេហៅ គេវៃសួរចម្លើយម្ដងៗហ្នឹង គឺថាអត់ មានផ្លាស់ប្ដូរអីទេ មានតែរំពាត់វៃរំពាត់ផ្ដៅ រំពាត់ខ្សែតី រំពាត់ឫស្សីពុះប៉ុនមេដៃ ប៉ុនពីរផ្ទាប់ហ្នឹងវៃ ។ វៃលើកទីមួយ លើកទីពីររហូត គឺថាព្រឹកពីម៉ោងប្រាំពីរ ដល់ម៉ោងដប់ពីរ ម៉ោងមួយ អីបានមកដល់ កន្លែងបានហូបបាយ ហូបទឹកបបររាវៗ ។ ដល់ពេលល្ងាចរហូតដល់ម៉ោងប្រាំមួយ ម៉ោងប្រាំពីរយប់ អីនោះ បានៗមកហូបបបរហូបបាយនៅក្នុងគុកវិញ ក្នុងបន្ទប់រួមវិញ ។ ហើយពេលនុំងគេវៃហើយ គេលែងដាក់ក្នុងបន្ទប់រួមហើយ គេដាក់នៅបន្ទប់មួយប្រលោះៗនៅក្រោម ។ ខ្ញុំសូមបញ្ជាក់ប្រាប់ថយ ក្រោយបន្តិចវិញ គេវៃសួរចម្លើយហើយគេអត់មកនៅក្នុងបន្ទប់រួមទៀតទេ នៅក្នុងបន្ទប់ខាងក្រោម ជាន់ ខាងក្រោមដែលបន្ទប់ មួយប្រលោះៗសម្រាប់ម្នាក់ៗ ។ ដល់ពេលបាយ គេរែកបាយយកហុចឲ្យ បើក ទ្វារហុចឲ្យ ។

**ស៖** អ៊ីចឹងសង្ខេបមកវិញមានន័យថា អ៊ំហ្នឹងជាប់ឃុំឃាំងហ្នឹងនៅក្នុងបន្ទប់ឃុំឃាំងពីរប្រភេទ ដំណាក់កាលដំបូង អ៊ំជាប់នៅក្នុងបន្ទប់រួមប្រហែលជាក្នុងអំឡុងពេលប្រាំខែ ហើយក្រោយមកបានគេនាំ ទៅអ៊ំទៅសួរចម្លើយ ដោយមានធ្វើទារុណកម្មវាយនឹងរំពាត់ ជាច្រើនហ្នឹង ហើយចាប់ពី ពេលនោះមកអ៊ំ មិនត្រូវបានគេយកនាំទៅឃុំឃាំងបន្ទប់រួម ឃុំឃាំងរួមទៀតទេ ។ គឺគេនាំអ៊ំទៅឃុំ ឃាំងដោយឡែក ដាច់តែម្នាក់ឯង អ៊ីចឹងមែនទែ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍! អ៊ីចឹងមែនហើយលោកប្រធាន ។

**ស៖** តើមានការធ្វើទារុណកម្មលើរូបអ៊ំហ្នឹង ប្រភេទផ្សេងដូចជាការឆក់ខ្សែភ្លើងជាដើមនោះ តើ មានដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មាន ។ ថ្ងៃមួយហ្នឹង គេវ៉ៃសួរចម្លើយហើយ គេបណ្តើរមកអគារ “D” ។ អគារ “D” មានប្រដាប់ស៊កឌុយឆក់ខ្សែភ្លើងនុំង ហើយដាក់បន្តខ្សែមកគេឆក់ ក្បែរកេត្តិភេទ ក្បែរភ្លៅ ។ ញ៉ាច់ទៅមានម៉េចអីម៉េចទេ សន្លប់បាត់មាត់ឈឹង ហើយគេយកទឹកមកជះ បានដឹងខ្លួនមកវិញ ។ ខ្ញុំតែដាក់វ៉ាប់សន្លប់ មិនដឹងភ្លើងប៉ុន្មានវ៉ុល ប៉ុន្មានវ៉ាត់ទេ ខ្ញុំមិនដឹងទេ ពេលដែលចាប់ឆក់ហ្នឹង ។ ហ្នឹងអគារ “D”, អគារ “ឃ” ។

[១០:៣៣:១១]

**ស៖** ចាប់ពីពេលអំមិញ យើងសួរទៅហើយថា អត់មានប្រាប់អំពីមានកំហុសអីទេ? សំណួរសួរថា ក្នុងអំឡុងពេលដែលទៅដល់ហ្នឹង ទៅក្នុងគុក នៅក្នុងគុកហ្នឹង មានដែលមានការសម្រេចពីក្រុមប្រឹក្សាជំនុំជម្រះអីថា សម្រេចដាក់ទោសអំហ្នឹង ប៉ុន្មានថ្ងៃ? ប៉ុន្មានឆ្នាំ? មានលក្ខណៈជាតុលាការអីចឹងមានការពិភាក្សាអីចឹងទេមុនទេ នៅក្នុងអំឡុងពេលនៃការដែលគេឲ្យជាប់ឃុំឃាំងនោះ?

**ឆ៖** ជម្រាបលោកប្រសាសន៍ ជម្រាបប្រសាសន៍លោកប្រធាន គ្មានទេ ។ គឺថាចូលទៅវាចាប់ដាក់នៅៗ គ្មានជំនុំជម្រះ គ្មានបញ្ហាពីណា ពីណីមកទេ ។ គ្រាន់តែថា ខ្ញុំមានថ្ងៃមួយ វាវ៉ៃពីខាងក្រៅឆ្អែតហើយ វ៉ៃហើយបណ្តើរចូលវិញ មកអាផ្លូវមួយ ដើមផ្លូវមួយទៅអគារ “D” អាដើមផ្លូវហ្នឹងកាលហ្នឹងមិនទាន់មានស៊ីម៉ង់ត៍ដូចឥឡូវទេ ផ្លូវដី ។ ខ្ញុំដំបៅពេញខ្លួនមកដល់វ៉ៃកន្លែងហ្នឹងមួយសាទៀត ហ្នឹង ហ៊ឹមហ៊ុយ ហើយមានម្នាក់មកប្រាប់ថា “អ្ហេ! កុំវ៉ៃងាប់ បងប្រាប់ថាកុំវ៉ៃងាប់ ទុក” ។

យើងខ្ញុំដេកវាឈឺពេក វាសុទ្ធតែដំបៅ ហើយវ៉ៃលើដំបៅ ខ្ញុំផ្កាប់មុខ-- ផ្ងារខ្នងដេកហ្នឹង កុំឲ្យវ៉ៃត្រូវដំបៅ ។ ហ៊ឹម ហ៊ុយ យកឈើ ឫស្សីវំពាត់រុកដំបៅខ្នង ដេកខ្នងផ្ទាល់ដីសុទ្ធតែគ្រាប់គ្រោះ គ្រាប់អីចូលក្នុងដំបៅ ។ វារុកៗទាល់តែក្រឡាប់មុខមកវិញបានវ៉ៃទៀត ថាខ្ញុំចង់សន្លប់ម្តងៗ ។

**ស៖** អ៊ំដល់ពេលណាបានគេត្រូវជ្រើសរើសអ៊ំទៅធ្វើជាអ្នកគូររូប?

**ឆ៖** ហ្នឹងនៅពេលមួយ គេយកខ្ញុំពីអាបន្ទប់ដោយឡែកហ្នឹងមកខាងលើដើម្បីព្យាបាល ។ ព្យាបាល របួសហ្នឹង សូមជម្រាបថាគ្មានថ្នាំទេ ទឹកអំបិលយើងមួយចានគ្រោងអីចឹង ចាក់លាង ថាខ្ញុំញាក់អ្វួយលើសឈឺ លើសវ៉ៃទៀត ។ ធម្មតាអំបិល ហើយនិងសាច់មនុស្ស គ្រាន់តែពន្លាត់កង្កែប ហើយប្រឡាក់ខ្ញុំឃើញថាវាញាក់អីចឹងហើយ ចុះខ្ញុំជាមនុស្ស ។ លោកប្រធានគិតមើលយ៉ាងម៉េច ទៅវិញអាហ្នឹងវាសម្បើមណាស់ វាឈឺណាស់ ។ ខ្ញុំជានេះ ជាដោយសារថ្នាំទឹកអំបិល ឈឺក្បាលវិលមុខ អី លេបថ្នាំគ្រាប់ទន្សាយ ។ អាថ្នាំគ្រាប់មូលៗដូចអាចម៍ទន្សាយអីចឹង យកមកឲ្យលេប ឈឺក្បាលវិល មុខអី ។

វេទនាណាស់ ។

**ស៖** ឥឡូវស្លាកស្នាមដែលរបួសដោយសាររំពៃហ្នឹង នៅៗសល់ដល់សព្វថ្ងៃទេអ៊ំ ឬក៏ផ្សះជាអស់ហើយ?

**ឆ៖** ផ្សះជាហើយ សូមជម្រាប ។ ប៉ុន្តែ សម្លាកពេញខ្នងហ្នឹងលោកប្រធាន តាំងពីដៃមកក៏ឃើញដែរ វាត់ចុងរំពាត់ ដេកផ្កាប់មុខរំពៃតាមចិត្ត ។ ម្នាក់ៗរំពៃមួយហាត់ៗ ប្រាំនាក់រំពៃម្តង ។

**ស៖** ឥឡូវសូមមើលសម្លាកបន្តិចបានទេ?

**ឆ៖** បាទ, បាន ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីទនស្តី៖**

លោកប្រធាន ខ្ញុំអនុញ្ញាត សូមឲ្យសម្រាកបន្តិចមុននឹង មុនពេលលោក ប៊ូ ម៉េង បង្ហាញពីស្លាកស្នាម ។ ថាតើសមស្របដែរឬទេ ដើម្បីឲ្យគាត់គិតថា ពេលមួយដើម្បីសុំលើកបន្តិចមុននឹងអាចបង្ហាញបាន ។ សូមអរគុណ ។

[១០:៣៨:០៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយសឹមបន្តដំណើរការសវនាការដេញដោលតទៅទៀត ។

*[សវនាការសម្រាកពីម៉ោង ១០:៣៩ នាទី ដល់ម៉ោង ១១:០២ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ហើយអង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគី និងសាធារណជនថា អង្គជំនុំជម្រះលុបចោលនូវការកិច្ចនៃការបង្ហើយអ្នករស់រានមានជីវិត ប៊ូ ម៉េង បង្ហាញនូវស្លាកស្នាមរបួសរបស់គាត់ ហើយការលុបចោលនេះ ទាំងភាគីក៏ហាមមិនឲ្យធ្វើដូច្នេះដែរ ។

ម៉េចទៅមានបញ្ហាអីទៀតហើយ?

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។

ខ្ញុំសូមស្នើឡើងថា យើងអាចបន្តនៅក្នុងសវនាការជាអសាធារណៈ ហើយនៅពេលនោះ គឺលោក ប៊ូ ម៉េង អាចបង្ហាញនូវលើស្លាកស្នាមរបស់គាត់ជូនភាគី ចំណុចនេះ គឺវាជាគុណប្រយោជន៍របស់យើងដែរ ។

**សួរដោយប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះសម្រេចរួចហើយ លុបចោលនូវនីតិវិធីនៃការបង្ហាញនេះ ទោះបីអសាធារណៈក៏ដោយ ។ ក្នុងករណីចាំបាច់ គឺអាចបង្ហាញដោយរូបថត ។

**ស៖** អ៊ំ ប៊ូ ម៉េង តើអាចបង្ហាញត្រឹមកម្រិតថតរូប នៃស្លាកស្នាមរបួស ស្លាកស្នាម សម្លាកលើខ្នងរបស់អ៊ំដោយរូបថត យកមកបញ្ចាំងបង្ហាញដល់អង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺខ្ញុំគ្មានទេរូបថត មានតែសម្លាកនៅលើខ្នងហ្នឹងជាក់ស្តែង នៃរូបខ្ញុំផ្ទាល់ ។

**ស៖** សម្លាកហ្នឹងហើយ អង្គជំនុំជម្រះនឹងសូមថតជារូបថត ហើយយកមកបង្ហាញនៅក្នុងកញ្ចក់អេក្រង់ទូរទស្សន៍នេះ អ៊ំអនុញ្ញាតយល់ព្រមទេ?

**ឆ៖** បាទ, យល់ព្រម ។

**ស៖** បន្តទៀត អ៊ំត្រូវបានគេជ្រើសរើសអ៊ំធ្វើជាអ្នកថតរូបហ្នឹងនៅពេលណាដែរ? ចាប់ពីពេលណាដែរ? អ្នកគូររូប ជាងគូររូបហ្នឹងនៅពេលណាអ៊ំ?

[១១:៥០:៣៨]

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គេចាប់ផ្តើមប្រហែលជា១ចុងឆ្នាំ៧៧ ពីព្រោះថាដើម ឆ្នាំ៧៨ ហ្នឹងខ្ញុំចាប់ផ្តើមគូរ ក្នុងនុំងគូរបានមួយផ្ទាំង ។ ថ្ងៃមួយឮសួរមេក្រូពី១ស្អាតអូឡាំពិកហ្នឹងគេធ្វើ បុណ្យខួបអីគេទេ ឮសួរភ្លេងហ្នឹង ថ្ងៃហ្នឹងគេឲ្យស៊ីហូបចុកឆ្អែតឆ្អន់ណាស់ មានតាំងពីគុយទាវ ហ៊ំគេ រែកមក ពួកអាឆ្មាំគុកហ្នឹងគេរែកយកមកឲ្យហូប ។ ដូចថាអំណរបុណ្យគេហ្នឹង បានហូបឆ្ងាញ់គុយទាវ ។ ខ្ញុំពីរនាក់ ណាត ហ្នឹងស៊ី ហូបហើយហ្នឹង ណាត គេថា អញលោតឲ្យវាធ្លាក់ទៅក្រោមឲ្យហូបបានច្រើន ហ្នឹង វ៉ាន់ ណាត ។ ខ្ញុំនឹកឃើញរឿងហ្នឹងឡើង ខ្ញុំដូចអស់សំណើចដែរ ធម្មតាមួយក្រពះវាមិនដែលទៅហូប រលាក់ទៅបានពីរក្រពះទេ វានៅតែមួយក្រពះដដែល ។

ចាប់ផ្តើមគេគូរហ្នឹងក្នុងឆ្នាំបើមិន៧០ ចុងឆ្នាំ ដើមឆ្នាំ៧៧ ចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨ ពីព្រោះរូបទាំងអស់វាមានបួនផ្ទាំង ។ ក្នុងមួយផ្ទាំងហ្នឹង ឌុច សួរខ្ញុំថា “គូរប៉ុន្មានខែ ប៉ុន្មានថ្ងៃហើយ ដូច ហើយៗដូច ទៀតហ្នឹង មិនមែនហើយៗមិនដូចទេ “ប៉ុន្មានខែ ប៉ុន្មានខែដូច” ។ ខ្ញុំថា សុំរយៈពេលបីខែក្នុងមួយផ្ទាំង ផ្ទាំងហ្នឹងវាធំ ទទឹងរូបប្រហែលជាមួយម៉ែត្រកន្លះ កម្ពស់រូបមួយកំណាត់ខ្លួនហ្នឹង គ្រាន់តែខ្ញុំឈរកំពស់ក្បាល ប៉ុល ពត តែម្តង មួយជំហរដៃខ្ញុំ ។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញរូប ប៉ុល ពត នេះហើយដែលជារូបគំនូរ ថតពីរូបគំនូរ ប៉ុល ពត ដែលខ្ញុំគូរ ។ ខ្ញុំរស់ដោយសារគូររូប ប៉ុល ពត ហ្នឹងដូច គេក៏ទុកសិនទៅ គេថា ទុកសិនទៅ ទុករហូតដល់មក ៧ មករា ហ្នឹងខ្ញុំត្រូវរួច ។ ហ្នឹងខ្ញុំសូមជម្រាបប្រសាសន៍លោកតុលាការ ។

**ស៖** នៅក្នុងអំឡុងពេលដែលគេដោះលែងអ៊ំ ឲ្យទៅគូររូបហ្នឹងអ៊ំទៅគូររូបនៅកន្លែងណា? ហើយមានអ្នកណាផ្សេងទៀតធ្វើការជាមួយអ៊ំដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធានអង្គចៅក្រម! គឺមានខ្ញុំ ប៊ូ ម៉េង មួយ, វ៉ាន់ ណាត ពីរ, អៀម ចាន់ ជាងចម្លាក់ឈើបី, ជាង ទូច ជាងសូនរូបមួយទៀត ។ ហើយតែប៉ុណ្ណឹងទេ ធ្វើការនៅក្នុងកន្លែងអគារ “E” អគារដែលចំកណ្តាលសព្វថ្ងៃនេះ គេដាក់កន្លែងទទួលភ្ញៀវ ។ ភ្ញៀវបរទេសអីចេញចូលមើល ទស្សនាសារមន្ទីរគុកទួលស្លែងហ្នឹង កន្លែងហ្នឹង ។

**ស៖** ចុះរបបហូបចុកចាប់ពីអ៊ំបានទទួលមកធ្វើជា ជ្រើសរើសមកធ្វើជាជាងគំនូរហ្នឹង របបហូបចុកយ៉ាងម៉េចដែរ? ដូចជាអ្នកទោសដែរ ឬក៏របបហូបយ៉ាងម៉េច?

**ឆ៖** បាទ, សូមជម្រាប លោកប្រសាសន៍ប្រធានអង្គចៅក្រមជាទីគោរព! គឺថាការរបបហូបចុកហ្នឹង គឺគេបន្ធូរបន្ថយ ។ បន្ធូរយ៉ាងម៉េច? បន្ធូរពីហូបមួយវែក ទឹកបបររាវៗ មកការហូបបាយរឹងហើយមានសម្លគ្រប់គ្រាន់ ឆ្នាំគុកហ្នឹង វែកយកមកដាក់នៅកន្លែងអគារ “E” ហ្នឹង ឲ្យខ្ញុំដួសចែកគ្នាហូបហ្នឹងហូបគ្រប់គ្រាន់ ។

**ស៖** ក្នុងអំឡុងពេលដែលអ៊ំ ទទួលបានជ្រើសរើសមកជាងគំនូរហ្នឹង អ៊ំគេឲ្យទៅសម្រាកពេលយប់នៅកន្លែងណាដែរ? ពេលៗដេក ពេលដេកពេលយប់នៅកន្លែងណា?

**ឆ៖** កន្លងមកហ្នឹងគឺថា គូរហើយ ដល់ទៅពេលសម្រាកដេកយប់ គឺនៅក្នុងបន្ទប់ម៉ាស៊ីនភ្លើងនៅជិតអគារ“E” ហ្នឹង ក្រោយអគារ “E” ហ្នឹង ។ ជំនាន់នុំងមានម៉ាស៊ីនភ្លើងមួយ កាលណាភ្លើងចរន្តក្រៅ ដាច់គេបញ្ចេះម៉ាស៊ីនភ្លើងហ្នឹង ហើយបន្ទប់ម៉ាស៊ីនភ្លើងហ្នឹងនៅហ្នឹង ខ្ញុំដេកនៅហ្នឹង ។

**ស៖** គេដាក់ខ្នោះអ៊ំទេ ឬក៏គេបិទចាក់ក្នុងដាក់អ៊ំក្នុងបន្ទប់ សម្រាកក្នុងបន្ទប់ ហើយបិទចាក់សោពីខាងក្រៅដែរឬទេ?

**ឆ៖** គេដាក់ក្នុងបន្ទប់ហ្នឹង តែគេអត់មានបានដាក់ខ្នោះទេ ដេកធម្មតា ជុំរោងជាមួយគ្នា អ៊ឹង ប៊ុច, វ៉ាន់ ណាត, អៀម ចាន់, ផា ថនចាន់, រុយ នាគង់ ទាំងអស់គ្នាប្រាំពីរនាក់ ជុំ ម៉ី ។ សូមអនុញ្ញាតមើលរូប អ៊ឹង ប៊ុច , ផា ថនចាន់, ប៊ូ ម៉េង, វ៉ាន់ ណាត, អៀម ចាន់, រុយ នាគង់, ជុំ ម៉ី ឥឡូវនៅសល់តែ ជុំ ម៉ី , វ៉ាន់ ណាត, ប៊ូ ម៉េង សល់តែបីនាក់ បួននាក់ស្លាប់ដោយជំងឺ ។

**ស៖** នៅក្នុង--

**លោកស្រី ស៊ីលឃីស្ទូត ហ្វ៊ីនស្តី៖**

លោកប្រធានខ្ញុំស្នើសុំតុលាការឲ្យបង្ហាញនូវរូបភាពនេះ ដែលសាក្សីគាត់ ដែលដើមបណ្តឹងរដ្ឋប្បវេណីគាត់បង្ហាញនេះនៅផ្ទាំងអេក្រង់ ។

**ប្រធានអង្គជំនុំ៖**

ដូចមិនទាន់ដល់ពេលទេ ។ នេះជាការដឹកនាំគ្រប់គ្រងសវនាការហើយ យើងជាអ្នកគ្រប់គ្រងសវនាការ ។

**សួរបន្តដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំនៅក្នុងអំឡុងពេល កាលដែលអ៊ំ គេឲ្យគូររូបហ្នឹង អ៊ំបានជួបជាមួយនឹងជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែរឬទេ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកប្រធាននៃអង្គចៅក្រមជាតិ និងអន្តរជាតិជាទីគោរព! គឺថាពេលនុ៎ង លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង នៅអង្គុយក្បែរតែខ្ញុំ មើលខ្ញុំគូររូបបងធំទីមួយហៅ ប៉ុល ពត ហ្នឹង ។ ហើយបង្គាប់បញ្ជាខ្ញុំថា “នែ៎!អាគូរ អានេះកែមិនមែនកពកទេ ប៉ុវាធ្លាក់ កែសម្រួលឲ្យស្រួលទៅកុំឲ្យដូចរូបហ្នឹងពេក” ខ្ញុំក៏កែសម្រួលទៅ ។ អ៊ីចឹងបានថា សូមបង្ហាញរូបថតនេះ នេះជារូបថតពីគំនូរខ្ញុំគូរ ។ សមរម្យមិនធ្លាក់ដូច កពកទេ ។

**ស៖** គាត់អញ្ជើញមកទីនោះញឹកញាប់ទេ មកមើលអ៊ំគូរហ្នឹងមកៗញឹកញាប់ទេ? ហើយមកៗពេលណា? ពេលយប់ ឬក៏ពេលថ្ងៃ?

**ឆ៖** នៅពេលថ្ងៃ ដែលគាត់មកហ្នឹង គឺច្រើនតែពេលថ្ងៃ ហើយគាត់ស្លៀកខោអាវ ខោខ្លីពាក់អាវ ដៃខ្លី ខោខ្មៅ គាត់ចូលមកអង្គុយគងទាក់ខ្លា មើលខ្ញុំគូរ ជួនអីគាត់បង្គាប់ខ្ញុំឲ្យគូររូប ហ្

ជីមិញៗ ខ្លួនឆ្អែ ក្បាលជា ហូ ជីមិញ ។ អាហ្នឹងគូរជាគំនូរ *ការីកាទៀ* អាគំនូរខ្សៀក គូរហើយមានផ្ទះបាក់ដំបូល នៅក្នុងទឹកមហាសមុទ្រខ្យល់ប៉ើង ស្បូវរប៉ាត់រប៉ាយ ព្យុះសង្ឃរា ទឹកលិច ជន់ផ្ទះ ។ ខ្ញុំនៅចាំកាលនោះគាត់បង្គាប់ឲ្យខ្ញុំគូរច្រើនណាស់ រូប ។

**ស៖** ហើយ អ៊ំកត់សម្គាល់ឃើញថា អាកប្បកិរិយារបស់គាត់ហ្នឹងយ៉ាងម៉េចដែរ? នៅពេលអំឡុងពេលដែលគាត់មកមើលអ៊ំ នៅក្នុងអំឡុងពេលដែលអ៊ំគូររូបហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន! គាត់មិនមានបញ្ហាអីវ៉ែដំច្រំធាក់ណាស់ណាទេ តាមមើលពេលនុ៎ង គឺថាគ្រាន់តែថ្ងៃមួយមិនដឹងជាខ្ញុំខុសអី ពីរនាក់ អៀម ចាន់ ហ្នឹង គាត់ថា ឥឡូវវ៉ៃគ្នាពីរនាក់ហ្នឹងមើលអាណាយកទុយោមួយមើល ទុយោខ្មៅប៉ុនកដៃហ្នឹង ប្រវែងហ្នឹងមកវ៉ៃគ្នាម្តងម្នាក់មើល។ អ្នកណាវ៉ៃមុន អ្នកណាវ៉ៃក្រោយ វ៉ៃមកមើល ។ អង្គុយខ្ញុំមើលខ្ញុំវ៉ៃគ្នា ។ វ៉ៃឌឹបចុះ ឌឹបឡើងៗ បានមួយសន្ទុះគាត់ថា ឈប់ទៅ ។ កាលណាខ្ញុំគូរហ្នឹង គូរដូចបានមួយផ្ទាំងអីចឹង គូរផ្ទាំងពីទីពីរ គូរផ្ទាំងទីបី គូរផ្ទាំងទីបួន ប៉ុន្តែអាមួយផ្ទាំងចុងក្រោយនៅសល់ វាបាត់ទៅ នៅសារមន្ទីរហ្នឹងធ្វើបាត់ទៅ មិនដឹងជាបាត់ដោយប្រការណាទេ ខ្ញុំមិនដឹងដែរ ។

**ស៖** អ៊ំៗចាំឆ្លើយសំណួរ សួរថា អ៊ំមានបានសង្កេតទេនូវអាកប្បកិរិយា ឬក៏ទឹកមុខនៃជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង នៅក្នុងអំឡុងពេលដែលគាត់ទៅមើលអ៊ំគូរហ្នឹង ដែលគាត់រីករាយគាត់ក្រៀមក្រំ ឬក៏មនុស្សពោរពេញទៅដោយទុក្ខព្រួយ ឬក៏មានវិបត្តិអីចឹង តើអ៊ំមានការកត់សម្គាល់ឬក៏សង្កេតអំពីបញ្ហានេះដែរឬទេ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកប្រធាន! គឺថាទឹកមុខគាត់ធម្មតា ដូចជាគ្មាន ដូចថាប្រែប្រួលអីទេ ត្រូវសើចៗ ត្រូវគាត់ញញឹមៗទៅ ។ ខ្ញុំមិន មើលមុខគាត់ស្គាល់ ដឹងទឹកមុខគាត់ ប៉ុន្តែវាមិនស្គាល់ចិត្តគាត់ ។ អាហ្នឹងពាក្យមួយគេថា “ស្គាល់មុខតែមិនស្គាល់ចិត្ត” ពាក្យហ្នឹងគេសួរខ្ញុំច្រើនណាស់ អ្នកកាសែតពិភពលោក គេសួរខ្ញុំច្រើនណាស់ ខ្ញុំថា “ខ្ញុំស្គាល់មុខ តែវាអត់ស្គាល់ចិត្តគាត់ទេ” ។ ពិតមែនតែនៅកិតកាលនៅក្បែរគូរមើលខ្ញុំហ្នឹង គាត់រហូតដល់គាត់ហូតបារីមួយកញ្ចប់ឲ្យខ្ញុំជក់ទៀតផង គាត់ពេញចិត្តនឹងគំនូរ ។

**ស៖** គាត់ដែលប្រព្រឹត្ត អំពើវាយដំ ផ្ទាល់ទៅលើអ៊ំដែរឬទេ ឌុច ហ្នឹង?

**ឆ៖** បាទ, មិនដែលផ្ទាល់ទេ ប៉ុន្តែគាត់ឲ្យ អៀម ចាន់ វ៉ៃខ្ញុំ ឲ្យខ្ញុំវ៉ៃ អៀម ចាន់ ។ ត្រង់ហ្នឹងមួយខ្ញុំដូចថា វាដូចថាវា វាមិនសប្បាយចិត្ត ហាក់ដូចជាខ្ញុំហ្នឹងវាអមនុស្ស ដូចជាមិនមែនមនុស្ស វាបាត់សិទ្ធិ

ជាមនុស្ស ។

**សៈ** អ៊ំដែលឃើញគាត់ដើរ ធ្វើដំណើរតាមពីអគារមួយទៅអគារមួយ នៅក្នុងបរិវេណនៃអគារ A, B, C, D អីអ៊ីចឹងដែរទេ ឬក៏គាត់ចូលមកនៅក្នុងបរិវេណ នៃមន្ទីរសន្តិសុខស-២១ គាត់ចូលត្រឹមតែកន្លែងដែលអ៊ំគូររូបទេ?

[១១:១៧:៤៩]

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំមិនបានឃើញគាត់ដើរនៅតាមអគារមួយៗទេ តែគាត់ចូលមកគាត់បាញ់ចិត្តតែលើរឿងរូបថតបងទីមួយរបស់គាត់នោះ ប៉ុល ពត ហ្នឹង ។ ឃើញញឹកកន្លែងខ្ញុំគូរតែម្តង ឃើញមកតែកន្លែងហ្នឹង ញឹកញាប់ កន្លែងផ្សេងទៀត ខ្ញុំមិនដែលឃើញ ។ អានេះខ្ញុំនិយាយតាមការពិត ។

**សៈ** ចុះក្រៅពីអ៊ំ តើអ៊ំធ្លាប់បានឃើញថា គាត់បានធ្វើទារុណកម្ម ឬក៏វាយដំ វាយតប់ទៅលើអ្នកដទៃផ្សេងទៀតទេ?

**ឆៈ** បាទ, ជម្រាបប្រសាសន៍លោក! ខ្ញុំនិយាយថយក្រោយបន្តិច ថ្ងៃមួយមានជនជាតិវៀតណាមគេអួតខ្លួនគេ គេថាគេចេះសូនរូប ដល់គាត់យកដីឥដ្ឋ ឲ្យកូនចៅគាត់យកដីឥដ្ឋ មកច្របាច់ពូតចុះឡើងៗ មិនដឹងជាស្អីៗទេ មើលទៅគាត់ថា អ្ហែ!អាហ្នឹងបែបមិនកើតទេ អាហ្នឹងរបៀបគាត់ធ្វើតេសអាវៀត-ណាមហ្នឹង ។ គាត់ឲ្យពួកវ៉ៃមនុស្សហ្នឹង ធ្វើទារុណកម្មមនុស្សហ្នឹងទាត់ម្នាក់មួយជើង ស្ទុតដូចបាល់អ៊ីចឹងព្រោះវាអួតថាចេះ ហើយដល់ធ្វើ វាធ្វើមិនកើត ។ អាហ្នឹងវារឿងមួយដែលភរភូតៗគាត់ តាមខ្ញុំយល់ ។ គាត់ក៏ធ្វើទារុណកម្មហ្នឹងមួយសន្ទុះ ក៏មិនដឹងទៅណា អាវៀតណាមហ្នឹងបាត់ទៅ ចេញពីកន្លែងមុខខ្ញុំហ្នឹងទៅ ។

**សៈ** គាត់បញ្ជា បញ្ជាខ្លួនគាត់ ឲ្យទៅពួកសន្តិសុខក្រោមកូនចៅរបស់គាត់ហ្នឹង ធ្វើទារុណកម្មហើយបើគាត់បញ្ជា គាត់បញ្ជាប្រើសម្តីថាម៉េចទៅ? អ៊ំចាំទេនូវពាក្យសម្តីនៃការបញ្ជារបស់ ឌុច ចំពោះកូនចៅរបស់គាត់ក្នុងការធ្វើទារុណកម្ម ដែលថាអ៊ំអះអាងថាជនជាតិវៀតណាម អម្បាញ់មិញនេះ?

**ឆៈ** បាទ, អានេះ ខ្ញុំសូមជម្រាបប្រសាសន៍លោកប្រធាន! ពីព្រោះខ្ញុំវា ដូចជាភ្លេចភ្លាំងខ្លះ ឬមួយក៏គាត់ឲ្យជាសញ្ញាដល់កូនចៅគាត់ ក៏មិនដឹងទេណ៎ា! ស្រាប់តែឃើញអាវៀតណាមហ្នឹង ចេញពីហ្នឹងបាត់ទៅចេញពីហ្នឹងទៅចេញពីមុខខ្ញុំទៅ ចេញពីកន្លែងអគារខ្ញុំគូររូបឆ្លាក់ហ្នឹងទៅ មានជាងឆ្លាក់មានជាងគូរ មានជាងឆ្លាក់ឈើ មានជាងសូនរូប មានជាងគំនូរ ។ វាចម្រុះគ្នាអ៊ីចឹងក្នុងហ្នឹង ។

**ស៖** អ៊ំឃើញថា អ្នកឆ្មាំគុកដែលវាយទៅលើអ្នកដែលអះអាងថា ចេះសូនរូបហ្នឹង វាយនៅក្នុងបរិវេណអាកន្លែងដែលគាត់ គេបញ្ជាឲ្យធ្វើរៀបចំសូនរូបនៅក្នុងអគារ “E” ហ្នឹង ឬក៏នាំចេញទៅក្រៅបានគេវាយតប់នោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ពេលនុ៎ង គឺវាដូចថាគ្នាបីបួននាក់ហ្នឹងទាត់មួយនាក់មួយជើង ស៊ុតចុះ ស៊ុតឡើង អាវៀតណាមហ្នឹង គ្នាអន់ឱ ដល់ឃើញអ៊ីចឹង ឃើញបណ្ដើរចេញទៅក្រៅប៉ុន្តែមិនដឹងទៅណា អត់មានឮសួរបញ្ជាពីគាត់ទេ ។ អាហ្នឹងពេលដែលធ្វើទារុណកម្មហ្នឹង ឃើញបាត់ រូបគាត់ហើយ គាត់ចេញបាត់ហើយ ហើយឃើញតែអាពួកធ្វើទារុណកម្មហ្នឹង វាមកវ៉ៃតប់វៀត-ណាម ហ្នឹង ។

[១១:២១:៤៩]

**ស៖** សរុប អំឡុងពេលដែលគេឲ្យជ្រើសរើសឲ្យអ៊ំធ្វើជាជាងគំនូរហ្នឹង អ៊ំគូរបានរូបសរុបហ្នឹងប៉ុន្មានផ្ទាំងដែរទៅ? ហើយរូបអីខ្លះ?

**ឆ៖** ទាំងអស់មានបួនផ្ទាំងរូប ប៉ុល ពត ហ្នឹង។ ប៉ុន្តែ នៅសល់មួយផ្ទាំងនៅក្នុងឆ្នាំ១៩៨១ មានអាល្លឺម៉ង់ វាមកថតជាខ្សែភាពយន្ត ដាក់ឈ្មោះថា “រឿងអង្គការ ស្អីវានោះ” ។ ខ្ញុំបើករូបថតដែលខ្ញុំគូរហ្នឹងឲ្យគេមើល ហើយខ្ញុំចាំផ្ដើមយកថ្នាំបៀកខ្វែង ដូចថាខ្ញុំខឹងណាស់ លុបបំបាត់រូបហ្នឹង មិនចង់ឃើញរូបហ្នឹង ។ ខ្ញុំលុបខ្វែងអ៊ីចឹង លើរូបហ្នឹង ។ អាល្លឺម៉ង់គេថតទាំងអស់ ខ្សែភាពយន្តអង្គការ រឿងអង្គការស្អីវានោះ ។

**ស៖** ហ្នឹងរូបហ្នឹង អ៊ំគូរបានរូបច្រើន ព្រោះអំមិញ មានរូបឆ្កែអី រូបតុក្កតាអី ក្បាល ហូ ជីមិញ អីណាដែលអ៊ំបាននិយាយហ្នឹង ប៉ុន្តែដោយឡែករូប ប៉ុល ពត ហ្នឹង គឺរូបគូរបានតែបួនផ្ទាំងទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍ពិតមែនហើយ ខ្ញុំគូរបានបួនផ្ទាំងអ៊ីចឹងមែន ។

**ស៖** ប៉ុន្តែក្រៅពីរូបប៉ុល ពតហ្នឹង មានបងធំទីមួយហ្នឹង មានគូររូបអីផ្សេងទៀតទេ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោកប្រធាន! គឺមានគូររូប ហ្វា គួហ្វុង, ម៉ៅ សេទុង គូរផ្ទាំងធំៗដែរ ប៉ុនៗរូបបងធំទីមួយហ្នឹងដែរ ប៉ុល ពត ហ្នឹងដែរ ។

**ស៖** កាលដែលអ៊ំគូររូបហ្នឹង ដាច់ដោយឡែកពីគ្នាពីអ៊ំ វ៉ាន់ ណាត ឬក៏រូបមួយហ្នឹងយើងគូរចូលគ្នា រួមគ្នា ជាងពីរនាក់គូររូបមួយហ្នឹង ឬក៏រូបមួយអ៊ំគូរទៅ ហើយមួយទៀត វ៉ាន់ ណាត គូរដាច់ដោយ

ឡែកគ្នា អត់មានអាចចូលគ្នាបានទេ បច្ចេកទេសខាងជាងគំនូរនេះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ពីកាលហ្នឹង ខ្ញុំបានឃើញពិត និងដឹងពិត គាត់គ្មានជំនាញខាងគំនូរគូរស-ខ្មៅទេ ។ គំនូរស-ខ្មៅនេះ ថ្នាំខ្ញុំធ្វើដោយខ្លួនឯង សូមអនុញ្ញាតឲ្យគាត់ប្រើកូនចៅគាត់ទៅរកប្រេងកាតឲ្យខ្ញុំមួយលីត្រ ខ្ញុំដុតយកផ្សែងវា ដើម្បីត្រងដាក់កំប៉ុងទឹកដោះគោគ្របលើផ្សែងភ្លើងហ្នឹង ដើម្បីបានផ្សែងហ្នឹងច្រើន យកមកធ្វើជាថ្នាំគូររូបគំនូរស-ខ្មៅ ។ វ៉ាន់ ណាត គាត់មិនចេះគូរទេ គាត់គ្មានជំនាញខាងហ្នឹងទេ ។

[១១:២៤:៤៥]

**ស៖** អ៊ីចឹងបានន័យថា ការគូររូបហ្នឹង គឺធ្វើដាច់ដោយឡែកពីគ្នា មួយជំនាញខាងស-ខ្មៅ មួយជំនាញខាងពណ៌ ខាងផាត់ពណ៌ ខាងរូបពណ៌ អ៊ីចឹងន៎?

**ឆ៖** បាទ, ពិតអ៊ីចឹងមែន ។

**ស៖** ហើយអ៊ំបានលើកឡើងរូបបងធំទី១ ឬប៉ុល ពត អំមិញហ្នឹង គឺជារូបតែមួយក្នុងចំណោមរូបទាំងឡាយដែលអ៊ំបានគូរ អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ពិតជាអ៊ីចឹងមែន ។

**ស៖** (មន្ត្រីតុលាការយករូប ប៉ុល ពត ដែលគូរដោយអ៊ំ ប៊ូ ម៉េង បញ្ចាំងស្លាយ) ។ រូបនេះឬដែលអ៊ំអះអាងថា រូបដែលគូរដោយដៃអ៊ំ នៅក្នុងអំឡុងពេលដែលអ៊ំជាប់ឃុំឃាំងហើយគេបានជ្រើសរើសឲ្យទៅជាជាងគំនូរ គូររូបថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** បាទ, លោកប្រធាន គឺពិតជារូបហ្នឹងហើយ ។

**ស៖** អំមិញអ៊ំបានអះអាងថា ដោយស្នាដៃរបស់អ៊ំ ដែលបានគូររូបគំនូរនេះហើយ ដែលនាំឲ្យអ៊ំរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះ? វាហេតុផលយ៉ាងម៉េចទៅ អ៊ំអាចពន្យល់បញ្ហានេះបានទេ អំពីថាដោយហេតុផលនៃគំនូររូបមួយផ្ទាំងនេះ នាំឲ្យអ៊ំបានរស់រានមានជីវិតរហូតដល់សព្វថ្ងៃនេះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺថាហេតុផលដែលខ្ញុំយល់ គឺគូរដូច ដល់គូរដូចអ៊ីចឹងទៅ ចាប់ផ្ដើមគូរផ្ទាំទីពីរ ទីបី ទីបួន ទៅ ពន្យាររហូតដល់៧ មករា ១៩៧៩ នៅសល់មួយផ្ទាំង ។ ហើយរួចទៅកងទ័ពរណសិរ្សរំដោះជាតិហ្នឹង គេមកចូលមកវ៉ៃលុកនោះ ក៏ពេលហ្នឹងនៅគុកទួលស្លែងវាខ្ចាត់ខ្ចាយបាត់អស់ រត់បាត់អស់ មិនដឹងទៅណា បាត់អស់ទេ ។ ថ្ងៃហ្នឹង គេនាំខ្ញុំចេញពីគុកហ្នឹង ថានាំគ្នាចេញទៅក្រៅ ដើរឲ្យត្រង់ផ្លូវ តែអ្នកណាដើរចេញពីផ្លូវ បាញ់បាក់ជើង អូ! មិនហ៊ានទេ ដើរឡើង

ត្រង់ភ្លឹង មិនឲ្យងាកជើងចេញក្រៅទេ គោរពតាមបញ្ជាគ្នា ខ្លាចងាប់ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដករូបនេះចេញវិញ ។

**ស៖** អ៊ំ! នៅមានឯកសារមួយចំនួន អ៊ំបានឆ្លើយលើកមុនថា អ៊ំត្រូវបានគេបញ្ជូនអ៊ំទៅព្រៃស នៅក្នុងអំឡុងពេលមួយនោះ គឺបញ្ជូនទៅព្រៃស ។ ហើយនៅមួយរយៈ នៅព្រៃសនោះ ស្រាប់តែគេបញ្ជូនអ៊ំត្រឡប់មកកាន់មន្ទីរស-២១ គុកទួលស្លែងវិញ តើមានព្រឹត្តិហេតុនេះដែរទេ អ៊ំ?

**ឆ៖** ជម្រាបលោកប្រសាសន៍! ដូចគ្មានទេ ខ្ញុំនៅតែក្នុងគុកទួលស្លែងហ្នឹងរហូត ប៉ុន្តែបើជម្លៀសមាន ថ្ងៃបែកហ្នឹង ថ្ងៃ៧មករា ហ្នឹង យប់ហ្នឹងគេនាំខ្ញុំដើរកាត់តាមចំការដូង ដើរកាត់ទៅឈប់នៅព្រៃស អឺ!វាលបឹងជើងឯកហ្នឹងមួយរយៈ ប្រហែលជាប្រាំមីនុតក៏មិនដឹង ភ្លេចហើយ ក៏មានបញ្ជាមក ក៏យកទៅ នាំអ្នកពួកប៉ុល ពត ហ្នឹង នាំខ្ញុំទៅគុកព្រៃស នាំទៅគុកព្រៃស ប្រហែលជាបានទៅម្ភៃមីនុត ឬក៏ដប់មីនុតទេ ក៏ថា អឺ! ទៅទៀត ក៏ចេញទៅទៀតទាំងយប់ហ្នឹង ទៅទាំងយប់ហ្នឹង ។

[១១:៣០:០០]

**ស៖** អ៊ីចឹងបានន័យថា អ៊ំបានទៅដល់ព្រៃស គឺអ៊ំ ដោយសារការចេញនៅថ្ងៃទី០៧ មករា ពេលដែលកងទ័ពរណសិរ្សសាមគ្គីរំដោះជាតិកម្ពុជាហ្នឹង ចូលមករំដោះនៅក្នុងទីក្រុងភ្នំពេញហ្នឹង គឺអ៊ំត្រូវចាកចេញទៅជាមួយនឹងកងកម្លាំងនៃសន្តិសុខ ដែលតម្រូវបង្ខំឲ្យអ៊ំចេញទៅជាមួយគេទេ មិនមែនអ៊ំទៅលក្ខណៈដោយឡែកក្នុងអំឡុងពេលមុននោះទេ ។ អ៊ីចឹងទេគឺទៅ ទៅថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩ មែនទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ពិតមែនអ៊ីចឹងហើយ ចេញនៅពេលយប់ប្រហែលម៉ោងប្រាំមួយ ម៉ោងប្រាំពីរ ។ *(ឮមិនច្បាស់)* ចេញពីគុកព្រៃសហ្នឹងទៅទៀត ទៅទាំងយប់ ដើរមួយយប់វាស់ភ្លឺលោកប្រធាន ។ អូសជើង ដើរអូសជើង ។

**ស៖** អ៊ំចេញទៅហ្នឹង ទៅដល់ណា ហើយបានអ៊ំត្រលប់មកវិញ? អ៊ំៗកុំអាល អ៊ំមើលអាភ្លើងក្រហមបើមានភ្លើងក្រហមបានអ៊ំអាចនិយាយបាន បានឮ បើថាអ៊ីចឹងឮតែម្នាក់ឯងទេ អ្នកផ្សេងទៀតអត់ឮទេ ។ ម្តងទៀត ថាអ៊ំបានធ្វើដំណើរចេញទៅហ្នឹង ទៅដល់ព្រៃស ហើយដែលអ៊ំធ្វើដំណើរបន្តទៀត អ៊ំធ្វើដំណើរហ្នឹងទៅដល់ណា? ហើយថ្ងៃណា? ដូចជាថ្ងៃទី០៨ ទី០៩ ឬក៏ទី១០ នោះ បានអ៊ំត្រលប់ក្រោយវិញ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺថា ខ្ញុំចេញពីអាគុកព្រៃសហ្នឹងនៅពេលយប់ ប្រហែលជាម៉ោងប្រាំពីរ ប្រាំបី ប្រាំបួនយប់ ដប់យប់ ណ៎ ។ ទៅទាំងយប់ ដើរទាំងយប់ ដើរកាត់ទៅរហូតដល់ផ្លូវជាតិលេខ៤ ឆ្លងកាត់ ព្រលឹមឡើងស្រាប់ឮរថក្រោះ ពួកវៀតណាម ពួកខ្មែរយើង ខ្មែររណសិរ្សហ្នឹងមកក៏ពួកហ្នឹង អង្គរក្សការពារអ្នកទោសគុកទួលស្លែង ដែលនាំខ្ញុំធ្វើដំណើរហ្នឹងរត់រប៉ាត់រប៉ាយបាត់អស់ហើយ ។ ខ្ញុំក៏ចេះតែចូលតាមគេរហូតទៅពីនាក់ ផា ថនចាន់ ហ្នឹងរហូត ជាប់រហូត ក្រៅពីហ្នឹងរត់បាត់អស់ហើយ មិនដឹងទៅណាបាត់អស់ វ៉ាន់ ណាត ក៏ដោយ វ៉ាន់ ណាត ពីណាក៏ដោយនេះ ។ បែកចែកគ្នាអស់ហើយ នៅសល់តែខ្ញុំជាប់ខ្ញុំពីនាក់ ផា ថនចាន់ ។ ដើរទៅរហូតដល់អមលាំង ទៅសម្ងំនៅសហករណ៍ព្រៃជ្រៅ ។ (ឮមិនច្បាស់) ផា ថនចាន់ គាត់និយាយ-- អីបន្តិច ខ្ញុំក៏មិនទុកចិត្តគាត់ទៅសុំអារបបពីសហករណ៍ទេ ខ្លាចគេយកបាញ់សម្លាប់គាត់ចោល ។ គាត់ឈាន ខ្ញុំនៅហ្នឹងមុខគាត់រហូតសុំអំណោយរបបហូបតាមផ្លូវរហូត មិនឲ្យគាត់មានគ្រោះថ្នាក់ តែគ្រោះថ្នាក់គាត់ គ្រោះថ្នាក់ដល់ខ្ញុំ ។ អ៊ីចឹង ខ្ញុំត្រូវចេញមុខទទួលខុសត្រូវ ។

[១១:៣៣:៣៥]

**ស៖** ហើយៗដល់ថ្ងៃណា បានអ៊ំត្រលប់មកវិញ ត្រលប់មកថយក្រោយវិញ?

**ឆ៖** ជម្រាបប្រសាសន៍ ពេលនោះគឺ វ៉ាន់ ណាត មកដល់ភ្នំពេញមុនខ្ញុំ ។ ពួកវ៉ាន់ ណាត ពួកប្រធាន អ៊ឹង ប៊ុច ហ្នឹង ហើយនិង រុយ នៀគង់ អីហ្នឹង មកដល់ភ្នំពេញមុនខ្ញុំ ។ តែខ្ញុំចេះតែធ្វើដំណើរតាមពួកគេរហូតទៅដល់ខេត្តពោធិសាត់ ។ ពេលនុំង វៀតណាមរុករាតល្បាតពេញក្នុងព្រៃជួបខ្ញុំ ផា ថនចាន់ ក៏នាំមកនៅស្វាយដូនកែវ ។ អង្គភាពទ័ពវៀតណាមនៅប្រចាំការនុំង កងទ័ពពិសេសគេនោះកងពលគេនោះនៅឈរចាំនៅស្វាយដូនកែវ ស្រុកស្វាយដូនកែវហ្នឹង ។ ហើយឲ្យខ្ញុំបម្រើការងារបដិវត្តអ៎!ច្រឡំ ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា កាលនុំងគេឲ្យខ្ញុំនៅធ្វើការនៅខេត្តពោធិសាត់ ជំនាញការខាងវាយអង្គុលីលេខពីពេលនោះ ខ្ញុំនៅការនៅសាលាខេត្តពោធិសាត់ ជាមួយចៅហ្វាយខេត្ត រស់ស្រេង, កង ប៉ាង ជាប្រធានមន្ទីរ ជាខុទ្ទកាល័យខេត្ត កង ប៉ាង ។

**ស៖** ឥឡូវហ្នឹង និយាយពីរឿងប្រពន្ធអ៊ំវិញ ។ អំមិញអ៊ំបាននិយាយរឿងខ្លួនឯងរួចហើយ ហើយដោយសារអ៊ំប្ដឹងហ្នឹង មានទាំងពីរ បានន័យថា អ៊ំប្ដឹងអំពីអ៊ំដែលត្រូវទទួលរងនូវទារុណកម្ម ដោយអយុត្តិធម៌ និងអមនុស្សធម៌មកលើអ៊ំ នៅក្នុងអំឡុងពេលនៃការចាប់ខ្លួន និងឃុំឃាំងនៅទីនោះ ។

ឥឡូវនិយាយពីរឿងប្រពន្ធអ៊ំវិញ ។ ចាប់តាំងពីពេលដែលចាប់បញ្ជូលទៅដល់ក្នុងមន្ទីរសន្តិសុខ

ស-២១ ហើយថតរូប និងសួរប្រវត្តិរូបរួចហើយ ដាក់ខ្នោះ និងរុំមុខបញ្ជូនទៅមន្ទីរឃុំឃាំង ។ តើចាប់ពីពេលនោះមកអ៊ំ ដែលបានដឹងឮ ឬទទួលព័ត៌មានពីប្រពន្ធរបស់អ៊ំទៀតដែរឬទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ពីពេលដែលចងមុខ ហើយយកទៅដាក់ក្នុងបន្ទប់រួមនៅខាងលើហ្នឹង បន្ទប់រួមហ្នឹង ។ តាំងពីហ្នឹង ខ្ញុំបែកប្រពន្ធខ្ញុំរហូតមកទល់មកថ្ងៃហ្នឹង មិនដែលឃើញមុខប្រពន្ធយ៉ាងម៉េច មិនដែលដឹងដំណឹងយ៉ាងម៉េចទេ ។ ដឹងដំណឹងដែរ ពីថ្ងៃហ្នឹងខ្ញុំកំពុងគូររូប ប៉ុល ពត, ហ៊ឹម ហ៊ុយ គេច្រត់ច្រៀងនៅបង្អួចក្បែរខ្ញុំគូរហ្នឹង គេថាណាំប្រពន្ធអ្អែងឲ្យធ្វើស្រែហើយ ។ ខ្ញុំនឹកថា ម៉េចចេះ គេមកប្រាប់ដំណឹងអ៊ីចឹង តិចគេយកទៅវៃចោលទៅ ហ្នឹងនឹកក្នុងចិត្តទេ មិនឲ្យគេឮទេ និយាយហ្នឹង ។ សួរខ្លួនឯង ខ្សឹបក្នុងពោះខ្លួនឯង ប្រហែលជាយកទៅវៃចោល នឹកឃើញអ៊ីចឹង ។ ធម្មតាធ្វើស្រែ ដូចខ្ញុំអ៊ីចឹង កាលហ្នឹង ឌុច គាត់និយាយដែរគាត់ថា នែ៎តែគូរមិនដូច ធ្វើជីស្រែណ៎ា អាធ្វើជីស្រែមួយម៉ាត់ហ្នឹង ខ្ញុំដូចអំពើការមានអារម្មណ៍ក្តុកក្តួលភ័យដែរ អូ៎!ខំគូរណាស់ ខំម៉្វៃបានតែសសៃសក់មួយក៏ខ្ញុំគូរដែរ ។ អ៊ីចឹង ហើយបានខ្ញុំសូមពន្យារពេលបីខែក្នុងមួយផ្ទាំង ។

[១១:៣៧:០៨]

**ស៖** តើអ៊ំដឹងអំពីជោគវាសនានៃប្រពន្ធ របស់អ៊ំហ្នឹងថាគាត់យ៉ាងម៉េចដែរ?

**ឆ៖** បាទ, សូមជម្រាបលោកប្រធាន! គឺថា ជោគវាសនាប្រពន្ធខ្ញុំ មិនដឹងជាយ៉ាងណាទេ មិនដឹងគេធ្វើទារុណកម្ម រូបភាពបែបណាទេ ។ ខ្ញុំបែកមុខគ្នារហូតចាប់ពីថ្ងៃដែលខ្ញុំចូលទៅបន្ទប់រួមហ្នឹងវិញកន្លែងឃុំឃាំងបន្ទប់រួមហ្នឹង បែកគ្នារហូតទាល់ឥឡូវ មិនដែលបានដឹងដំណឹងពីគ្នាយ៉ាងម៉េចទេ ។

**ស៖** យើងគិតមើល ថាតើគាត់ស្លាប់ ឬក៏ត្រូវគេសម្លាប់នៅក្នុងមន្ទីរសន្តិសុខស-២១ ឬយ៉ាងម៉េច?

**ឆ៖** សំណួររបស់លោកប្រធាន គឺធ្វើឲ្យខ្ញុំនឹកឃើញឡើងវិញ ចង់សួរទៅលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹងផង ។ តើគាត់ឲ្យកូនចៅគាត់កម្ទេច ពាក្យថាកម្ទេចសម្លាប់ហ្នឹង គឺសម្លាប់នៅក្នុងមន្ទីរ ស-២១ ក៏នៅជើងឯក ឬក៏នៅកន្លែងណា ដើម្បីខ្ញុំយកព្រះធរណីនោះ មកបណ្តុះខទ្ទិសដ្ឋានអុចរំឭកនឹកគុណ ធ្វើបុណ្យបញ្ជូនទៅគាត់ ។ ហ្នឹងគ្រាន់តែចង់ដឹង ចង់សួរតែប៉ុណ្ណឹងទេ ។

**ស៖** អ៊ីចឹង អ៊ំអត់ឆ្លើយនឹងសំណួរ ខ្ញុំទេ ហើយខ្ញុំទុកសំណួរនេះសួរទៅជនជាប់ចោទវិញ អ៊ីចឹងមែនទេ? អ៊ំអំមិញថា អ៊ំមានរូបថត ប្រពន្ធរបស់អ៊ំ ដែលមានឈ្មោះថា ឈ្មោះ យឿន ហៅ មិត្តធី អ៊ីចឹងទេ? អ៊ំនាំយករូបថតហ្នឹងមកជាមួយទេ? ហើយរូបថតនោះថតនៅពេលណា?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! រូបថតខ្ញុំយកមកជាមួយ នៅជាប់នឹងខ្លួន ចង់ខ្ញុំសូមអនុញ្ញាត សូមការបង្ហាញ ។

**ស៖** រូបថតហ្នឹងថតនៅពេលណា នៅក្នុងអំឡុងពេលដែលគេថត ពេលដែលចូលចាប់ខ្លួន ហើយបញ្ជូនចូលទៅក្នុងគុក មន្ទីរស-២១ ឬក៏ហៅថា គុកទួលស្លែង នោះ ឬក៏រូបថតដែលអ៊ំថត ជាមួយគាត់តាំងពីអនុស្សាវរីយ៍ពីការថ្មីថ្មោងមក?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! រូបនេះ គឺពិតជានៅអំឡុងពេលដែលខ្ញុំថតជាមួយគ្នា ជាមួយខ្ញុំថតមុន គាត់ថតក្រោយ ។ នេះអត្តលេខគាត់នៅទីនេះស្រាប់ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដាក់ យករូបថតពីអ៊ំ ម៉េង ហើយដាក់បញ្ចាំងនៅលើអេក្រង់ទូរទស្សន៍ ។

**សួរបន្តដោយប្រធានអង្គជំនុំ៖**

អ៊ំប្រពន្ធអ៊ំហ្នឹងឈ្មោះ យឿន ហៅ មិត្ត ធី ត្រកូលគាត់ឈ្មោះអីទៅអ៊ំ ត្រកូលប្រពន្ធរបស់អ៊ំ? ហើយកាលណោះគាត់មានអាយុប៉ុន្មានឆ្នាំដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន ! គឺថាគាត់ឈ្មោះ ត្រកូលគាត់ឈ្មោះ ម៉ា យឿន ហៅ សមមិត្តធី ។

[១១:៤២:00]

**ស៖** កាលពីថតរូបហ្នឹង បានន័យថា កាលពីអំឡុងពេលដែលគេចាប់ខ្លួនចូល គាត់ទៅដល់មន្ទីរសន្តិសុខស-២១ហ្នឹង គាត់កាលណោះគាត់អាយុប៉ុន្មាន? នៅអំឡុងពេលដែលគាត់ថតរូបនេះ គាត់មានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកប្រធាន! កាលណោះប្រហែលជារវាងប្រហែលជា ២៥ ចំពោះខ្ញុំកាលណោះអាយុម្ភៃ-- សាមជាងហើយកាលណោះ ។ ប្រហែល២៥ ខ្ញុំអាយុប្រហែលខ្ទង់៣៦, ៣៧ ។ ខ្ញុំបងគាត់៩ឆ្នាំ ។

**ស៖** (មន្ត្រីតុលាការដកយករូបនេះចេញវិញ) ។

ឥឡូវនេះ រឿងផ្ទាល់ខ្លួនអ៊ំ ហើយនិងគ្រួសារអ៊ំ យើងបានសួរចប់សព្វគ្រប់ហើយ ។ ឥឡូវហ្នឹងសំណួរបន្ទាប់ទៀតថា នៅក្នុងអំឡុងពេលដែលអ៊ំបានទៅជាប់ឃុំឃាំង ហើយក្រោយមកអ៊ំបានត្រូវបានជ្រើសរើសជាជាងគូរគំនូរ រហូតដល់ថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ ។ តើអ៊ំបានឃើញ ដឹង នូវទិដ្ឋភាពនៃ

ការប្រព្រឹត្តរបស់បុគ្គលិកមន្ទីរស-២១ ចំពោះអ្នកទោសដទៃទៀតយ៉ាងម៉េចខ្លះដែរ? បើអ៊ំអាចចងចាំ អាចសូមអ៊ំរៀបរាប់ប្រាប់ពីហេតុការណ៍នានា ដែលអ៊ំបានឃើញដល់អង្គសវនាការបានដឹង អំពីបញ្ហានោះ ។ សូមអញ្ជើញអ៊ំ ។

**ឆ៖** សូមរៀបរាប់ថា ការដែលខ្ញុំគួរនៅមន្ទីរអគារ “E” ហ្នឹង កន្លែងគូររូបថត ប៉ុល ពតហ្នឹង ខ្ញុំក្រឡេកមើលតាមចន្លោះបង្អួច ឃើញបញ្ជូនកងទ័ពវៀតណាមមកទាំងខ្សែៗ ចូលអគារ “A” ។ ហើយនិងកងទ័ពរំដោះ (អ៎!ច្រឡំ) កងទ័ពខ្មែរក្រហមហ្នឹង ទាំងខ្សែៗចូលមក ។ អាហ្នឹងខ្ញុំមិនបានឃើញគេធ្វើទារុណកម្មចំពោះមុខខ្ញុំផ្ទាល់ទេ ប៉ុន្តែឮតែសម្រែក “លោកអើយជួយផង! ការវ៉ៃដំច្រំធាក់” ជុំវិញហ្នឹង ជុំវិញអគារគុកទួលស្លែងហ្នឹង ។ មិនបានឃើញទេ តែឮគេស្រែកសម្រែកយំ ស្រែកហៅម៉ែជួយផង ខ្ញុំងាប់ហើយ ឮសូរតែអ៊ីចឹង ។

**ស៖** ចុះទិដ្ឋភាពដទៃទៀត ដូចជាអំឡុងពេលដែលអ៊ំជាប់ឃុំឃាំងនៅក្នុងបន្ទប់រួម តើអ៊ំដែលបានឃើញមនុស្សស្លាប់នៅក្នុងអំឡុងពេលនៃការជាប់ខ្នោះជើងហ្នឹងដែរទេ នៅក្នុងបន្ទប់អ៊ំនោះ? ហើយបើឃើញឃើញញឹកញាប់ដែរទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំបានឃើញអ៊ីចឹងមែន ដេកទល់ក្បាល់ខ្ញុំអ៊ីចេះ ។ គាត់ នោះខ្មៅ រាងខ្មៅ រាងមាឌមិនជាខ្ពស់ធំណាស់ណាទេ រាងល្អិតមាឌល្អិត គេហៅមាឌល្អិត រាងខ្ពស់ជាងខ្ញុំ គេហៅមាឌធុនកណ្តាលខ្មៅ ហើយអាយុប្រហែលជារវាងប្រហែលជាប៉ុនខ្ញុំរាល់ថ្ងៃហ្នឹង ៦៧-៦៨ឆ្នាំ។ គឺថាក្មេងម្នាក់ហ្នឹងអាយុប្រហែលដប់ប្រាំ ប្រាំដប់មួយ ឡើងទន្ទ្រាំលើទ្រូងគាត់ ។ ដល់ប៉ុន្មានថ្ងៃឃើញ ក្អកធ្លាក់ឈាម ហើយឃើញស្លាប់នៅហ្នឹង ។ ស្លាប់នៅក្បាលដំណេកខ្ញុំដេកហ្នឹង បញ្ជិតបន្តិចទេមិនចំក្បាលដំណេកទេរាងបញ្ជិតបន្តិច ងាប់នៅគុកហ្នឹងបន្ទប់រួមហ្នឹង ដល់យប់បានជាគេយកទៅកប់តែមិនដឹងជាយកទៅកប់នៅឯណាទេ កប់មិនឆ្ងាយពីហ្នឹងទេនៅទួលស្លែងហ្នឹង ម្នាក់ហ្នឹង ។

**ស៖** ពីពេលដែលគាត់ស្លាប់ មានមនុស្សស្លាប់អ៊ីចឹងទៅរហូតដល់ពេលគេទៅយកសពហ្នឹងដើម្បីដោះចេញពីខ្នោះ ហើយយកចេញក្រៅយកទៅកប់ ឬក៏យកទៅដុតហ្នឹង ឃ្លាតប្រហែលជាប៉ុន្មានម៉ោងទៅ?

**ឆ៖** ប្រហែលជាខ្ទង់ មើលខ្ញុំឃើញតាំងពីថ្ងៃម៉ោង៦ ម៉ោង៧ អ្ហេ! ដល់យប់ ប្រហែល អ្ហេមិនដឹងទេអង្កាល់នោះខ្ញុំភ្លេចហើយ ។ ប៉ុនតែបាត់ បាត់ពីកន្លែងហ្នឹង ក្រែងគេយកទៅកប់មិនដឹងកប់ឯណាមិនដឹងយកទៅធ្វើរណា អត់បានដឹង ពីព្រោះវាកាលនោះខ្ញុំដេកនៅក្នុងខ្នោះមិនដឹងវាធ្វើរណា ។

**ស៖** ហើយអ៊ំបានកត់សម្គាល់ឃើញទេ នៅក្នុងអំឡុងពេលជាប់ឃុំឃាំងជាមួយគ្នា ព្រោះអ៊ំជាប់រយៈពេលច្រើន អ៊ំជាប់ខ្នោះជាប់ឃុំឃាំងហ្នឹងអំឡុងរយៈពេលច្រើនណាស់មុននឹងគេបញ្ចេញអ៊ំមកធ្វើជាជាងគំនូរនោះ ។ សំណួរសួរថាតើអ៊ំបានកត់សម្គាល់ឃើញថា មនុស្សដែលគេចាប់បញ្ជូនចូលទៅក្នុងដាក់ខ្នោះក្នុងបន្ទប់ឃុំឃាំងជាមួយអ៊ំហ្នឹងបញ្ចេញទៅក្រៅជាញឹកញាប់ហើយបញ្ចេញទៅមិនដែលឃើញត្រលប់មកវិញទេ? ឬក៏មិនមានទេ បានន័យថា បញ្ជូនទៅសួរចម្លើយហើយឃើញបញ្ជូនត្រលប់មកវិញ?

[១១:៤៧:៣០]

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំនិយាយតាមពុទ្ធំ ធម៌ គឺខ្ញុំនិយាយតាមការពិត គឺបញ្ជូនទៅឡាន ឃើញដឹកចេញទៅ មិនដែលឃើញត្រលប់មកវិញឃើញមនុស្ស ។ ហើយម្យ៉ាងទៀត ខ្ញុំរើសួរចម្លើយហើយគេទុកនៅក្រោម ម្យ៉ាងខ្ញុំមិនសូវដឹងផង នៅបន្ទប់ក្រោមមិនដឹងទេ ។ ប៉ុន្តែក្នុងអំឡុងពេលដែលខ្ញុំសម្រាកនៅកន្លែងបន្ទប់រួមនោះមិនដែលឃើញមកវិញ អ្នកដដែលៗមនុស្សដដែល ដែលធ្លាប់នៅក្បែរគ្នានោះអត់ឃើញ ស្រាប់បាត់ឈឹង ។

**ស៖** ចុះទិដ្ឋភាពផ្សេងទៀតដូចជាមានទិដ្ឋភាព ដូចការសែងមនុស្ស មនុស្សនោះវាដើរអត់រួចបានន័យថាស្គមពេក ដើរមិនរួច ហើយមានការសែងយកមកដាក់រថយន្ត ឬក៏សែងពីកន្លែងឃុំឃាំងយកទៅសួរចម្លើយអីអ៊ីចឹង តើអ៊ំមានឃើញទិដ្ឋភាពហ្នឹងដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍! ខ្ញុំបានឃើញរូបហ្នឹងពិតមែន ។ ឃើញមនុស្សហ្នឹងស្គមដៃជើងវែងៗ ហើយឃើញចង ចងដៃរួមគ្នាអ៊ីចឹង ហើយជើងរួមគ្នាអ៊ីចឹង ហើយស៊កឈើសែងតាមប្រឡោះដៃហ្នឹងតាមប្រឡោះជើងហ្នឹង សែងដូចជ្រូកអ៊ីចឹង ។ ជើងទាំងពីរ ដៃទាំងពីរឡើងលើអ៊ីចឹង ឃើញកាត់តាមក្បែរអគារខ្ញុំគូររូបថត ប៉ុល ពត ហ្នឹង គូររូប ប៉ុល ពត ហ្នឹង ខ្ញុំបង្ហើបមើល ។ ស្រាប់អាមួយនោះមកដល់ ខ្ទប់សួរផាំង អត់ឲ្យខ្ញុំមើលខ្ទប់បិទជិតឈឹងអស់លែងមើលឃើញអីហើយ ឃើញមួយភ្លែតហ្នឹងឃើញសែងដូចជ្រូក ស្គមមែនទែនដើរមិនរួចទេ មិនដឹងមកពីអគារមួយណាទេ ខ្ញុំអត់ដឹង។

**ស៖** ហើយគេសែងហ្នឹង សែងខ្មោចទេ ឬក៏សែងមនុស្សរស់ អាចងដៃចងជើងអ៊ីចឹង?

**ឆ៖** សូមជម្រាបប្រសាសន៍! អាហ្នឹងមិនមែនខ្មោចគឺមនុស្សរស់នៅដកដង្ហើមតឹកៗ ពោះស្វិតគ្រហែតៗ ដើរកាត់តាមហ្នឹង ចាំទៅដល់មុខឡានទម្លាក់លើឡានព្រូសទៅ ។ ឡាននៅចាំមុខគុកហ្នឹង ។ ឡានចេញ ហើយឡានចូលឮសូរឲ្យសន្ធឹកហ្នឹងមួយយប់ៗទល់ៗភ្លឺ ។

**ស៖** អ៊ំនៅចំណុចហ្នឹងដូចជាច្បាស់ដែរ ហើយយើងចង់ដឹងថា ការដែលរថយន្តដឹកអ្នកទោសចេញទៅក្រៅ ហើយអ៊ំនិយាយថាមួយយប់ៗទល់ៗភ្លឺ ។ ប៉ុន្តែ ការដឹកជាទូទៅហ្នឹង ដឹកទាំងថ្ងៃទាំងយប់ ឬក៏ដល់ពេលយប់ហើយបានមានឡានហ្នឹងដឹកអ្នកទោសចេញពីស-២១ ឬក៏គេអត់មានកំណត់ពេលទេ? ពេលណាក៏មានការដឹកអ្នកទោសចេញពីមន្ទីរស-២១ ដែរ ហើយមិនឃើញត្រលប់មកវិញទេ គឺមានតែដឹកចេញ ។

**ឆ៖** បាទ ជម្រាបប្រសាសន៍លោកប្រធាន កាលនោះ ខ្ញុំនៅក្នុងគុកដេកនៅលើបន្ទប់រួមនោះ និងក្នុងបន្ទប់ដោយឡែកគេវៃស្លរចម្លើយហើយ ក៏ឮសូរតែស្នូរឡានចេញនិងឡានចូលមិនបានឃើញផ្ទាល់ភ្នែកទេឡាននោះ គ្រាន់តែឮសូរសន្ធឹកឡានចេញ ឡានចូល ។ ប៉ុន្តែ ចំណែកមនុស្សអ្នកទោសក៏ខ្ញុំមិនដែលឃើញយ៉ាងម៉េចដែរ ។ ឃើញហ្នឹង ឃើញដោយក្នុងពេលដែលខ្ញុំគូររូប ប៉ុល ពត នោះទេ ដែលលួចមើលឃើញសែងដូចជ្រូកគឺឃើញអ៊ីចឹងមែន។ យកទៅបោះលើឡានប្លួសទៅ អាឡាននៅឈប់មុខគុកនុំង ។

[១១:៥១:៣៣]

**ស៖** ប៉ុន្តែពេលនោះ ពេលយប់ ឬពេលថ្ងៃ? ពីព្រោះអ៊ីចេះ បញ្ហាយើងគិតមើល បញ្ហាព័ត៌មានដែលយើងធ្វើការសវនាការច្រើនហើយ វាមានបញ្ហាពីរដែលយើងទទួលព័ត៌មាន ទីមួយ គឺការជាទូទៅក្នុងការដឹកមនុស្សចេញទៅ គឺនៅពេលយប់ គឺបានន័យថាទៅដល់កន្លែងជើងឯក ប្រតិបត្តិការក្នុងការសម្លាប់នៅពេលយប់ ។ នេះគឺព័ត៌មានដែលអង្គជំនុំជម្រះបានក្តាប់បាននៅក្នុងសំណុំរឿងក្នុងការដេញដោលកន្លងមក ។ នេះបញ្ហាមួយ ។ បញ្ហាទីពីរ គឺមានចម្លើយមួយអាចច្រឡំអ៊ំ ឬក៏អ៊ំពីរនាក់មុន ខ្ញុំមិនចាំគឺនៅក្នុងអំឡុងពេលដែលគាត់ផ្តល់សក្ខីកម្ម គាត់បានឆ្លើយអ៊ីចេះថា ពេលដែលរស់នៅក្នុងទីនោះ គឺការរស់របស់គាត់ហ្នឹង ពេលព្រឹកឡើងរហូតដល់ម៉ោងដប់ពីរយប់ ។ ការដល់ផុតដល់ម៉ោងដប់ពីរ ហើយគាត់សង្ឃឹមថា អាចរស់មួយថ្ងៃទៀត ។ បានសេចក្តីថា ការបញ្ចេញមនុស្សដើម្បីយកទៅសម្លាប់ហ្នឹងគឺពីម៉ោងដប់ពីរយប់ ទៅទល់ភ្លឺហ្នឹងកម្រមានណាស់ ។ បានន័យថា មានៗពេលព្រលប់ៗទេ ដែលគេដកមនុស្សចេញយកទៅសម្លាប់ ។ អ៊ីចឹងរបត់ពីរហ្នឹង ដែលយើងចង់បញ្ជាក់ចំណុចនេះឲ្យច្បាស់ថា តើអ៊ំបានទទួលព័ត៌មាន ឬក៏ដឹងថា ពេលដែលគេសែងមនុស្ស អំមិញនេះដែលឈើខ្លាំងដើរមិនរួចធ្វើដូចជ្រូកយកទៅដាក់ឡានហ្នឹង នៅពេលយប់ ឬក៏នៅពេលថ្ងៃ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកប្រធាន ពេលហ្នឹងគឺយប់ខ្ញុំមិនបានឃើញទេ គឺពេលថ្ងៃ ខ្ញុំ នៅគូររូបថតប៉ុលពត ហ្នឹងពេលថ្ងៃប្រហែលជាម៉ោងប្រាំបី-ប្រាំបួន ម៉ោងដប់ប៉ុណ្ណឹង ដែលខ្ញុំឃើញ ហ្នឹង រវាង ប្រហែលជាម៉ោងប្រាំបួន បើមិនម៉ោងប្រាំបួន ម៉ោងដប់ ។

**ស៖** តាមធម្មតារថយន្តដែលចូលមកដឹកមនុស្ស ដឹកអ្នកទោសចេញទៅហ្នឹង គេមកដល់អគារ មុខអគារតែម្តង ឬក៏គេឈប់នៅផ្លូវខាងក្រៅ ខាងកើតកន្លែងអគារ “E” ឯនេះ ខាងកើតផ្លូវខាងកើត ស-២១ ឬក៏គេចូលទៅដាក់នៅជិតហ្នឹងកន្លែងអគារ “B” ឬក៏ “C” អគារគ ឬក៏ “ក”, “ខ”, “គ” នេះ?

**ឆ៖** បាទ, សូមជម្រាបប្រសាសន៍លោកប្រធាន! គឺរឿងឡានដឹកអ្នកទោសចេញហ្នឹង ដែលខ្ញុំ ឃើញសែងដូចជ្រូកនៅពេលថ្ងៃ ប៉ុន្តែឡានចតហ្នឹង គឺចតនៅខាងក្រៅ អាផ្លូវខាងក្រៅក្លោងទ្វារនុ៎ង អត់ មាននៅក្នុងបរិវេណទេ ឡានអត់ចូលក្នុងបរិវេណទេ នៅតែខាងក្រៅហ្នឹង ។

**ស៖** ក្រៅពីនេះអ៊ំមានបានកត់សម្គាល់នូវទិដ្ឋភាព ឯណាផ្សេងទៀតទេនៃបុគ្គលិកមន្ទីរស-២១ ប្រព្រឹត្តទៅលើអ្នកទោសផ្សេងទៀត?

[១១:៥៤:៥០]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ដែលខ្ញុំគូរនៅទួលស្លែងហ្នឹង ពេលគូរឃើញគេបណ្តើរ អ្នកទោសស្រីៗហ្នឹង មនុស្សពោះធើមអីៗ ឃើញដើរជ្រិតជ្រោមទាត់គ្នា ស្រីៗដូចគ្នា គ្នាវាហ្នឹង អង្គរក្ស ស្រីៗហ្នឹង ឆ្មាំការពារហ្នឹង យកជើងទាត់គ្នាធាក់គ្នាឲ្យដើរឲ្យលឿនដើរកាត់តាមមុខអគារពី “B” ទៅ កាត់តាម-- ពីជើងទៅត្បូងនិយាយឲ្យខ្លីទៅពីអគារ“A” ទៅអគារ“D” ក៏ប៉ុន្តែ មិនដឹងគេដាក់កន្លែងណាៗ គ្រាន់តែឆ្លងកាត់គេវៀងទៅឯណា ក៏មិនដឹងទេ។

**ស៖** សំណួរចុងក្រោយ អ៊ំនៅពេលដែលមុនអ៊ំចេញជាមួយនឹងអ៊ំ ណាត ឬក៏អ្នករស់រានមាន ជីវិតផ្សេងទៀតហ្នឹង ចេញពីមន្ទីរសន្តិសុខស-២១ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ តើអ៊ំបានកត់សម្គាល់ ឃើញថា នៅក្នុងអគារនៃមន្ទីរសន្តិសុខស-២១ មានសេសសល់មនុស្សនៅទីនោះដែរ ឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍អស់លោកប្រធាន! ពីព្រោះថាអានេះ ជាសេរីភាពអ្នកជាប់គុក គេ មិនដែលឲ្យយើងដើរដឹងកន្លុកកន្លៀតទេ ។ ថាឲ្យឃើញ ខ្ញុំមិនឃើញទេ មិនដឹងជាមនុស្ស ឬក៏អត់មនុស្ស ពីព្រោះវិន័យគេតឹងណាស់ សូម្បីតែណែនៗពេញអគារហ្នឹងក៏មិនដែលឮសូរមួយអីសដែរស្ងាត់ឲ្យឈឹង។

**ស៖** សំណួរសួរអ៊ីចេះទេ អ៊ំថ្ងៃចុងក្រោយ ពីព្រោះថ្ងៃចុងក្រោយហ្នឹង វាមានក្រោយមកទៀត បានបន្សល់ទុកនូវខ្មោចដែលស្លាប់លើគ្រែរហូតដល់ដប់បួននាក់ ។ ហើយសាក្សីខ្លះថាដប់នាក់ ហើយជន

ជាប់ចោទបាននិយាយថា បួននាក់ គឺពួកយ-៨ គឺបួននាក់ ។ ហើយក្នុងហ្នឹង គឺអ្នកដែលរស់រានមានជីវិតដូចអ៊ំដែរ គាត់បានសង្កេតកត់សម្គាល់ឃើញមានឮស្នូរសំឡេងហើយនិងមានឃើញកម្រើកជាស្រមោលជាក្បាលអ៊ីចឹងមើលពីចម្ងាយទៅថាមានសល់ឃើញមនុស្សមុននឹងចាកចេញទៅអ៊ីចឹងទេ ។

អ៊ីចឹង សំណួរសួរថានៅពេលអ៊ំចេញទៅហ្នឹង តើវាមាន អាចទិដ្ឋភាពណាមួយដែលអ៊ំទទួលព័ត៌មានមកថា មានមនុស្ស ឬក៏គ្មាន? សំណួរសួរតែប៉ុណ្ណឹងទេ គឺនៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ មុនពេលអ៊ំចាកចេញពីមន្ទីរសន្តិសុខស-២១ តើមានការកត់សម្គាល់ថា មានមនុស្សរស់នៅដែរឬទេ? ឬក៏អត់មានទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ពីពេលដែលថា ខ្ញុំចេញពីគុកទួលស្លែងចុងក្រោយហ្នឹងថ្ងៃទី៧ មករា ហ្នឹង ពេលប្រហែលជាម៉ោងប្រាំបួនព្រឹក ទេភ្លេចហើយ ក៏ឮស្នូរអាវុធផ្ទុះក្នុងក្លាំងពេញហ្នឹងក៏គេបញ្ជាឲ្យខ្ញុំចេញ ឈប់គូរទៅចេញ ។ ពេលនោះ គឺខ្ញុំមិនបានឃើញ មិនបានឃើញ ហើយក៏មិនបានឮសំឡេងអីដែរ ហើយខ្ញុំក៏ភ័យពេក វាមិនបានចាប់អារម្មណ៍ ។ ដល់អ៊ីចឹងមិនដឹងជាខ្ញុំគេយកទៅសម្លាប់ឬក៏មួយយ៉ាងម៉េច? បើថា អ្អែង! បើប៊ានចេញពីផ្លូវបាញ់បំបាក់ជើង។ នែ៎! វាខ្លាចត្រង់ហ្នឹងដល់អ៊ីចឹងអត់ប៊ានចាប់អារម្មណ៍ថា អូ! នៅកន្លែងណា? មានអគារណាមាននៅមនុស្ស អីអត់ដឹង ។ ចំណែកគេអ្នកដឹងអាហ្នឹងរឿងគេ គេឃើញ គឺខ្ញុំមិនដឹង ខ្ញុំឆ្លើយតាមត្រង់អ៊ីចឹងហ្នង មិនដឹងទេ ។

**ស៖** អរគុណអ៊ំ បាននិយាយយ៉ាងល្អនិងផ្តល់ព័ត៌មានតាមការសួរ ក៏ដូចជាការរៀបរាប់ផ្ទាល់របស់អ៊ំ ហើយឥឡូវនេះ ដល់ពេលម៉ោងត្រូវសម្រាកពិសារអាហារថ្ងៃត្រង់ហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសារអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះនឹងលើកទៅបន្តនៅរសៀលនេះ ចាប់ពីម៉ោងមួយសាមសិបនាទី។ មន្ត្រីតុលាការសម្របសម្រួលអ្នករស់រានមានជីវិតអ៊ំ ប៊ូ ម៉េង នេះ ដើម្បីឲ្យគាត់បាន រកកន្លែងទទួលនូវកន្លែងសម្រាកសមរម្យ ហើយឲ្យអញ្ជើញគាត់មកកាន់ទីនេះ នៅម៉ោងមួយកន្លះរសៀលនេះ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់ទីនេះវិញឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីរសៀលនេះ ។

*[សវនាការសម្រាកនៅម៉ោង ១១:៥៩ នាទីដល់ម៉ោង ១៣:៣០ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោល ។

**សួរបន្តដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំម៉េង កាលដែលអ្នកសួរចម្លើយឈប់ធ្វើទារុណកម្មលើខ្លួនអ៊ំ ដោយមូលហេតុមកពីអ៊ំយល់ព្រមឆ្លើយសារភាពដោយកុហកតាមគោលបំណងនៃអ្នកសួរ ឬក៏ដោយសារតែអ៊ំមានភាពជំនាញខាងគូររូប?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! រឿងការវ៉ៃធ្វើទារុណកម្មចំពោះយើងខ្ញុំយ៉ាងអ្អែតផ្អន់ចប់សព្វគ្រប់អស់ហើយ គ្មានចម្លើយ ។ ខ្ញុំនៅតែថ្ងៃណាក៏ឆ្លើយពាក្យដដែលថា មិនដឹង មិនឮ មិនដែលស្គាល់ ហើយក៏មិនដែលដឹងថា អ្នកណាជាមេ អ្នកណាជាអ្នកនាំចូល *សេអ៊ីអា, កាហ្សេបេ* ហ្នឹងដែរ ។ ខ្ញុំឆ្លើយពាក្យដដែលៗ គេចេះតែវ៉ៃរាល់ថ្ងៃ ។ ដល់អស់មិនដឹងជាមានពាក្យចម្លើយសារភាពរបស់ខ្ញុំ គេបណ្ដើរខ្ញុំចូលមកគុកទួលស្លែងវិញ នៅកន្លែងបន្ទប់ខាងក្រៅកន្លែងភ្ញៀវគេទិញសំបុត្រអីហ្នឹង នៅកន្លែងហ្នឹងជិតបង្អួចមួយខាងឆ្វេងដៃផ្លូវចូលទៅក្នុង ។ គេឲ្យខ្ញុំអង្គុយហ្នឹង ហើយគេសរសេរចម្លើយក្លែងក្លាយហ្នឹងឲ្យខ្ញុំសរសេរចុះហត្ថលេខានៅហ្នឹង ។ មិនដឹងជាឯកសារហ្នឹងគេសរសេរម៉េចទេ ខ្ញុំភ្លេចហើយពាក្យសម្ដីដែលគេសរសេរខ្ញុំភ្លេចហើយ វាយូរឆ្នាំហើយ ។ ហើយវាទារុណកម្មហ្នឹងវាធ្ងន់ធ្ងរពេក វាភ្លេចភ្លាំងអស់ហើយស្មារតី ។ ឥឡូវ បើសិនថាពីជំនាន់នោះ បើស្មារតីរបស់ខ្ញុំដូចសព្វថ្ងៃនេះ ខ្ញុំមិនអាចគូររូបបានទេ ។ ហើយខ្ញុំក៏មិនអាចរស់ជីវិតដែរ ពីព្រោះជំនាន់នោះតែកាលណាយើងភរ យើងនិយាយមិនទៀង ភរភូតគេ គេវ៉ៃហើយ គេវ៉ៃចោលហើយ ។ គេថាយើងភរភូតអង្គការ ។

**ស៖** អ៊ំនៅក្នុងអំឡុងពេល គេបានសម្រេចថាយកអ៊ំមកធ្វើ-- ដោះលែង ហើយយកអ៊ំមកធ្វើជាជាងគំនូរគូររូបថ្នាក់ដឹកនាំបងធំទីមួយ ឬក៏ ប៉ុល ពត និងរូបផ្សេងទៀតនៅក្នុងនោះមានទាំងថ្នាក់ដឹកនាំចិនផងដែលអ៊ំបានលើកឡើង តើមានហេតុការណ៍កើតឡើងទេនៅក្នុងអំឡុងពេលដែលអ៊ំគូររូបនោះ? ចំពោះអ៊ំ ឧទាហរណ៍ដូចជាមានការយកអ៊ំទៅឃុំខ្លួនសាជាថ្មីម្ដងទៀតអីចឹង មានដែរទេ?

[១៣:៣៤:៣២]

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកប្រធាន! ដូចជាគ្មានទេ ។ គឺអំឡុងគូរនោះ ធម្មតាៗនៅតែគូរធម្មតាអីចឹងរាល់ថ្ងៃរាល់ខែអីចឹង ទម្រាំតែចប់បួនផ្ទាំងហ្នឹង គំនូរខ្ញុំគូររាល់ថ្ងៃ ។ ហ្នឹងហើយរាល់ពី

ធ្វើទារុណកម្មអស់ហើយហ្នឹង ។

**ស៖** រហូតដល់ពេលនេះ អ៊ំពិចារណាឡើងវិញ ឬក៏គិតឡើងវិញមើលថា តើក្រៅពីអ៊ំដែលបានអះអាងថា ទទួលរងទារុណកម្មធ្ងន់ធ្ងរដែលមានដំបៅរហូតដល់មានស្លាកស្នាមបន្សល់ទុកនៅលើដងខ្លួនរបស់អ៊ំរហូតដល់បច្ចុប្បន្ននេះ តើស្ថានភាពនៃការដែលអ៊ំទទួលរងរបួសស្លាមកន្លែងផ្សេងទៀត ឬក៏ខាងផ្នែកស្មារតីហ្នឹង វាមានលក្ខណៈយ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ផ្នែកខាងស្មារតីខ្ញុំឥឡូវនេះមានការភ្លេចភ្លាំងច្រើន មិនសូវចាំដូចពីដើមទេ ។ ឧទាហរណ៍ថា បើទុករបស់កន្លែងដែលត្រូវចាំហ្នឹង វាភ្លេចកន្លែងទុកហ្នឹងទៅទៀត ការភ្លេចវង្វេងវង្វាន់មុខក្រោយ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រី ចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់អ៊ំ ប៊ូ ម៉េង ដែរឬទេ? សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក ប៊ូ ម៉េង លោកនៅស-២១ ក្នុងរយៈពេលវែងមួយហើយលោកបានរៀបរាប់អំពីភាពឈឺចាប់ហ្នឹង បទពិសោធន៍ដែលបានឆ្លងកាត់នៅទីនោះ ។ សូមអរគុណលោកច្រើន ប៉ុន្តែខ្ញុំមានសំណួរមួយ ឬក៏ពីរតូចប៉ុណ្ណោះដើម្បីសួរលោក ។ ខ្ញុំចង់ដឹងអំពីអ្នកទោសផ្សេងៗទៀតដែលប្រហែលលោកបានឃើញនៅស-២១ ។

លោកបានរៀបរាប់អំពីអ្នកទោសដែលនៅក្នុងបន្ទប់តែមួយត្រូវបានដាក់ខ្នោះនិងឃ្នាងដូចលោកហើយលោកបានឃើញស្ត្រីមានផ្ទៃពោះដែលត្រូវបានគេទាត់ដោយឆ្មាំ ឬអ្នកយាមស្ត្រីដើម្បីឲ្យដើរឲ្យលឿន ថាតើលោកបានឃើញអ្នកទោសបរទេសនៅស-២១ ដែរឬទេក្រៅពីអ្នកទោសវៀតណាមដែលលោកបានរៀបរាប់?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! អ្នកទោសដែលនៅជាប់ជាមួយខ្ញុំ ដែលគេហៅថាបន្ទប់រួមហ្នឹង គឺមានជនបរទេស ជនជាតិអឺរ៉ុបក៏មិនដឹង ជនជាតិអូស្ត្រាលីក៏មិនដឹង ជនជាតិអាមេរិកក៏មិនដឹង ឬក៏ជនជាតិអីផ្សេងទៀតក៏មិនដឹង នៅជាប់ជាមួយខ្ញុំនៅគុករួម បន្ទប់រួម នៅជ្រុងជញ្ជាំង ។ ហើយក៏ហូបចុកអីរបៀបក្រុមខ្ញុំ ដូចគ្នា ។

[១៣:៣៨:២៦]

**ស៖** តើលោកដឹងអ្នកទោសក្រៅពីពួកបស្ចិមប្រទេស និងក្រៅពីវៀតណាមដែរឬទេ ដូចជាអ្នកទោសមកពីប្រទេសថៃជាដើម តើមានដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! គឺមិនដែលឃើញទេជនជាតិថៃ ដែលឃើញតែជនជាតិវៀតណាម និងជនជាតិបរទេសជាអឺរ៉ុបមិនដឹង ជាអាមេរិកក៏មិនដឹង ជាអីសាសន៍អីមិនដឹងទេ ខ្ពស់ហើយភ្នែកស សក់ក៏រាងទ្រង់លឿងៗ ទ្រង់ក្រហមនោះ ។ ក្រៅពីនុំងមិនដែលឃើញទេ ជនជាតិថៃជនជាតិអីទេ ។ យោបល់ខ្ញុំសូមចប់ ។

**ស៖** បន្ថែមទៅលើអ្នកទោសវៀតណាមដែលលោកបានឃើញ តើលោកបានឃើញអ្នកទោសដែលជាប្រជាជនសាមញ្ញ មិនមែនជាអ្នកទោសទាហានវៀតណាមដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ខ្ញុំបានឃើញអ្នកទោសដែលជា មិនមែនជាកងទ័ពដូចខ្ញុំនិយាយខាងដើមអ៊ីចឹង ពីព្រោះគេអួតខ្លួនថា គេចេះសូនរូប ដល់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ឲ្យធ្វើច្របាច់ច្របល់ដីចុះឡើងៗរបៀបដូចថាមិនចេះ ហើយអួតឯងថាចេះ ។ ហើយពេលនោះ អង្គការមិនសប្បាយចិត្តទេ អ្នកភរភូតអ៊ីចឹង ចូលចិត្តតែការត្រង់ ។ ហើយយោបល់ខ្ញុំក៏អត់មានចម្លើយតទៅទៀតទេ សូមបញ្ចប់តែប៉ុណ្ណឹង ។

**ស៖** អ្នកដែលលោកបានឃើញថា ប្រហែលជាអ្នកអឺរ៉ុប ឬក៏ប្រហែលជាជនជាតិវៀតណាម អ្នកទាំងអស់នោះត្រូវបានគេប្រព្រឹត្តដូចគ្នានូវអ្វីដែលដូចគេបានប្រព្រឹត្តលើរូបលោកដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! រឿងអ្នកទោស វាដោយឡែកៗពីគ្នា ចំពោះខ្ញុំធ្វើទារុណកម្មសូម្បីតែអ្នកជាប់គុកជាមួយខ្ញុំហ្នឹងក៏មិនដឹងថាគេធ្វើទារុណកម្មខ្ញុំយ៉ាងម៉េចផង ។ បើខ្ញុំមិននិយាយប្រាប់គេ គេមិនដែលដឹងទេ គឺខ្លួនអ្នកណាគឺអ្នកនុំងដឹង ។ ហ្នឹងខ្ញុំសូមជម្រាបប្រសាសន៍លោកស្រី ។

**ស៖** ថាតើលោកបានឃើញក្មេងៗជាច្រើននៅស-២១ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ចំពោះក្មេងៗនៅ ស-២១ ខ្ញុំមិនដែលឃើញដើរប្រសាក់ប្រាស្រ័យ ឬក៏ជាប់នៅក្នុងហ្នឹងទេ គ្រាន់តែឃើញតាមរូបភាព រូបថត ។ ចំពោះរូបពិត គឺមិនដែលឃើញទេ ។ នេះខ្ញុំឆ្លើយដោយស្មោះត្រង់ គឺឃើញអ្វីថាហ្នឹង ខ្ញុំមិនចេះនិយាយភរភូតពន្លើសឲ្យគេមានទោសមានទុក្ខដោយសារខ្លួនទេ ។ ខ្ញុំត្រង់ណាស់ កើតមកជាតិនេះ ។

[១៣:៤២:០១]

**ស៖** តើលោកធ្លាប់ឮសំឡេងស្រែករបស់កូនក្មេងនៅជុំវិញបរិវេណស-២១ ដែរ ឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រី! ចំពោះសំឡេងក្មេងដូចជាមិនដែលឮ ឮសូរតែសំឡេងមនុស្សចាស់ ស្រែក ម៉ែអើយជួយផងៗ ងាប់ខ្ញុំហើយ ។ ហ្នឹងឮសូរ ហ្នឹងខ្ញុំនៅក្នុងគុករួម ។ ហើយនៅក្នុងគុកមួយប្រឡោះតូចៗដោយឡែកម្នាក់ៗ ម្នាក់ឯង គឺមានឮសូរអ៊ីចឹង ប៉ុន្តែមិនដែលឃើញនឹងភ្នែកទេ ចំពោះក្មេងមិនដែលឃើញសោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណច្រើនលោក ប៊ូ ម៉េង ។ លោកប្រធានខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រមមានសំណួរអ្វីសួរទេ? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សួស្តីលោក ប៊ូ ម៉េង ! ខ្ញុំក៏មានសំណួរបន្តិចតែប៉ុណ្ណោះ ដើម្បីសួរលោកដើម្បីឲ្យលោកបំភ្លឺនូវអ្វីដែលលោកបានរៀបរាប់បន្ថែមឲ្យបានពិស្តារជូនចំពោះអង្គសវនាការនៅថ្ងៃនេះ ។ ខ្ញុំគិតថា ខ្ញុំយល់នូវអ្វីដែលលោកបានរៀបរាប់ ហើយតាមការអាននៅក្នុងចម្លើយរបស់លោកជីវិតរបស់លោកគឺមានការលះបង់ច្រើន ហើយលោកមានការគោរពនិងកោតក្រែងច្រើន ។ លោកបានរៀបរាប់នូវព្រឹកមិញនេះថា លោកបានឆ្លើយតបទៅនឹងការអំពាវនាវរបស់ទ្រង់ សីហនុ នៅក្នុងឆ្នាំ១៩៧០ ក្នុងការរំដោះប្រទេសកម្ពុជា ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ពេលនោះខ្ញុំឮសូរសម្តេចព្រះនរោត្តម សីហនុ លោកផ្សាយតាមប៉ុស្តិ៍មិនដឹងជាប៉ុស្តិ៍អាមេរិកមិនដឹង ប៉ុស្តិ៍អីមិនដឹងទេ ឬបារាំងមិនដឹងទេ ។ ឮសូរនិយាយថា “*កូនចៅចូលព្រៃម៉ាគីដើម្បីតស៊ូ*” ។ អាហ្នឹងខ្ញុំក៏សម្រេចចិត្តថាចូលព្រៃម៉ាគីពីឆ្នាំ១៩៧១ កាលនោះមានមិត្តម្នាក់ឈ្មោះ មិត្តឌុន នៅមន្ទីរ ក-២៥ មកបបួលខ្ញុំឲ្យចូលកងទ័ពដើម្បីគូរគំនូររូបម៉ាកលេនីន គូរជាទង់ កណ្តៀវ ញញួរ អីគេនោះ ទង់បក្សគេនោះ ។ ខ្ញុំនឹងហើយអ្នកធ្វើ ។ ហើយរូបម៉ាក្សលេនីន ខ្ញុំហើយអ្នកគូរ គូរហើយបោះជា*ប៊្លូស្លង់ស៊ីល* ហើយអូសបានច្រើនទៅចែកចាយឲ្យគ្រប់អង្គភាពគេយល់ដឹងអំពីវីរបុរសរបស់ លេនីន អ៎! អាដែងវីរបុរសកុម្មុយនីស្ត មានទាំងអស់មានប្រាំនាក់ ម៉ាក្ស, កាល់ម៉ាក្ស, អង់ហ្គែល, លេនីន, ស្តាលីន, ម៉ៅសេទុង ទាំងអស់មានប្រាំ ។ ខ្ញុំគូរនៅលើកំណាត់ក្រហមក៏មានគូរ ជារូបប្រាំនាក់ហ្នឹងដែរ របៀបដូចទង់អ៊ីចឹង ។

**ស៖** ដូច្នេះលោកបានបំពេញការងារ ក្នុងការឃោសនានៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយលោកបានគោរពទៅតាមការស្នើសុំរបស់គេ ។ ហើយនៅចន្លោះការបញ្ចប់ការចូលរួមក្នុងការឃោសនារបស់លោក ការងាររបស់លោកនៅសាលាបច្ចេកទេសអ្ញូរឬស្ស៊ី ថាតើលោកបានធ្វើការអីផ្សេងទៀតនៅពេលនោះ នៅក្នុងមុខងារការងាររបស់លោក?

**ឆ៖** សូមជម្រាបលោកប្រធាន! សូមទោសខ្ញុំសូមកែតម្រូវថា ជាសាលាបច្ចេកទេសឫស្សីកែវ ពុំមែនអ្ញូរឬស្សីទេ ។

**ស៖** ថាតើលោកចេញពីការងារឃោសនា ហើយបន្ទាប់មកទៅសាលាបច្ចេកទេសឫស្សីកែវតែម្តង ឬក៏លោកបំពេញការងារអីទៀតនៅក្នុងចន្លោះពេលនោះ?

[១៣:៤៧:១៤]

**ឆ៖** នៅក្នុងចន្លោះពេលនុ៎ង គឺខ្ញុំបានធ្វើការងារខាង-- មុនដំបូងសុំមកខិតឡើងលើបន្តិច ពីដំបូងនៅខាងក្រសួងពាណិជ្ជកម្មៗរដ្ឋ គឺមាន កុយ ធួន ជានាយករដ្ឋមន្ត្រីនាពេលនោះ បានឲ្យខ្ញុំគូរស្លាកកាណូត កប៉ាល់ ដាក់ថា "ពាណិជ្ជកម្មជើងទឹក ដឹកជញ្ជូនជើងទឹក" ស្លាកហ្នឹងដែលខ្ញុំបាញ់ជាស្លាកកាណូត កប៉ាល់ ទាំងអស់ហ្នឹង ។ ហ្នឹងខ្ញុំអ្នកធ្វើទាំងអស់ លេខកាណូត លេខកប៉ាល់ លើកខ្ញុំទាំងអស់ដាក់គ្រប់ស្លាកទាំងអស់ ដូចយើងដាក់ស្លាកឡានសព្វថ្ងៃអ៊ីចឹង ។

**ស៖** នៅពេលនោះ ថាតើលោកជឿបក្សកុម្មុយនីស្តកម្ពុជាទាំងស្រុងតែម្តង ហើយលោកគោរពទៅតាមនូវអ្វីដែលគេប្រាប់ឲ្យលោកធ្វើ ឬយ៉ាងម៉េច?

**ឆ៖** ជម្រាបលោកប្រធាន! នេះជាមុខងារបច្ចេកទេសរបស់ខ្ញុំ ដែលត្រូវចេះ ។ ខ្ញុំធ្វើទៅតាមមុខជំនាញរបស់ខ្ញុំ ហើយខ្ញុំមិនជឿជាក់ទេ ។ ខ្ញុំដឹងថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះធ្វើឲ្យខ្ញុំខូចអារម្មណ៍ហើយ អស់ទឹកចិត្តហើយ នឹកថាខំតស៊ូពីណាពីណីមកគ្រុនចាញ់ពោះខៀវដូចស្វាអ៊ីចឹងពោះដូចស្វាព្រៃអ៊ីចឹង ឡើងខៀវ ។ គ្រុនៗនោះគ្រុនៗឆ្អែតឆ្អន់រឿងគ្រុនចាញ់ ខ្ញុំមិនគួរណាមកទទួលលទ្ធផលចុងក្រោយអ៊ីចឹង បានខ្ញុំវាមិនមានពាក្យអីនឹងថ្លាថ្លែងទេ មានតែពាក្យការសោកស្តាយខុសខ្លួន ។ ដោយសារអំពើព្រៃផ្សៃដឹកនាំហ្នឹង ដឹកនាំវាៗមិនស្របនឹងឆន្ទៈនឹងចិត្តគំនិតយោបល់ និងទស្សនៈរបស់ខ្ញុំសោះ ។ ខ្ញុំចូលតែខ្លួនទេ តែចិត្តខ្ញុំមិនចូលទេ ។ ពាក់អាវខ្មៅមែន ប៉ុន្តែ ចិត្តខ្ញុំមិនខ្មៅទេ! គេឲ្យប្រើធ្វើអ្វីគឺធ្វើនុ៎ង តាមមុខងាររបស់ខ្ញុំដែលខ្ញុំចេះ ។

សូមជម្រាបលោកចៅក្រមតែប៉ុណ្ណឹង សូមចប់ ។

[១៣:៥០:១០]

**ស៖** ថាតើមានពេលណាមួយជាក់លាក់ដែរឬទេ? ដែលលោកបានបាត់បង់ការជឿជាក់ទៅលើបក្សកុម្មុយនីស្តកម្ពុជា នៅពេលដែលលោកថា លោកបានជឿហ្នឹង ប៉ុន្តែអ្វីដែលគេធ្វើនោះគឺមិនឆ្លើយតបទៅនឹងភាពការពិតជាក់ស្តែង ។

**ឆ៖** ខ្ញុំដូចជាមិនយល់នូវសំណួររបស់លោកចៅក្រម សូមលោកបញ្ជាក់ឲ្យបាន ថាពាក្យសាមញ្ញបន្តិច ហើយខ្លីបន្តិចស្រណុកខ្ញុំយល់ ។

**ស៖** ដូច្នេះ យើងអាចនិយាយបានដែរទេថា នៅពេលដែលលោកកំពុងធ្វើការងារនៅឫស្សីកែវ ហើយនៅពេលដែលលោកធ្វើការងារមុននឹងនៅក្នុងការឃោសនា លោកបានផ្តល់ការជឿជាក់លើអង្គការបក្សកុម្មុយនីស្តកម្ពុជា ។

**ឆ៖** ខ្ញុំសូមជម្រាបរឿងធ្វើការនេះតាមកិច្ចបញ្ជារបស់ប្រធានអង្គភាពដែលគេចាត់តាំងឲ្យខ្ញុំធ្វើជាគូរជាគំនូរ គ្រឿងម៉ាស៊ីនក្តី គ្រឿងបន្ទាស់ខ្មៅខ្ចងក្តី ដើម្បីឲ្យសិក្ខាកាមខ្មែរក្រហមរៀនហ្នឹងគឺទៅតាមកិច្ចបញ្ជារបស់ប្រធានសាលាបច្ចេកទេសឫស្សីកែវគឺ តាហាក់ ។ សូមជម្រាបលោកប្រធានប៉ុណ្ណឹង ។

**ស៖** លោកបានពន្យល់ថា មេរបស់លោកនៅសាលាបច្ចេកទេសនោះត្រូវបានចាប់ខ្លួន ហើយលោកខ្លួនឯងត្រូវបានគេបញ្ជូនទៅអប់រំ នៅពេលនោះ ថាតើការជឿជាក់របស់លោកចំពោះបក្សកុម្មុយនីស្តកម្ពុជា? តើលោកមានការផ្លាស់ប្តូរមិនជឿជាក់-- ឈប់ជឿជាក់ទៅលើបក្សកុម្មុយនីស្តកម្ពុជាទៀតដែរឬទេ?

**ឆ៖** ពេលនោះខ្ញុំ សូមជម្រាប *(ឮមិនច្បាស់)* ពេលនោះខ្ញុំៗអស់ជំនឿត្រង់ថា ខ្ញុំធ្វើការសុខៗធ្វើការងារល្អ ។ បានន័យថា ល្អចុះ ពីព្រោះខ្ញុំធ្វើការមិនដែលភ្លេចភ្លាំងទេ គេបញ្ជាឲ្យធ្វើអីគឺធ្វើហ្នឹង តែខ្ញុំមិនយល់ហេតុអីបានបញ្ហាដែលគេផ្លាស់ប្តូរហ្នឹងមកលត់ដំនៅសហករណ៍តាឡីហ្នឹង ខ្ញុំអស់ទឹកចិត្តពីកន្លែងហ្នឹង ។ សូមជម្រាបលោកប្រសាសន៍-- ប្រសាសន៍លោកប្រធានចៅក្រមត្រង់ៗអ៊ីចឹង ។ ខ្ញុំអស់ទឹកចិត្តពីត្រឹមហ្នឹងមក អស់ជំនឿពីត្រឹមហ្នឹងមក ។

[១៣:៥៣:៤៣]

**ស៖** ប៉ុន្តែទោះបីជាភាពលំបាកលំបិន ឬស្ថានភាពលំបាកដែលលោករងគ្រោះក៏ដោយ លោកនៅតែអនុវត្តទៅតាមបញ្ជាដែលគេដាក់នៅចំពោះលោក ។ ដូច្នេះ លោកពិបាកណាស់ក្នុងការស្វែងយល់ថា

ហេតុអ្វីបានជាគេចាប់ខ្លួនលោក ដោយខាងក្រុមកម្មាភិបាលសន្តិសុខនោះ?

**ឆ៖** សូមជម្រាបលោកចៅក្រមថា ការនោះទាំងខ្ញុំ ទាំងអ្នកដទៃក៏ផ្លាស់មកដែរ ។ ប្រហែលជាគ្នាប្អូនដប់នាក់ ផ្លាស់ពីសាលាបច្ចេកទេសឫស្សីកែវនោះមកសហករណ៍តាឡី មិនដឹងពីមូលហេតុអី? ប៉ុន្តែមុននឹងផ្លាស់មកហ្នឹង គេឲ្យធ្វើប្រវត្តិរូប ។ ខ្ញុំនៅចាំគេធ្វើប្រវត្តិរូប ហើយខ្ញុំក៏ធ្វើប្រវត្តិរូបជូនអង្គការថ្នាក់ដឹកនាំនុ៎ងទៅក៏គេ បានប៉ុន្មានទេ? ស្រាប់តែរំលងមួយខែឬពីរខែហ្នឹងភ្លេចទៅហើយ ប្រហែលប៉ុណ្ណឹងគេផ្លាស់មកសហករណ៍តាលៃហ្នឹងមានគ្នាមួយឡានប្រហែលជាប់ដប់នាក់កាលនុ៎ង ។ ទាំងប្រពន្ធខ្ញុំទាំងអីគឺមកទាំងអស់គ្នា មកធ្វើការនៅសហករណ៍តាឡី នៅលត់ដំខ្លួននៅសហករណ៍តាឡីហ្នឹង ។ ខ្ញុំមិនដឹងពីមូលហេតុដែរ សូមជម្រាបប្រសាសន៍លោកចៅក្រម ។ សូមអស់ប៉ុណ្ណឹង ។

**ស៖** នៅពេលនោះថា តើលោកធ្លាប់ឮអំពីមន្ទីរសន្តិសុខដែរ ឬទេ? ហើយលោកបានដឹងដែរឬទេអំពីករណីដែលថា ស-២១ នេះវាមានរួចទៅហើយនោះ?

**ឆ៖** សូមជម្រាបលោកចៅក្រមថា រឿងមន្ទីរសន្តិសុខក្តី រឿងគុកក្តីជំនាន់នោះ ខ្ញុំអត់ដែលឮសោះ ប៉ុន្តែស្រាប់តែបាត់មនុស្ស ។ មនុស្សចេះតែផ្លាស់ប្តូរជាប់ទៅលត់ដំទៅរៀនសូត្រទៅកន្លែងនេះទៅកន្លែងនោះ តាំងពីឆ្នាំ១៩៧៦ មកឮសួរតែផ្លាស់ប្តូរមនុស្សចេះតែផ្លាស់ប្តូរទីកន្លែងញឹកញាប់ ។ ខ្ញុំចេះតែឆ្ងល់មនុស្សធ្វើការសុខៗហេតុផ្លាស់ប្តូរអីចឹង ឬក៏គេចង់ឲ្យលត់ដំពីការងារអង្គុយស្ងៀមនៅបច្ចេកទេសហ្នឹងទៅធ្វើលត់ដំស្រែចម្ការ ជាកសិករ ជាកម្មករ ជាកសិករហ្នឹង ខ្ញុំចេះតែនឹកឆ្ងល់អីចឹង មិនមាត់មិនកទេ ។ ចេះតែខំអនុវត្តទៅតាមកិច្ចការដែលគេប្រគល់ឲ្យហ្នឹង ចេះតែខិតខំធ្វើទៅរើអង្គុលីលេខជាមេរៀនជាទ្រឹស្តីហ្នឹង ហើយនិងគូរភាពជាគ្រឿងម៉ាស៊ីនជាអីពន្យល់ដល់កូនសិស្សគេហ្នឹង ។

គំនិតរបស់គេខ្ញុំមិនអាចយល់ ពីព្រោះថ្នាក់គេគឺថ្នាក់ខ្ពស់ៗណាស់ ។ ខ្ញុំគេហៅ មនុស្សស្រទាប់ក្រោយសាមញ្ញាតូចទាបគ្រាន់តែមានតែបច្ចេកទេសនឹងបម្រើការងារឲ្យគេតែប៉ុណ្ណឹង ។ សូមចប់ ។

[១៣:៥៧:៥០]

**ស៖** ដូច្នេះយើងអាចនិយាយបានទេថា លោកមិនបានដឹងទាល់តែសោះថាលោកមិនបានប្រព្រឹត្តកំហុសអ្វី? ហើយលោកមិនបានដឹងថា លោកក្បត់បក្សកុម្មុយនីស្តកម្ពុជា ហើយលោកក៏មិនបានដឹងអំពីបញ្ហានៃអ្នកជនក្បត់នោះផងដែរ ។

**ឆ៖** សូមជម្រាបប្រសាសន៍! វាមានអីចេះដែរ កាលខ្ញុំមក-- សូមជម្រាបលោកប្រធានឲ្យច្បាស់ ខ្ញុំមកខាងអី? ប្រធានកុងសីខាងរដ្ឋមន្ត្រីខាងក្រសួងឃោសនាការឈ្មោះលោក ហ៊ូ នឹម បានស្នើខ្ញុំ

មកគូរនៅកន្លែងគាត់ជាផែនទី ជាផ្ទាំងគំនូរ ប្រព័ន្ធភ្លឺស្រែ ហើយកាលនោះមានសម្ដេចយើងរាល់ថ្ងៃនេះ គាត់បង្កាត់ក្មេងនៅកន្លែងនុ៎ង ។ គាត់បង្ហាត់របាំបាឡេ ហើយខ្ញុំក៏អង្គុយមើល ហើយគាត់-- លោកក៏ឃើញខ្ញុំចេះគូររូបស្អាតៗគាត់ទៅយករូបថតឲ្យខ្ញុំប៉ុនបីផ្ទាប់ហ្នឹង ប្រវែងហ្នឹង ខ្ញុំភ្លេចគុណប៉ុន្មាន ទំហំគុណប៉ុន្មាននឹងប៉ុន្មានទេ ខ្ញុំភ្លេចហើយ ។ ប៉ុន្តែ ចំនួនប៉ុណ្ណឹងខ្ញុំដាក់ហោប៉ៅអាវទៅថា បងជួយគូររូបឲ្យខ្ញុំមួយ ខ្ញុំថាបាទ ។ គូររូបពុកខ្ញុំឲ្យខ្ញុំមួយ ខ្ញុំយកមក អ្នក! ហៅព្រះបិតាហៅពុកអ៊ីចឹង ខ្ញុំចេះតែនឹកឆ្ងល់ក្នុងចិត្តមិនប៊ាននិយាយអីទេ ។ ខ្លាចប៉ះពាល់ខ្លាចគេចាប់អារម្មណ៍មកខ្ញុំដាក់ហៅប៉ៅអាវ ហើយទៅអង្គភាពវិញទៅ ទៅសាលាបច្ចេកទេសឫស្សីកែវវិញទៅ ។ ប្រហែលជាគេឃើញរូបហ្នឹង គេផ្លាស់ខ្ញុំមកក៏មិនដឹង ថាខ្ញុំពាក់ព័ន្ធនឹងអ្នកនេះអ្នកនោះ នឹងខ្មែរស្ដេចអីក៏មិនដឹងអីយ៉ាងម៉េចទេ? ខ្ញុំមិនដឹងទេ អាហ្នឹងជារឿងរបស់គេ នឹងមានអ៊ីចឹងមែន ។ នេះខ្ញុំសូមជម្រាបតាមត្រង់ ។

[១៤:00:០៤]

**សះ** នៅព្រឹកមិញនេះ លោកក៏បាននិយាយយ៉ាងច្រើន អំពីការការធ្វើបាបផ្សេងៗដែលបានធ្វើលើលោក ហើយលោកត្រូវបាននិយាយអំពីការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្តរបស់លោក ។ ហើយលោកក៏បាននិយាយថា លោកមានស្លាកស្នាមនៅលើខ្នង ។ ខ្ញុំហាក់ដូចជាយល់ថា ការធ្វើទារុណកម្មនេះគឺវានាំឲ្យមានការថ្លង់ត្រចៀករបស់លោកផងដែរ ។ ថាតើលោកមានការលំបាក និងសល់លទ្ធផលណាមួយដែលកើតចេញពីការធ្វើបាបទាំងអស់នោះដែរឬទេ?

**ឆះ** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះគឺវាមានតាំងពីទះកំផ្លៀង មានតាំងពីវ៉ៃក្បាលសព្វគ្រប់ហើយ ការធ្វើទារុណកម្មនេះ ។ អ៊ីចឹងហើយ បើនិយាយឲ្យទៅវា ខ្ញុំយល់ថាប្រហែលបណ្ដាលមូលហេតុមកពីធ្វើទារុណកម្មហ្នឹងហើយ បានគេហៅថាចាស់មុនអាយុបាក់ធ្មេញមុនអាយុ ។ គេក្រោយៗៗស្រករខ្ញុំ បងខ្ញុំដូចជា ជុំ ម៉ី អីគេធ្មេញគេនៅពេញមាត់ ។ គេមានដែលអ្នកណាដល់អាណាអីធ្វើទះតប់អីឲ្យហឹងត្រចៀកឲ្យខូចត្រចៀកដូចខ្ញុំគ្មានទេ ។ គេនៅក្មេង ធ្មេញគេនៅក្មេង តែខ្លួនគេចាស់ អាយុគេចាស់ជាងខ្ញុំ បងខ្ញុំ១០ឆ្នាំ ។ បើប្រៀបធៀបនឹងវ័យមនុស្ស ហេតុអីបានគេនៅធ្មេងពេញមាត់ ខ្ញុំអស់ ។ មកពីខ្ញុំ គេធ្វើបាបខ្ញុំសំណល់ពីនុ៎ងមក ។ ខ្ញុំសូមបញ្ចប់ ។

**សះ** តាមអ្វីដែលលោកចងចាំនោះ តើលោកមានអារម្មណ៍ថា អ្នកដែលសួរចម្លើយលោកនោះគឺសប្បាយចិត្តនឹងធ្វើនោះទេ? ដោយថា ឃើញលោកមានការឈឺចាប់ តើគេសម្ដែងអារម្មណ៍សប្បាយឬយ៉ាងដូចម្ដេច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! គឺថាពេលគេធ្វើទារុណកម្មខ្ញុំហ្នឹង អ្នកខ្លះគេយកខ្នុរមកហែកស៊ី ហើយគេបោះគ្រាប់ខ្នុរលើក្បាលខ្ញុំក៏មាននៅកន្លែងផ្ទះវៃសួរចម្លើយហ្នឹង ។ ខ្ញុំនឹកទៅតូចចិត្តណាស់ ហេតុតែខ្ញុំជាអ្នកទោស ហេតុតែខ្ញុំ គេថា គេចោទថាខ្មាំង ខ្ញុំចេះតែទ្រាំទៅ គេធ្វើម៉េចគេធ្វើទៅតាមចិត្តគំនិតដែលគេអរសប្បាយ គេធ្វើបាបខ្ញុំដោយគ្មានការអាណិតអាសូរចំពោះខ្ញុំ ។ ខ្ញុំមានការក្តុកក្តួលណាស់ នឹកឃើញពេលណាខ្ញុំទឹកភ្នែក តូចចិត្តខ្លួនថាខំតស៊ូនឹងគេដែរ តែចុងបំផុតខ្ញុំត្រូវបានត្រឹមជាប់គុកត្រឹមគេធ្វើទារុណកម្ម ។ ដូចឈើគ្រុនចាញ់ស្លាប់ គឺស្លាប់ក្នុងព្រៃបាត់ហើយ ប៉ុនមកពីអាយុខ្ញុំថ្លៃណាស់ ។ សូមជម្រាបបញ្ចប់ប៉ុណ្ណឹង ។

**ស៖** នៅពេលដែលលោកជាជាងគំនូរនៅរោងជាងនោះ តើលោកចាំដែរឬទេថាតើមានសមាជិកណាម្នាក់ដែលគេយកចេញពីរោងជាងនោះ ទាក់ទងនឹងបាតុភាព ឬក៏ហេតុការណ៍មួយដែលគេយកចេញពីកន្លែងរោងជាងនោះប្រហែលជាពីរសប្តាហ៍ហើយ តើលោកចាំថា គេយកលោកមកវិញកន្លែងរោងជាងគំនូរនោះ ហើយលោកនិយាយថាសុំទោស ហើយអង្វរកគេ ហើយតើមានអ្នកណាទាត់ធាក់លោកដែរឬទេ អំពីសាច់រឿងហ្នឹង? ឬក៏ហេតុការណ៍ណាមួយស្រដៀងនឹងអ្វីដែលលើកឡើងអម្បាញ់មិញនេះ?

[១៤:០៤:៥៩]

**ឆ៖** តាមខ្ញុំនឹកចងចាំដូចជាគ្មានបាតុភាពអ្វីទេ ។ ហើយរឿងអ្នកខ្លះហ្នឹងក៏ អ្នកមួយនឹងនៅបន្ទប់ជិតខ្ញុំហ្នឹង គេចាប់ទៅបាត់ មិនដឹងជាមានកំហុសអ្វីទេ នៅបន្ទប់ក្បែរខ្ញុំហ្នឹង នៅកន្លែងសាលាបច្ចេកទេសឫស្សីកែវហ្នឹង ។ ហ្នឹងជាបុគ្គលិកនៅកន្លែងហ្នឹងដែរ ។ ពីរនាក់ប្តីប្រពន្ធ មិនដឹងជាចាប់ប្តីក៏មិនដឹងចាប់ប្រពន្ធទាំងពីរនាក់ហ្នឹទៅក៏មិនដឹង ស្រាប់តែបាត់ដែរ អស់ឃើញពីរនាក់ហ្នឹង ប្តីប្រពន្ធ ។ ហើយក្រោយមកដល់ខ្ញុំ ផ្លាស់មកសហករណ៍តាឡី ។ តាមខ្ញុំចាំបានឃើញតែប៉ុណ្ណឹង ការភ្លេចភ្លាំងក៏វាចាំខ្លះមិនចាំខ្លះសុំខន្តីអភ័យទោសចំពោះលោកប្រធានជាទីគោរព ដែលខ្ញុំនិយាយនេះ វាមានចាំខ្លះមិនចាំ ។ សូមចប់ ។

**ស៖** លោក ប៊ូ ម៉េង ខ្ញុំយោងទៅរកដើម្បីថា-- លោក ប៊ូ ម៉េង ក្នុងពេលមួយដែលលោកធ្វើការនៅកន្លែងជាងគំនូរនៅស-២១ នៅកន្លែងគូរនៅស-២១នោះ ក្នុងពេលនោះ ក្នុងពេលនោះឯងដែលធ្វើការជាជាងគំនូនៅរោងជាង តើលោកបានធ្វើការជាមួយលោក វ៉ាន់ ណាត ហើយអ្នកគូរផ្សេងទៀតក្នុងពេលហ្នឹង ។ តើមានរឿងអ្វីកើតដែលលទ្ធផលនៃរឿងហ្នឹង ដែលថាលោកផ្ទាល់ត្រូវទៅនិយាយសុំទោស

គេដោយមានអំពើអ្វីមួយ តើធ្លាប់មានឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម! គឺការសុំទោសនេះមិនដឹងសុំទោសទៅអ្នកណា? ទៅគ្នាឯងក៏មិនដឹង ទៅលោកប្រធានសារមន្ទីរគុកទួលស្លែង ប្រធានសន្តិសុខស-២១ ហ្នឹង ឬមួយយ៉ាងណា ខ្ញុំមិនទាល់យល់រឿងហ្នឹង ។

**ស៖** តើគេបានបង្ខំលោកឲ្យសុំទោសទៅអ្នករួមការងារជាមួយគ្នានៅក្នុងរោងជាងស-២១ ឬក៏ឲ្យសុំទោសទៅអ្នកណាម្នាក់ទេ? តើថ្ងៃមួយ គេបានដាក់ខ្នោះ ដាក់ច្រវាក់ ហើយគេបាននាំទៅជួបមនុស្សមួយម្នាក់ ឬក៏ជាអ្នករួមការងារដើម្បីឲ្យគេ-- ឲ្យលោកសុំទោសគេនៅកន្លែងរោងជាងហ្នឹង តើមានដែរឬទេ?

**ឆ៖** តាមខ្ញុំនឹកមើលទៅដូចជាមិនឃើញ មើល៍ ខ្ញុំច្រឡំក៏មិនដឹង ភ្លេចក៏មិនដឹង ពីព្រោះថាការសុំទោសហ្នឹងដូចមិនដែលសុំទោសអ្នកណាទេ គ្នាឯងក្តីអីក្តីក៏មិនដែរ ។ អានេះខ្ញុំនិយាយនេះដោយការចងចាំ និងការភ្លេចភ្លាំង វាចៀសមិនផុតទេ ដូចពាក្យចាស់ថា "ដំរីជើងបួនតែងមានភ្លាត់ អ្នកចេះចងចាំស្ទាត់គង់មានភ្លេច" អ្នកហ្នឹងខ្ញុំសំអាងទៅលើពាក្យសុភាសិតខ្មែរបុរាណ ។

[១៤:០៩:១៥]

**ស៖** សូមអរគុណលោក ប៊ូ ម៉េង ដែលលោកបានឆ្លើយដល់ខ្ញុំ ។ ហើយខ្ញុំមានសំណួរចុងក្រោយមួយ ព្រឹកមិញនេះលោកបានប្រាប់យើងថា ជនជាប់ចោទបាននិយាយថា ពីរឿងជី គឺថាគេអាចនឹងយកមនុស្សអាចទៅធ្វើជីសម្រាប់ស្រែ ។ តើលោកអាចពន្យល់ពីអត្ថន័យពាក្យថា "យកមនុស្សទៅធ្វើជីស្រែ" នោះបានទេ?

**ឆ៖** ជម្រាបលោកប្រធាន! គឺខ្ញុំនិយាយនេះ ទៅតាមពាក្យរបស់លោកចុងចោទដែរ ឈ្មោះហៅថា កាំង ហ្គេកអ៊ាវ ហៅ ឌុច គាត់និយាយថា "បើគួរមិនដូច យកធ្វើជីស្រែ" ហើយខ្ញុំនឹងឆ្ងល់ថា ជីស្រែធ្វើម៉េច? យកធ្វើជីស្រែយកទៅឲ្យខ្ញុំកាប់ជញ្ជ្រាំធ្វើជីស្រែ ឬមួយក៏យកខ្ញុំទៅកប់ក្នុងស្រែឲ្យមានជីជាតិដល់ស្រូវ ដល់ដើមស្រូវដុះដងល្អូតលាស់ល្អ ។ ត្រង់ហ្នឹងដែលខ្ញុំនៅនឹងឆ្ងល់ដែរ អាហ្នឹងជាសម្តីរបស់គាត់ដល់សួរខ្ញុំ ខ្ញុំពិបាកឆ្លើយ ។ សុំទោស សុំចប់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោក ប៊ូ ម៉េង ។ លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមប្រគល់វេទិកានេះជូនទៅសហព្រះរាជអាជ្ញាដើម្បីមានលទ្ធភាពក្នុងការតាំងសំណួរដល់អ៊ំ ប៊ូ ម៉េង ដែលជាអ្នករស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១ ។ បើសិនជាមានសូមអញ្ជើញ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អរគុណលោកប្រធាន ជម្រាបសួរលោកពូ ប៊ូ ម៉េង ។ ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលោកពូ ។ ទាក់ទងទៅនឹងរបបអាហារ តើរបបអាហារដែលគេចាត់ចែងឲ្យលោកហ្នឹង តើលោកគិតថាគ្រប់គ្រាន់ដែរឬទេ?

[១៤:១១:៥៣]

**ឆ៖** ការរបបអាហារនៅពេលជាប់គុកហ្នឹងគឺមិនបានគ្រប់គ្រាន់ទេ តែនៅពេលដែលខ្ញុំចេញ គេអំពាវនាវរកអ្នកចេះគូរចេញមកគូរនៅក្នុងអគារ “E” ហ្នឹង ជាមួយនឹង វ៉ាន់ ណាត, ជាមួយនឹង អៀម ចាន់, ជាមួយនឹង រុយ នាគង់, ជាមួយនឹង អ៊ឹង ប៊ិច អីហ្នឹង, ផា ថនចាន់ អីហ្នឹង អាហ្នឹងវាការហូបគ្រប់គ្រាន់ ប៉ុន្តែក្នុងគុកហូបមិនគ្រប់គ្រាន់ទេ ។ អាហ្នឹងខ្ញុំនិយាយខាងដើមរួចហើយ ។ ហើយបើចង់ពិស្តារទៀត អាហ្នឹងវាមានឯកសារផ្សេងៗនៅ-- យើងផ្អែកទៅលើពាក្យបណ្តឹងរបស់ខ្ញុំខ្លះៗដែលបានធ្វើរួចហើយ ។ សូមជម្រាប សុំចង់ត្រឹមហ្នឹង ។

**ស៖** អរគុណ ។ តើនៅពេលដែលលោកជាប់នៅក្នុងមន្ទីរស-២១ ដែលថា នៅក្នុងបន្ទប់រួមនោះ ឬក៏បន្ទប់ដោយឡែកហ្នឹង របបអាហារលោកថាមិនគ្រប់គ្រាន់ទេ តើលោកមានវិធីអ្វីដើម្បីឲ្យបាន ហៅថាបំបាត់ការស្រេកឃ្លាននេះដែរទេ?

**ឆ៖** គឺថាគ្មានអ្វីបំពេញទេ ខ្ញុំវាឃ្លានៗហើយ ឃើញជីងចក់វាលើក្បាល នឹងថាបើធ្លាក់មកច្បាស់ជាស៊ី ហូបឲ្យមានកម្លាំង ។ ពេលដែលហេរហត់ស្គម កដៃប៉ុនដងវែក ។ ខ្ញុំនឹកៗទៅដូចថាមួយជីវិតខ្ញុំមិនដែលជួបប្រទះអ៊ីចឹង ខ្ញុំមិនដឹងធ្វើបុណ្យអ្វីបានមកជួបប្រទះ គេបង្អត់បាយ បង្អត់ទឹក ឲ្យតែទឹកកាវៗហូបអ៊ីចឹង ឬមួយវាចង់មានកម្មមានពារអ្វីពីជាតិមុនមកជាមួយនឹងអ្នកអស់ហ្នឹង ។ ខ្ញុំចេះតែនឹកឆ្ងល់រកកន្លែងនឹកមិនឃើញសោះនូវទោសកំហុសនៅ-- ខ្ញុំផ្អែកទៅលើកម្មផលរបស់ខ្ញុំទៅវិញ ។ នេះនិយាយកម្មផល ។ បើនិយាយពីផ្លូវច្បាប់វិញ រឿងដូចគ្មានខុសអីសោះ ដូចគ្មានធ្វើកំហុសអីសោះ ប៉ុន្តែគេនិយាយចេញមកថា ហ៎ស! មិនដែលអង្គការអ្នែកម្ចាស់មិនដែលចាប់មនុស្សមកភ្លើទេ ហ្នឹងពីដើមដំបូងគេ

និយាយអ៊ីចឹង កាលខ្ញុំចូលមក ។

**ស៖** អរគុណ ។ តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ដឹងថានៅមន្ទីរស-២១ នេះ មានការបូមឈាមដែរឬទេ? បូមឈាមអ្នកទោស ។

**ឆ៖** រឿងហ្នឹងខ្ញុំ ក៏មិនបានដឹងដែរ ពីព្រោះថាការធ្វើទារុណកម្ម ដូចខ្ញុំជម្រាបម្តងហើយ ម្តងទៀត ។ ចំពោះខ្លួនខ្ញុំគឺខ្ញុំដឹង គេធ្វើទារុណកម្មលើរូបខ្ញុំយ៉ាងម៉េចៗ គឺខ្ញុំដឹងតែចំពោះខ្លួនខ្ញុំ តែចំពោះទារុណកម្មចំពោះអ្នកដទៃ បូមឈាមក្តី ឬក៏ទារុណកម្មបែបផែនផ្សេងៗពីនេះក្តីក៏ខ្ញុំមិនបានដឹងដែរ ។ អានេះវាជារឿងរបស់គេ ។សូមចប់ប៉ុណ្ណឹង ។

[១៤:១៥:១៥]

**ស៖** លោកបាននិយាយថា លោកត្រូវបានគេធ្វើទារុណកម្ម ហើយវាយខ្លួនបែកចេញឈាមហើយពេលមួយ ហើយគេបានបញ្ជូនលោកទៅចាក់ទឹកអំបិល តើអ្នកដែល លោកទៅឲ្យគេចាក់ទឹកអំបិល អ្នកនោះជាពេទ្យ ឬក៏ជាអ្នកណា?

**ឆ៖** ប្រសាសន៍លោក! រឿងហៅខ្ញុំទៅព្យាបាលនៅជាន់លើ កាលនោះខ្ញុំជាប់បន្ទប់ម្នាក់ឯង វាដំបៅបែកពេញខ្នង គេហៅទៅព្យាបាលរបួសហ្នឹង គេហៅទៅបន្ទប់ខាងលើ ជាន់ទីពីរអីមិនដឹង ហ្នឹងហើយជាន់ទីពីរអ៊ីចឹងហើយ ។ ហើយគេព្យាបាលហ្នឹង អ្នកហ្នឹងឯងជាពេទ្យ គេថាពេទ្យ គេដើរចែកថ្នាំយប់ព្រលប់អី ក្រែងអ្នកណាឈឺក្បាល វិលមុខ អ្នកទោស គេចែកថ្នាំអាចម៍ទន្សាយ គ្រាប់ថ្នាំគ្រាប់អាចម៍លេបហើយ ហើយទៅខ្ញុំលេប ដល់លេបទៅវាចេះតែទើនៅបំពង់កលេបមិនចូល គេដាក់ក្បាលខ្ញុំមួយដៃបុាំង "គ្រាន់តែលេបប៉ុណ្ណឹងលេបមិនចូលដែរ បំពង់កអ្លែងប៉ុនណា បានលើកអាគ្រាប់ថ្នាំប៉ុនអាចម៍ទន្សាយលេបមិនរួច?"

**ស៖** អរគុណ ។ នៅពេលដែលគេស្វះស្វែងរកអ្នកគូររូប ហើយពេលនោះលោកត្រូវបានគេនាំយកទៅជួប ឌុច តើនៅពេលដែលលោកជួបឌុចហ្នឹង លោកមានអារម្មណ៍រីករាយ ឬក៏ភ័យខ្លាចយ៉ាងដែរពេលនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ពេលនោះខ្ញុំមានការត្រេកអរៗយ៉ាងម៉េច? ត្រេកអរថា ខ្ញុំមានវាសនានឹងបានហូបឆ្អែត ហើយខ្ញុំនឹកថា ប្រហែលជាដល់ពេលដែលខ្ញុំត្រូវរួចពីទុក្ខទោសទារុណកម្មនរកអវិចីហ្នឹងហើយមើលទៅ ។ ហើយខ្ញុំក៏សម្រេចចិត្តថា ខិតខំធ្វើគូរបំពេញការងារជូនគេហ្នឹងឲ្យបានពេញលេញ ប៉ុន្តែដំបូងដៃហ្នឹងគឺទៅហ្នឹង គេសាកខ្ញុំសិនមុននឹងឲ្យខ្ញុំត្រលប់ឡើង ថយក្រោយបន្តិចវិញ ។

គេសាកយ៉ាងម៉េច? សាកថា ដឹងជាអ្នកហ្នឹងចេះ ឬមិនចេះផង ។ ដល់អ៊ីចឹងគេឲ្យក្រដាសមួយសន្លឹង ដៃខ្មៅមួយ ឲ្យខ្ញុំ ធ្វើតេស្តខ្ញុំ ។ លោកហ្នឹង លោកមិនមែនធម្មតា លោកចេះណាស់ លោកកាំង ហ្គេកអ៊ាវ ហៅឌុចហ្នឹង លោកចេះណាស់ មិនមែនមនុស្សថ្នាក់ដូចខ្ញុំទេ កម្រិតវប្បធម៌គាត់ខ្ពស់ជាងខ្ញុំ តាមខ្ញុំយល់ មិនមែនតាមយល់ គឺដឹងអ៊ីចឹងតែម្តងកន្លងមក គាត់ខាង-- ជាប់លេខមួយខាងគណិតវិជ្ជាអីគេហ្នឹង អាហ្នឹងវាសំខាន់ណាស់មនុស្សៗគេគ្រាន់បើមែនទែន ។ តែចំពោះខ្លួនខ្ញុំ ថ្នាក់ខ្ញុំតូចទាបជាងគាត់ទេ ចេះតែជំនាញខាងគំនូរហ្នឹងទេ ។

[១៤:១៨:៣៨]

**ស៖** អរគុណ ។ តើនៅអំឡុងពេលដែលលោកត្រូវបានគេឲ្យទៅគូរគំនូរ លោកមានធ្លាប់ឃើញថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យណាទៅមន្ទីរស-២១ នោះដែរឬទេ?

**ឆ៖** ធ្លាប់ឃើញ តែមិនស្គាល់ឈ្មោះ ។ ធ្លាប់ឃើញម៉េច? ធ្លាប់ឃើញថាមនុស្សហ្នឹងរាងខ្ពស់ៗជាងគាត់ហ្នឹងទៀត ដើរប៉ុន្មាននាក់ហ្នឹងទៅនៅនឹងកន្លែងខ្ញុំគូរហ្នឹង ឃើញចូលមួយភ្លែត មិនដឹងជាអីទេ ហើយចេញមកវិញមក កាលនុំងខ្ញុំកំពុងគូររូប ប៉ុល ពត ។

**ស៖** លោកបាននិយាយថា លោកធ្លាប់បានឃើញគេបណ្តើរទាហានវៀតណាម ដែលលោកបានលួចមើលតាមបង្អួច តើលោកដឹងថា ទាហានវៀតណាម ហេតុអីបានជាលោកដឹងថា ជាទាហានវៀតណាម? មានស្លៀកពាក់ឯកសណ្ឋានឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបប្រសាសន៍លោក បានយល់ខ្ញុំយល់ថា ជាទាហានវៀតណាម ឃើញពាក់មួកកូប ហើយខោអាវខុសពីខោអាវកងទ័ពរំដោះខ្មែរក្រហមហ្នឹង ។ កងទ័ពខ្មែរក្រហមកងទ័ពហ្នឹងពាក់អាវខ្មៅ ខោខ្មៅ តែកងទ័ពវៀតណាមស្លៀកពាក់អាវពណ៌ត្រែអ៊ី ស្លៃជ្រក់ ។ សូមជម្រាប យល់ឃើញអ៊ីចឹង មើលឃើញសម្គាល់អ៊ីចឹង ។

**ស៖** អរគុណ ។ ត្រលប់មកកន្លែងដែលពេលជនជាប់ចោទបានធ្វើតេស្តសាកល្បងលោក ថាលោកមានចំណេះដឹងខាងគូរគំនូរយ៉ាងម៉េចដែរនោះ តើជនជាប់ចោទបានធ្វើតេស្តយ៉ាងម៉េចខ្លះដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក!ការធ្វើតេស្តដូចខ្ញុំនិយាយឲ្យអស់ មិនទាន់និយាយឲ្យចប់ចុងចប់ដើមពីលើកមុន ។ គាត់ឲ្យក្រដាសមួយសន្លឹកមក គាត់ឲ្យខ្ញុំខ្មៀកគំនូរឲ្យគាត់មើល ហើយខ្ញុំក៏ខ្មៀកគ្មានគំនូរទេ ប៉ុន្តែ ខ្ញុំចាំដៃពីធ្លាប់ធ្វើនៅក្នុងព្រៃ កន្លងមកនៅក្នុងភ្នំពេញហ្នឹងដែរ នៅសាលាបច្ចេកទេសឫស្សីកែវហ្នឹង ហើយខ្ញុំធ្លាប់គូរវាចាំដៃហើយ អ៊ីចឹងខ្មៀកទៅ គាត់ថា “អើ! បាន ។ អ៊ីចឹងអ្លែងត្រូវការ

ឧបករណ៍អីខ្លះៗ?” ខ្ញុំក៏រៀបរាប់ប្រាប់ “ត្រូវការប្រេងកាតមួយលីត្រ ត្រូវការជក់ ត្រូវការសំឡី ដើម្បីយកមកផាត់ពីព្រោះផ្ទាំងវាធំ ហើយនិងទឹកគេសម្រាប់សរសេរចិន យកមកគូសស្នែក គូសអី រង្វង់មាត់អី សរសៃសក់អី” អាហ្នឹងខ្ញុំប្រាប់ទៅគាត់អ៊ីចឹង គាត់ក៏ឱ្យកូនចៅគាត់ហ្នឹងដើររកៗ កាលនោះវាសម្បូរដែរ ។ ឧបករណ៍នៅភ្នំពេញហ្នឹងគ្រប់ទីកន្លែង កន្លែងណាក៏មិនខ្វះដែរ រំដោះហើយថ្មីៗឧបករណ៍ច្រើនណាស់ ចង់ធីណាក៏មានដែរ ក្រដាសកងសុងមកពីស្រុកបារាំង អារម្មូរមួយម៉ែត្រកន្លះទទឹងមួយបំពង់មួយរម្មូរនោះ ទើបលើទៅឱ្យខ្ញុំ ខ្ញុំក៏លាប្រវែងមួយម៉ែត្រកន្លះ កម្ពស់ប្រវែងក្រដាសហ្នឹង គុណនឹងទទឹងមួយម៉ែត្រកន្លះ វាទាំងអស់វាកាត់ជាបួនសន្លឹកសម្រាប់គូររូបថតប៉ុល ពត ហ្នឹង ហើយរូបថត ប៉ុលពតហ្នឹងទៀត មិនដែលឃើញរូប ប៉ុល ពត ផ្ទាល់ទេ ឃើញតែក្នុងរូបដែលគេយកមកឱ្យគូរហ្នឹង ខ្នាតវាប្រហែលជាមួយតឹកកន្លះ គុណនឹងមួយតឹកប្រាំបីអីអ៊ីចឹង ហើយគេដាក់ស៊កក្នុងស្រោម រូបថតហ្នឹង ។ អាកន្លែងរូបថតហ្នឹង វាស្រោមហ្នឹង រូបថតហ្នឹងគេដាក់ថា “ហាងថតរូបរដូវផ្ការីកនៅខេត្តសៀងហៃប្រទេសចិនប្រជាមានិត” ។

[១៤:២៣:០៩]

**ស៖** អរគុណ ។ សូមលោកជួយបញ្ជាក់បន្តិចថា នៅពេលដែលលោកត្រូវបានគេចាប់បញ្ចូលមកមន្ទីរស-២១ តើលោកមានគិតដែរទេថា ជីវិតរបស់លោកនឹងត្រូវគេសម្លាប់នៅថ្ងៃណាមួយ ទោះបីជាលោកមិនបានធ្វើអីខុសក៏ដោយនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោក! ពីព្រោះរឿងនេះខ្ញុំមិនបានគិតដល់ បានជាមិនគិតដល់អ៊ីចេះចំពោះមនុស្សត្រង់ មិនយល់ថា គេយកមកហ្នឹងដើម្បីសម្លាប់ ឬមួយយ៉ាងម៉េចទេ ដឹងតែឃើញគេប្រើឱ្យធ្វើការហ្នឹង ខ្ញុំគិតថា អូ! រស់វិញហើយ ប្រហែលមិនអីទេ ។ ខំធ្វើទៅតាមការគេណែនាំ គេស្អីចាត់តាំងទៅ ធ្វើគ្រប់បួនផ្ទាំង ប៉ុន្តែអក្សរផ្ទាំងចុងក្រោយនោះឥឡូវនេះវាបាត់ នៅសារមន្ទីរហ្នឹងគេធ្វើបាត់ មិនដឹងជាអ្នកណាលួចយករូបហ្នឹងទៅបាត់ទៅ ខ្ញុំវាស្តាយដែរ មានការសោកស្តាយខ្លាំងដែរ អន្តរជាតិសួររកគ្រប់តែគ្នា ។ បើតាមតែជួបពួកបរទេស វាជាប់មួយរយប្រទេសតាំងពី១៩៨១ មកឥឡូវហ្នឹង ។ កាលពីឆ្នាំ១៩៨១ ចិត្តសិបទេ មកទស្សនានៅសារមន្ទីរហ្នឹង ។

**លោកសេង ប៊ុនឃាង៖**

អរគុណលោកប្រធានខ្ញុំអស់សំណួរហើយ សូមអញ្ជើញសហការីរបស់ខ្ញុំ ដើម្បីបន្តសំណួរ ។

**ប្រធានអង្គជំនុំ៖**

សូនអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ ។

[១៤:២៥:០៣]

**លោក រ៉ូបឺត ពើទីត៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទេទៅសាក្សី ហើយខ្ញុំសូមអនុញ្ញាតដែលសាក្សីលោកបានផ្តល់នូវសក្ខីកម្មថ្ងៃនេះ ក្នុងនាមខាងសហព្រះរាជអាជ្ញានោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមប្រគល់វេទិកានេះជូនទៅខាងមេធាវី តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយដោយការកត់សម្គាល់ពីម្សិលមិញឃើញថាមានការបែងចែកនៃអទិភាពទៅតាមកូនក្តី នៃតំណាងក្រុមនីមួយៗ សំណួររបស់អង្គជំនុំជម្រះសួរថា តើប្រកាន់ជំហរដូចកាលពីម្សិលមិញដែរទេថា កូនក្តីនៅក្នុងក្រុមណា គឺក្រុមហ្នឹងមានអាទិភាពក្នុងការនិយាយមុន ហើយពេលវេលាអ្នកដែលក្រុមក្រោយទៀតគឺជារឿងបន្ទាប់បន្សំបំពេញបន្ថែម?

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

សូមអរគុណលោកប្រធាន ។ យើងខ្ញុំសូមអនុញ្ញាតបន្តរបៀបនីតិវិធីដូចនេះក្នុងសប្តាហ៍នេះហើយនិងសប្តាហ៍ក្រោយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ។

**សួរដោយលោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំឡើងសួរសាក្សី សួរដើមបណ្តឹងរដ្ឋប្បវេណីដែលរស់រាមមានជីវិត ហើយសូមគោរពអង្គជំនុំជម្រះទាំងអស់ ។

**ស៖** ជាបឋមខ្ញុំបាទសូមជម្រាបសួរអ៊ំដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង ក្នុងសំណួរដំបូងនេះខ្ញុំសូមសួរបន្តិច ចំពោះបញ្ហាទាក់ទងទៅនឹងត្រចៀករបស់អ៊ំដែលថា ត្រូវរងការធ្វើទារុណកម្ម ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរអ៊ំថា តើសព្វថ្ងៃនេះ អ៊ំស្តាប់គេនិយាយផ្ទាល់នឹងត្រចៀកបានទេ ឬមួយក៏អ៊ំប្រើអ្វី ដើម្បីជាជំនួយនៅក្នុងការស្តាប់?

**ឆ៖** លោកតុលាការបានអនុគ្រោះនិងជួយនាំខ្ញុំទៅ មន្ត្រីតុលាការហ្នឹងនាំខ្ញុំទៅកន្លែងពេទ្យត្រចៀកទៅវាស់មើល ។ ដល់វាស់ទៅគេឲ្យធ្វើប្រដាប់ស្រូវសំឡេងហ្នឹងមកឲ្យ ឮគ្រាន់បើ បើស្តាប់ត្រចៀកទេមិនដឹងគេនិយាយរឿងអីទេ នៅចម្ងាយហ្នឹងនិយាយមិនឮទេ ទាល់ទៅជិតស្តាប់ ឱនត្រចៀកស្តាប់អាហ្នឹងបានឮ ។ ឧបមាថាមួយរយភាគ វាឮបានត្រឹមសាមសិបភាគរយប៉ុណ្ណឹង ។

[១៤:២៨:១៦]

សព្វថ្ងៃនេះខ្ញុំដូចមនុស្សពិការទាំងអស់ ភ្នែកក៏ពិការ ត្រចៀកក៏ពិការ ធ្មេញវាជារឿងធម្មតារបស់វ័យមនុស្សទេ ។ ប៉ុន្តែ វាគ្រាន់តែថា វាបាក់មុនអាយុ ដូចខ្ញុំនិយាយអ៊ីចឹង ជុំ ម៉ី អាយុបងខ្ញុំដប់ឆ្នាំជាង គេនៅពេញមាត់ តែខ្ញុំបាក់អស់ អាហ្នឹងគេហៅចាស់មុនអាយុ ធ្មេញចាស់មុនអាយុ ។ បើមិនធ្វើទារុណកម្មទេ ខ្ញុំក៏មិនទាន់បាក់ដែរធ្មេញហ្នឹង ។ ហើយត្រចៀកខ្ញុំ បើធម្មតាក៏វាមិនទាន់ដល់ថ្នាក់ហ្នឹងដែរ អានេះថ្នាក់និយាយចម្ងាយហ្នឹងអីមិនឮទេ ទាល់តែទៅឱនត្រចៀកស្តាប់បានឮ ។

**ស៖** សូមអរគុណលោកអ៊ំ ។ អ៊ីចឹងខ្ញុំសូមតាំងសំណួរជាបន្តទៀត ខ្ញុំចង់ដឹងថា តើការឈឺចាប់របស់អ៊ំហ្នឹង មានរយៈពេលប៉ុន្មានបានអ៊ំជា ឬមួយក៏នៅតែឈឺចាប់រហូតដល់ឥឡូវនេះ?

**ឆ៖** បញ្ជាក់សួរឲ្យច្បាស់ថា តើឈឺចាប់ផ្លូវកាយ ផ្លូវចិត្តរួមគ្នាទាំងអស់ ឬមួយក៏ឈឺចាប់អ្វី?

**ស៖** សូមអរគុណ។ ទាក់ទងនឹងត្រចៀករបស់អ៊ំ អ៊ំឈឺហ្នឹងណ៎ា ពេលគេវ៉ៃទៅអ៊ំមានរងនូវការឈឺចាប់ អ៊ីចឹងអ៊ំឈឺហ្នឹងដល់ឆ្នាំណាបានជា ឬមួយក៏ឥឡូវហ្នឹងក៏នៅតែឈឺដែរ?

**ឆ៖** ឥឡូវនេះបានជាហើយ ហើយក៏វាគ្រាន់តែថាស្តាប់វាមិនឮ ទាល់តែថែមជំនួយសំឡេងហ្នឹងទៅបានពេទ្យអង្គឌួង គេធ្វើសំឡេងសម្រាប់ស្រូបសំឡេងហ្នឹង អាហ្នឹងជំនួយទៅ បានដាក់ទៅវាឮ ។ ធម្មតាត្រចៀកទទេដាក់ទៅ និយាយមិនដឹងស្តាប់ទេ មឹងមាំង១ដូចមនុស្សថ្លង់អ៊ីចឹង ។ សូមអស់ ។

**ស៖** ទាក់ទងទៅនឹងការឆក់ខ្សែភ្លើង ដែលអ៊ំបានលើកឡើងថា ការឆក់ខ្សែភ្លើងនោះ គឺប្រើខ្សែភ្លើងតាមរយៈខ្សែភ្លើងដែលនៅជាប់នឹងជញ្ជាំង ។ អ៊ីចឹង ខ្ញុំសូមសួរថា សូមសាក្រោយបន្តិច អ៊ំថាឆក់នៅក្បែរប្រដាប់កេរ្តិ៍ភេទរបស់អ៊ំ អ៊ីចឹងខ្ញុំចង់សួរសំណួរថា តើការឆក់នោះនៅចម្ងាយប៉ុន្មានពីប្រដាប់កេរ្តិ៍ភេទនោះ?

**ឆ៖** សូមជម្រាប នៅចំគល់ភ្លៅតែម្តង ។ គ្រាន់តែឆក់វ៉ាប់ សន្លប់ភ្លឹងតែម្តង ស្រាប់ដឹងខ្លួនវិញទទឹកជោកខ្លួនអស់ ។

**ស៖** បាទសូមអរគុណ ។ អ៊ីចឹងកាលដែលគេដាក់ឆក់នោះ តើគេដាក់ពីលើខោ ឬមួយក៏គេដាក់ផ្ទាល់នឹងសាច់តែម្ដង?

**ឆ៖** គេឆក់ផ្ទាល់សាច់តែម្ដង ប៉ុន្តែគេមាន គេហៅប្រដាប់ទប់ភ្លើងមួលឲ្យនៅប៉ុន្នានវ៉ុល។ ដែលឃើញគេយកមកដាក់នៅហ្នឹង គេដោតពីអាន់ុងហ្នឹងមកវិញ ។ គេមានដោត*ឌីរ៉ុច* នឹង*ព្រី* នៅកន្លែងតាមជញ្ជាំងទេ គេមានប្រដាប់ទប់ឲ្យបាន-- ចង់បានប៉ុន្នានវ៉ុល ប៉ុន្នានវ៉ាត់អ៊ីចឹង គេដាក់មក គេឆក់ ។ ប៉ុន្តែបើភ្លើងហ្នឹង បើមិនខ្លាំងវាមិនឆក់សន្លប់ទេ បាត់មាត់ទេ ។ ប្រហែលជាភ្លើងខ្លាំង ។ ខ្ញុំអស់ហើយ ។

**ស៖** សូមអរគុណ ។ ឥឡូវអ៊ំបានជម្រាបអង្គជំនុំជម្រះហើយថា ពេលឆក់ភ្លាមសន្លប់ភ្លាមអ៊ីចឹង អ៊ំមានបានដឹងទេថា តើរយៈប៉ុន្នាននាទី ប៉ុន្នានម៉ោង ក្រោយមកបានដឹងខ្លួនវិញ?

**ឆ៖** សន្លប់ធ្វើវណា ធម្មតាអ្នកសន្លប់មិនដឹងថា ម៉ោងណា។យើងសន្លប់ទេ ដូចយើងដេកអ៊ីចឹង យើងដេកអ៊ីចឹងទៅមិនដឹងថាម៉ោងណាដេកលក់ទេ ។ សូមទោស ។

**ស៖** ទាក់ទងនឹងបញ្ហាមួយទៀត អ៊ំមានបានទៅខាងពេទ្យផ្លូវចិត្ត ដើម្បីសុំឲ្យគេជួយអ៊ំផ្នែកខាងផ្លូវចិត្តអីទេ?

**ឆ៖** កន្លងមកខ្ញុំបានទៅខាងពេទ្យផ្លូវចិត្តគេពិនិត្យ ហើយគេនឹងជួយខ្ញុំថ្នាំវីតាមីន ថ្នាំសម្រាប់ធ្វើប្រសៃប្រសាទនឹងឆាប់ដេកលក់ ។ មិនឲ្យគិតច្រើន អាហ្នឹងគេឲ្យពីរមុខ មកលេបជារៀងរាល់ថ្ងៃ បានគ្រាន់បើហើយឥឡូវហ្នឹង មិនស្រូវមានការគិតគូរអីវែងឆ្ងាយទេ ។ តែដល់មកនិយាយអ៊ីចេះ ខ្ញុំជម្រាបត្រង់ចុះ ទៅហូបបាយ ហូបអត់កើតទេ ។ ហូបបានតែកន្លះចានទេ អំមិញ និយាយត្រង់ វាគិតឃើញច្រើនពេញ វានេះអស់ហើយ វាខូចអារម្មណ៍អស់ ។ បាយមិនឆ្ងាញ់ អីក៏មិនឆ្ងាញ់ ។

[១៤:៣៤:០៣]

**ស៖** បានសូមអរគុណ ។ ទាក់ទងទៅនឹងការសួរចម្លើយ អ៊ំបានជម្រាបអង្គជំនុំជម្រះថា មានមនុស្សប្រាំនាក់ឈ្មោះ ហ៊ា, ចាន់, ទិត, ប៉េង, ហ៊ុយ ។ អ៊ីចឹង អ៊ំមិនទាន់បានបញ្ជាក់ច្បាស់លាស់ថា តើនៅពេលសួរចម្លើយនោះ អ្នកទាំងប្រាំនោះ នៅជាមួយគ្នាវ៉ៃអ៊ំ ឬក៏ចូលម្ដងម្នាក់ៗ?

**ឆ៖** ចូលម្ដងម្នាក់ៗ ម្នាក់ហត់ចូលម្នាក់ទៀត ។ ប៉ុន្តែវ៉ៃ ខ្ញុំប្រាប់ថា ចាន់ ចូលមុនគេវ៉ៃ វ៉ៃរាប់ខ្ញុំរាប់បានដប់ ឲ្យវ៉ៃទៅឲ្យខ្ញុំរាប់ មួយ, ពីរ, បី, បួន, ប្រាំ តាមរំពាត់ដែលគេវ៉ៃ ។ ខ្ញុំរាប់បានដប់ ខ្ញុំថាដប់ហើយ “អ្ហែ! អញទើបវ៉ៃមួយ អ្ហែងថាដប់” សម្ដីតា ម៉ម ណៃ និយាយអ៊ីចឹង ។ ខ្ញុំនៅចាំមិនភ្លេចទេ ចាំទាំងមុខ-- ធម្មតាទេ ឧក្រិដ្ឋជនតែបាញ់មនុស្សងាប់ហើយ គេយកហែកភ្នែកមនុស្សថតមើលឃើញ

ដឹងថារូបអ្នកណាៗ វាចាំណាស់ៗអ្នកដែលធ្វើបាប ។ ចាំមុខណាស់ អ្នកធ្វើល្អក៏ចាំ អ្នកមិនធ្វើល្អក៏ចាំ ។

**ស៖** សូមអរគុណ ។ ប៉ុន្តែ ខ្ញុំចង់សួរអ៊ីចេះ ចង់សួរថា នៅថ្ងៃតែមួយៗអ្នកទាំងប្រាំហ្នឹង មកវាយ ឬក៏ម្តងម្នាក់ៗ ថ្ងៃនេះវ៉ៃម្តង ស្អែកមានអ្នកផ្សេងទៀត ខាងស្អែងម្នាក់ផ្សេងទៀត?

**ឆ៖** អានេះបើនិយាយទៅ ក្រុមគេអ្នកធ្វើទារុណកម្មហ្នឹង មានប៉ុន្មាននាក់ ។ ឧទាហរណ៍ថា ប្រាំនាក់ហ្នឹង វ៉ៃម្នាក់ម្តងៗទាល់តែបាត់ហត់ ទាំងប្រាំនាក់ទៀតគេ-- ដល់ពេលគេឈប់បានគេឈប់ ដល់ម៉ោងគេឈប់ ឧទាហរណ៍ថា ម៉ោងប្រាំពីរ ដល់ម៉ោងដប់មួយ ឬដប់ពីរ គេសម្រាកហើយ បាយទឹកហើយ អាហ្នឹងគេឈប់ហើយ ។ វាឃើញទាំងអស់គ្នាហ្នឹង ។

**ស៖** អ៊ីចឹងបើតាមខ្ញុំយល់ អ៊ំចង់បញ្ជាក់ថា ក្នុងថ្ងៃតែមួយហ្នឹងមានវត្តមានអ្នកទាំងប្រាំនាក់ហ្នឹង អ៊ីចឹងទេអ៊ំ?

**ឆ៖** បាទ, ពិតមែនអ៊ីចឹង ។

**ស៖** ខ្ញុំសូមសួរជាបន្តទៀត ។ អ៊ំបានបញ្ជាក់ជូនអង្គជំនុំជម្រះហើយថា នៅពេលដែលគេបាញ់ទឹកទុយោចូលក្នុងបន្ទប់ ។ អ្នកទោសទាំងអស់ហ្នឹង ត្រូវតែស្រាតខោចេញ ដើម្បីសម្អាតបន្ទប់ ហើយនិងសម្អួតខោហ្នឹងផង ពួតឲ្យស្ងួត ។ សួរថា អ្នកយាមបញ្ជាឲ្យអ្នកទោសទាំងអស់ហ្នឹង ស្រាត ឬមួយក៏អ្នកទោសទាំងអស់ហ្នឹង ចង់ទៅស្រាតខ្លួនឯង?

[១៤:៣៧:១៦]

**ឆ៖** ចង់បញ្ជាក់ថា វាមានការភ្លេចភ្លាំង វាជាងសាមសិបឆ្នាំហើយ ខ្ញុំភ្លេច ។ ប៉ុន្តែ ខ្ញុំចាំអ៊ីចេះចាំត្រង់ថា កាលដែលងូតហ្នឹង ឃើញស្រាតទាំងអស់គ្នាមួយហ្វូងអ៊ីចឹងសាម-សែសិបនាក់ ស្រាតទាំងអស់គ្នា ។ រហូតដល់ខ្ញុំចាំពាក្យសម្តីមួយ ម្នាក់ហ្នឹងនៅក្មេងអាយុប្រហែល១៥-១៦ប៉ុណ្ណឹង ។ គេថា "យើ! អានេះមាឌតូចទេ តែប្រដាប់ធំណាស់វី!" ខ្ញុំសូមទោសនិយាយពាក្យមិនសមរម្យ ប៉ុន្តែ និយាយតាមការពិត ។ "អ្ហែ!អានេះ ខ្លួនឲ្យប៉ុនយក្សឡើងតូចមួយ" ឮសួរនិយាយអ៊ីចឹង ខ្ញុំក៏មិនចាំអារម្មណ៍ដែរការនិយាយនេះ គេនិយាយកំប្លែងលេងសើចជាមួយគេ ។ អានេះ ខ្ញុំនៅចាំអ៊ីចឹង តែត្រង់ថា គេឲ្យស្រាត ឬខ្ញុំស្រាតខ្លួនខ្ញុំអាហ្នឹង វាមិនច្បាស់ ។ ធម្មតាងូតទឹក បើនៅទាំងខោវាកម្រស្ងួត ប្រហែលជាស្រាតខ្លួនឯងមិនដឹង ឬក៏គេប្រើឲ្យស្រាត ដើម្បីឲ្យឃើញគេមើល ល្អមើលភ្នែករបស់គេមិនដឹងទេ អាហ្នឹង ខ្ញុំមិនដឹងទេ ។ ខ្ញុំវាភ្លេចមិនបានចាំ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ខ្ញុំចង់ដឹងទៀតថា តើរាល់ពេលងូតទឹកហ្នឹង គឺថាត្រូវតែស្រាត អ៊ីចឹងទាំងអស់ ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ, ត្រូវស្រាតទាំងអស់គ្នា ។ ស្លកទាំងអស់ហ្នឹង មើលដូចគ្មានរណាមួយថា មាននៅខោស្លៀក ឬក៏មានក្រម៉ាផ្លាស់អីទេ អត់ទេ ។ គឺស្រាតទាំងអស់គ្នា មួយហ្វូងដូចនរកអ៊ីចឹង ខ្ញុំមើលសង្វេកក្នុងចិត្តណាស់ ។ ហេតុតែខ្លាំង ហេតុតែយើងអ្នកទោស គេបាញ់ទឹកទុយោពីក្រៅមកស្រោចពេញខ្លួនសព្វអស់អ៊ីចឹងទៅបានទឹកល្អាចល្អឹមពេញតែក្នុងបន្ទប់ហ្នឹង យកខោផ្តិតៗពូតដាក់ក្នុងឡាំងគ្រាប់ក៏តាមប្រហោងបង្ហូរទៅក្រៅហ្នឹង ។ ពូតដាក់ហ្នឹង ជូតឱ្យទាល់តែស្ងួត បាត់ទឹកដក់លើហ្នឹងបានឈប់ហើយដេកទៅវិញហើយ ដេកលើទឹកហ្នឹងមិនទាន់ស្ងួត ។ ហើយកើតរមាស់ កើតចៃសរៗតាមចង្កេះខោហ្នឹង ខាំកើតរមាស់ ខ្ញុំកើតរមាស់ រហូតទៅដល់ទៅគួរនៅតែរមាស់អ៊ីចឹង ។ មិនដឹងជាខ្ញុំមិនចាំទេកាលនុំង ប៉ែន អេន អ៊ីចឹងមិនដឹង ញ៉ែម អេន អ៊ីចឹងមិនដឹង រកថ្នាំស្អី ស្ពាន់ធម៍ៗ បានរកប្រេងដូងឱ្យខ្ញុំកម្តោចធ្វើប្រេងដូងបានបន្តិច យកមកដាក់លាយជាមួយហ្នឹង លាបអាររមាស់ហ្នឹង បានបាត់ទៅ ។ អាការដើររកថ្នាំរកអីហ្នឹង តែពួកអង្គរក្សសន្តិសុខហ្នឹង តូចៗអាយុ១៥, ១៦, ១៧ ហ្នឹង គេអ្នករកពីភ្នំពេញថ្នាំស្ពាន់ធម៍ហ្នឹង ម្សៅស្ពាន់ធម៍ ដាក់លាយប្រេងដូងលាបរមាស់ពេញខ្លួនកាលនុំង ។ ខ្ញុំចាំអ៊ីចឹង ។

[១៤:៤០:៣៤]

**ស៖** អ៊ីចឹង នៅពេលដែលងូតទឹកហ្នឹង អ៊ំដែលបានទទួលសាប៊ូអីដុសខ្លួនទេ?

**ឆ៖** អត់មានសាប៊ូ អត់មានអីដុសទេ គឺថាងូត លាងដូចជ្រូកអ៊ីចឹង ខ្ញុំធ្លាប់លាងជ្រូក ខ្ញុំត្រដុសអង្អែលជ្រូកធ្លាប់ចញ្ចើមដែរ ។ ងូតទឹកទាល់តែលាងវា ឆ្កែក៏អ៊ីចឹង កាលណាងូតទឹកឱ្យវា លាងសម្អាតវាយកដៃលាងវា ដុសសាប៊ូ ។ តែអានេះខ្ញុំចោកជាឆ្កែទៀតហ្នឹង អត់បានដុសសាប៊ូ មានសាប៊ូអីដុសទេហើយក៏អត់ក្រម៉ាអីផ្លាស់ត្រឹមត្រូវដែរ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ខ្ញុំសូមសួរសំណួរបន្តទៅទៀត ទាក់ទងទៅក្នុងបន្ទប់រួម អ៊ំមានដែលឃើញអ្នកទោសដែលត្រូវគេនាំទៅក្រៅ ហើយត្រលប់មកវិញ មានឃើញអ្នកទោសហ្នឹងមានស្នាមរបួសអីលើខ្លួនទេ?

**ឆ៖** ដូចជាមិនដែលឃើញទេ ។ ប្រហែលជាគេដាក់ដូចខ្ញុំអ៊ីចឹង ក៏មិនដឹង ព្រោះខ្ញុំរៃហើយ គេយកមកដាក់បន្ទប់ខាងក្រោមអាជាន់ទីបីហ្នឹង អាបន្ទប់គេធ្វើឈើ ធ្វើស៊ីម៉ង់ត៍ហ្នឹង ដាក់ក្នុងបន្ទប់ហ្នឹង ។

អាហ្នឹង ដើម្បីអ្នកដទៃគេដឹកថា ខ្ញុំត្រូវរំពាត់បែកខ្នង ដំបៅពេញខ្នង ។

**លោក គង់ ពិសី៖**

បាទ,សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំពីរនាទី រហូតដល់ម៉ោងបី សូមចាប់ផ្តើមបន្តទៀត ។ មន្ត្រីតុលាការសម្របសម្រួលឲ្យអ៊ំ ប៊ូ ម៉េង បានមានទទួលនៅកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:00 នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ហើយសូមប្រគល់វេទិកានេះជូនទៅមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបន្តសំណួរសួរដល់អ៊ំ ប៊ូ ម៉េង ដែលជាអ្នករស់រានមានជីវិតមួយក្នុងចំណោមអ្នករស់រានមានជីវិតនៅមន្ទីរសន្តិសុខស-២១ ។

**សួរដោយលោក គង់ ពិសី៖**

បានសូមអរគុណលោកប្រធានម្តងទៀត ហើយក៏សូមគោរពអង្គជំនុំជម្រះ ដែលបានអនុញ្ញាតឲ្យខ្ញុំបាទបន្តសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីដែលរស់រានមានជីវិតពីមន្ទីរ ស-២១ ។

**ស៖** ហើយសំណួរបន្តទៅទៀត អ៊ំបានបញ្ជាក់ជូនអង្គជំនុំជម្រះហើយថា អ៊ំបានឃើញអ្នកយាមស្ត្រី ប៉ុន្តែស្ត្រីមានផ្ទៃពោះ អ៊ីចឹងសំណួរសួរថា តើអ៊ំឃើញគេបណ្តើរពីណាទៅណា?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! គឺថាខ្ញុំមើលទៅខាងកើត ទ្វារខាងកើត ហើយខ្ញុំនៅគួរផ្អែកគំនូរហ្នឹង វាផ្អែកជញ្ជាំងជិតក្បែរមាត់បង្អួចហ្នឹង ហើយខ្ញុំក្រឡេកឃើញតាម ប្រឡោះទ្វារហ្នឹងៗកាលហ្នឹង ឃើញស្រីហ្នឹងពោះធំ មនុស្សស្រីហ្នឹង ដើរមកឃើញតែមនុស្សស្រីបណ្តើរហ្នឹង ឃើញធាក់ទាត់គ្នា មិនដឹងជាដួល មិនដឹងអី ខ្ញុំក៏មិនបានមើលចប់ចុងចប់ដើមដែរ ពីព្រោះខ្លាចខាងក្នុងនេះគេឃើញខ្ញុំលួចមើលអ៊ីចឹង គេវ៉ៃខ្ញុំ ខ្លាចគេធ្វើទារុណកម្មអីខ្ញុំ ខ្ញុំមើលតែក្រឡេកកន្ទុយភ្នែកមួយភ្លែតទៅឃើញអ៊ីចឹង ។ អាហ្នឹងខ្ញុំបានឃើញនឹងភ្នែកខ្ញុំ ដោយខ្ញុំលួចមើល ។ សូមចប់ ។

**ស៖** សូមអរគុណ។ អ៊ីចឹងអ៊ំឃើញអ្នកមានផ្ទៃពោះនោះប៉ុន្មាននាក់? ហើយអ្នកយាមបណ្ដើរអ្នកមានផ្ទៃពោះនោះប៉ុន្មាននាក់?

**ឆ៖** សូមជម្រាបថា អ្នកដែលផ្ទៃពោះនោះមានតែម្នាក់ទេ ហើយអ្នកដែលបណ្ដើរនោះឃើញពីរបីនាក់ដើរពីក្រោយ មានប៉ុណ្ណឹង ។

**ស៖** អ៊ំឃើញច្បាស់ថា ធាក់ ឬក៏ទាត់ ?

**ឆ៖** អត់ទាត់--មានតែធាក់ រឿងទាត់មិនដែលឃើញ មិនមានអ្នកណាចេះទាត់ ចេះដាល់ទេ មនុស្សស្រី គ្នាគេ គេច្រើនតែធាក់ ច្រើនតែទះកំផ្លៀងអីហ្នឹង អាហ្នឹងវាឃើញអ៊ីចឹង វាដើរមិនលឿនអាហ្នឹងវាអ៊ីចឹងណា ហើយធម្មតាមនុស្សភ័យដើរលឿនទីមទើមជំពប់នេះជំពប់នោះវាធម្មតាទេ វាភ័យវាព្រលឹងនៅក្នុងខ្លួនវាអស់ហើយ ដើរចេញអស់ហើយ ដូចខ្ញុំអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

អ៊ំៗ អ៊ំ ម៉េង អ៊ំៗចាំបង្អង់បន្តិច ចាំដល់ពេលមានភ្លើងក្រហម សឹមអ៊ំមានប្រសាសន៍ អាហ្នឹងបានវាអាចស្រូបសំឡេងទៅអ្នកបកប្រែបាន អ៊ំចេះតែនិយាយមុនទៅ អត់បកប្រែបានទេ អ៊ីចឹងខាងភាសាអន្តរជាតិហ្នឹងស្ដាប់អត់បានណាអ៊ំណា ហើយអ៊ំចង់បានឲ្យសំឡេងអ៊ំហ្នឹងបានទទួលទាំងខ្មែរទាំងអ្នកនៅក្នុងនេះ ហើយទាំងប្រជាជនខ្មែរនៅក្នុងកម្ពុជាទាំងមូលគេអាចស្ដាប់តាមវិទ្យុ ឬក៏តាម ទូរទស្សន៍ផង ហើយក៏ឲ្យមានការបកប្រែជាភាសាអន្តរជាតិ ជាភាសាបរទេស ដែលគេអាចស្ដាប់នៅ លើពិភពលោកផងអ៊ំណា ។

**លោក គង់ ពិសី៖**

ដោយចៃដន្យខ្ញុំក៏អស់សំណួរហើយដែរ ហើយខ្ញុំក៏សូមអនុញ្ញាតពីលោកប្រធានដើម្បីផ្ដល់ឱកាសទៅដល់អ៊ំ ប៊ូ ម៉េង ដើម្បីតាំងសំណួរទៅសួរជនជាប់ចោទ នៅពេលដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមផ្សេងៗទៀតបានសួរចប់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុមបន្តទៀតដែលគាំទ្រ សូមអញ្ជើញមេធាវីក្រុមមួយ បាទ ។

**សួរដោយកញ្ញា ទី ស្រ៊ីនណា៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន ក៏ដូចជាអង្គសវនាការទាំងមូល ។ សូមជម្រាបសួរលោកអ៊ំ ប៊ូ ម៉េង ! ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរទៅលោកអ៊ំ ហើយខ្ញុំសូមលោកអ៊ំជួយ

ឆ្លើយយ៉ាងខ្លីៗដើម្បីជួយ នេះដោយសារពេលវេលារបស់ក្រុមដើមបណ្ដឹងរដ្ឋប្បវេណីខ្ញុំមានពេលរយៈពេលខ្លី អ៊ីចឹងខ្ញុំសូមលោកអ៊ំជួយឆ្លើយខ្លីៗទៅនឹងសំណួររបស់ខ្ញុំ ។ សូមអរគុណ ។

**ស៖** សំណួរទីមួយរបស់ខ្ញុំ ខ្ញុំចង់សួរថា ចាប់តាំងពីលោកអ៊ំទៅដល់មន្ទីរស-២១ មកគេធ្វើទារុណកម្មទៅលើលោកអ៊ំដើម្បីសាកសួរយកចម្លើយ តើរយៈពេលសរុបនៃការធ្វើទារុណកម្មមកលើលោកអ៊ំហ្នឹងមានរយៈពេលប៉ុន្មាន?

[១៥:០៥:៤៤]

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកមេធាវី! អ្នកស្រីមេធាវី ខ្ញុំអារឿងហ្នឹងវាដូច វាដូចជាមានការភ្លេចភ្លាំង រយៈពេលដែលគេសួរចម្លើយហ្នឹង វាៗច្រើនខែដែរ ច្រើនអាទិត្យដែរ មិនមែនច្រើនខែទេ ច្រើនអាទិត្យ ។ ប៉ុន្តែ ធម្មតានៅជាប់នៅក្នុងគុកនុំង វាទម្រាំតែតាំងពីធាត់រហូតដល់កដៃប៉ុនដងវែក វាយូរដែរ ហូបទឹក បបររាវៗហ្នឹង អានេះសូមបញ្ជាក់ទៅក្រោយបន្តិចវិញ ។ វាធម្មតាទេ កាលនៅកម្លាំងពេញខ្លួន គេមិនទាន់ចាប់ផ្ដើមវិតយើងទេ បកស្បែកយើងទេ ដល់យើងស្គមកម្លាំងយើងអន់ហើយ បានគេបកស្បែកយើង ពាក្យថា បកស្បែកហ្នឹង គេយកទៅវ៉ៃ ហើយវ៉ៃហើយ ធម្មតាវ៉ៃមានដំបៅ ដំបៅមានសម្លាក ហើយ សម្លាកស្បែកចាស់ ទៅចេញអាស្បែកថ្មីមកស្ដើងៗ ។

**ស៖** សូមអរគុណលោកអ៊ំ ខ្ញុំសូមបន្តសំណួរទីពីរ ។ ទាក់ទងនឹងសំណួរទីពីរ ខ្ញុំចង់សួរលោកអ៊ំថានៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ពេលនុំងលោកអ៊ំបានចាកចេញពីមន្ទីរ ស-២១ ពេលដែលអ៊ំចាកចេញពីមន្ទីរ ស-២១ នោះ មានខាងសន្តិសុខមន្ទីរ ស-២១ បានបង្ខំអ៊ំទៅជាមួយគាត់ ពេលនោះតើអ្នកដែលបង្ខំបានន័យថា សន្តិសុខដែលបង្ខំអ៊ំទៅជាមួយនឹងគាត់មានឈ្មោះអ្វីដែរ? ហើយមានគ្នាប៉ុន្មាននាក់?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំដូចជាមិនចាំថាប៉ុន្មាននាក់ទេ ប៉ុន្តែ ដឹងច្បាស់ថាបណ្ដើរខ្ញុំទៅកាត់យប់ហ្នឹង វាតាមចំការដូង តាមអីហ្នឹង ប៉ុន្តែចេញពីគុកទួលស្លែង ឈប់នៅកន្លែងមួយដូចជាកន្លែងម៉ុ កន្លែងប៉ុស្ដិ៍ទូរទស្សន៍ កន្លែងផ្ទះមួយត្រង់ហ្នឹង ស្នាក់នៅត្រង់ហ្នឹងសិន ។ ដល់ព្រលប់ហ្នឹងបានចាប់ផ្ដើមដើរចេញទៅកាត់តាមចំការដូង ។ ហើយកាត់តាមចំការដូងហ្នឹងទៅ មិនដឹងជាមានកងទ័ពអ្នកឆ្នាំហ្នឹងប៉ុន្មាននាក់ទេ ខ្ញុំភ្លេចទៅវាភ័យពេក មិនដឹងជាគេយកទៅសម្លាប់ចោល ឬគេយកទៅធ្វើអីខ្ញុំអត់ដឹង ។ ដល់អ៊ីចឹងវាភ័យ ដល់ភ័យលែងដឹងរឿងអី មិនដឹងជាប៉ុន្មាននាក់ៗទេ ប៉ុន្តែ គ្រាន់តែឃើញមានស្ពាយកាំភ្លើង ។

**សះ** លោកអ៊ំខ្ញុំអរគុណច្រើន ប៉ុន្តែខ្ញុំសុំសួរទាក់ទងទៅនឹងឈ្មោះ ឈ្មោះអ្នកយាមដែលគេទៅជាមួយលោកអ៊ំ តើលោកអ៊ំអាចចាំបានទេ ថាតើគាត់មានឈ្មោះអ្វីដែរ?

**ផះ** អត់ចាំ បើអ្នកវ៉ៃចាំ ដល់ទៅអ្នកនាំបណ្តើរទៅមិនចាំទេ ភ្លេចហើយ ។

**សះ** សូមអរគុណលោកអ៊ំ ខ្ញុំសូមបន្តសំណួរខ្ញុំមួយទៀត ដែលជាសំណួរចុងក្រោយ ។ ខ្ញុំចង់សួរថាកាលពេលនុ៎ងលោកអ៊ំបានឮសំឡេងឡានដឹកអ្នកទោសចេញពីមន្ទីរស-២១ ទាំងថ្ងៃទាំងយប់ អ៊ំបានឮសំឡេងថាឡានដឹកចេញ ខ្ញុំគ្រាន់តែចង់សួរលោកអ៊ំថា ពេលដែលអ៊ំឮសំឡេងហ្នឹងឡានដឹកចេញតាមច្រកទិសខាងលិច ឬក៏តាមច្រកទិសខាងកើត? សូមលោកអ៊ំរកនឹកមើលសិនកុំអាលឆ្លើយ សូមលោកអ៊ំរកនឹកសិន បើសិនជាអ៊ំចាំ សឹមអ៊ំឆ្លើយ តែបើសិនជាអត់ចាំ ក៏អត់អីដែរលោកអ៊ំ ។

**ផះ** តាមខ្ញុំចាំ វាភ្លេចខ្លះអីខ្លះហើយ ពីព្រោះថាអារឿងឡានចេញឡានចូលវាជារឿងធម្មតាពីពេលនុ៎ងវាមិនដឹងជា អាដឹកចូលអាដឹកចេញ មិនដឹងជាដឹកចេញទៅណា អាដឹកចូលដឹងថាចូលមកកន្លែង មកកន្លែងទួលស្លែងហើយ ឮសួរតែសំឡេងចេញ និងសំឡេងចូល អាហ្នឹងពាក្យថាឮសំឡេងទេ ប៉ុន្តែ វាមិនបានឃើញផ្ទាល់នឹងភ្នែក ព្រោះខ្ញុំកាលហ្នឹងនៅជាអ្នកទោស នៅក្នុងកន្លែងប្រឡោះមួយៗហើយនិងកន្លែងរួមម្តេចនឹងគេឲ្យមើល មិនដឹងជាឡានគេឈប់នៅមុខគុកទួលស្លែងនេះ អត់បានឃើញខ្ញុំអស់ហើយ ។

[១៥:១០:៣៨]

**សះ** ខ្ញុំសុំទោស ប៉ុន្តែឥឡូវខ្ញុំសូមបន្តសំណួរមួយទៀត ដោយសារតែខាងក្រុមនាងខ្ញុំហ្នឹង គាត់មានសំណួរមួយទៀត ដើម្បីបន្តទៅលោកអ៊ំ អ៊ីចឹងខ្ញុំសុំបន្តសំណួរមួយទៀត ។ សំណួរមួយទៀត ទាក់ទងទៅនឹងលោកអ៊ំ បាននិយាយថា លោកអ៊ំបានឮសំឡេងសម្រែកថ្ងូររបស់ជនរងគ្រោះ គឺអ្នកទោសនៅក្នុងមន្ទីរស-២១ ស្រែកពីការឈឺចាប់របស់ពួកគាត់ ។ តើពេលដែលលោកអ៊ំឮសំឡេងនោះ លោកជនជាប់ចោទឈ្មោះ ឌុច គាត់នៅទីនោះជាមួយលោកអ៊ំដែរ ឬក៏អត់?

**ផះ** ការឮសួរសំឡេងហ្នឹង អ៊ីចេះ ខ្ញុំដេកនៅលើបន្ទប់រួមនៅខាងលើអគារ “គ” ជាន់ទីបី ហ្នឹងឮសួរសំឡេងយំ ឮសួរវ៉ើៗ បែបវ៉ៃសួរចម្លើយហើយគ្នាឈឺ ហើយស្រែកយំ ម៉ែអើយជួយផង ខ្ញុំងាប់ហើយគេវ៉ៃងាប់ហើយ ។ ឮសួរស្រែកយំច្បាស់ថែស ឮសួរពេញជុំវិញបរិវេណគុកទួលស្លែង ។ ផ្ទះជុំវិញហ្នឹងពីដើមសុទ្ធតែ ផ្ទះវ៉ៃសួរចម្លើយអ្នកទោស ។ ប៉ុន្តែ ឥឡូវហ្នឹងខ្មែចខ្ចី អាខ្លះក៏រុះទៅពី៧៩ រុះខ្លះអីខ្លះទៅ ។ ឥឡូវហ្នឹងគេកសាងផ្ទះថ្មី ផ្ទះថ្មពេញទឹកពេញដី ហើយមិនដឹងស្អីណាបាត់បង់អស់ហើយ

ភស្តុតាងអីអស់ទាំងហ្នឹង វារតាត់រតាយបាតអស់ហើយ រលុបអស់ហើយ អាស្លាកស្នាម ភស្តុតាងផ្ទះសួរចម្លើយហ្នឹង តែផ្ទះសួរចម្លើយខ្ញុំនៅក្រោយអគារ “A” ហ្នឹងក្រៅគុកនោះ ក៏ទៅជាផ្ទះរបស់គេអស់ហើយ ក៏បាត់បង់អស់ហើយអាស្លាកស្នាមពីមុនហ្នឹង លែងមើលស្គាល់មើលមិនយល់ទេ ។ សូមអស់ហើយ ។

**កញ្ញា ទី ស្រ៊ីនណា៖**

ខ្ញុំសូមអស់សំណួរ និងសូមអរគុណលោកអ៊ំ ដែលបានឆ្លើយទៅនឹងសំណួរខ្ញុំ ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីបន្តតទៀត មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ សូមអញ្ជើញ ។

[១៥:១៣:៥៣]

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណ លោកប្រធាន អង្គចៅក្រម ។

**ស៖** លោក ប៊ូ ម៉េង ខ្ញុំមានសំណួរមួយ លោកបាននិយាយថា នៅក្នុងបន្ទប់ដែលដាក់អ្នកទោសរួមនោះ គឺថាមានអ្នកទោសបរទេសដែលថា មានអ្នកទោសដែលមើលទៅដូចជាពួកបរទេស ។ តើគេយកអ្នកទាំងនោះចេញទេ? តើពួកគេនៅហ្នឹងបន្ទប់នោះដដែល នៅពេលដែលគេយកលោកចេញពីបន្ទប់នោះមកនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍ លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី! ពេលដែលខ្ញុំឃើញហ្នឹងឃើញអ៊ីចេះ ឃើញជាជនជាតិអឺរ៉ុប រាងខ្ពស់ ហើយភ្នែកស សក់ក្បាលរាង គេហៅថា ពណ៌ទង់ដែង មិនដឹងជាសាសន៍អីទេ ប៉ុនជាជនជាតិអឺរ៉ុប ។ ហើយឃើញតែរយៈពេលខ្លីស្រាប់បាត់ទៅ មិនឃើញ មិនឃើញនៅយូរទេ ឃើញប្រហែលជាចំនួនកន្លះខែអីប៉ុណ្ណឹង ខ្ញុំចូលមកជាប់គុកនៅកន្លែងអគារ “គ” ហ្នឹងខាងជាន់ខាងលើហ្នឹង បន្ទប់រួម ឃើញមិនយូរទេ ស្រាប់បាត់ទៅ មិនដឹងថា ទៅណា មិនដឹងគេយកទៅណាអត់ដឹង ។ សូមចប់ហើយ ។

**ស៖** សូមអរគុណ ។ សំណួរ លោកបាននិយាយថា លោកបានឃើញទាហានវៀតណាមមានទាំងឯកសណ្ឋានផង ដូច្នេះហើយលោកច្បាស់ថា ពួកទាំងនោះគឺជាទាហានវៀតណាម ដោយអត់មានចម្ងល់ទេ ។ តើអ៊ីចឹងឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោកមេធាវី! ពីព្រោះថា ទាហានវៀតណាម បានស្គាល់ថា វៀតណាម ពីព្រោះឃើញពាក់មួក វាខុសពីមួកកងទ័ពខ្មែរក្រហម កងទ័ពខ្មែរក្រហមសម្លៀកបំពាក់ឯកសណ្ឋានខ្មៅ ពាក់មួកកន្ទិបប៉ារ៉េ ដូចចិនកុម្មុយនីស្តអ៊ីចឹង ។ ហើយចំនែកឯកសណ្ឋានរបស់កងទ័ពយួនហ្នឹង ពណ៌ គឺថាពណ៌ស្លែទេ ខោអាវ ហើយសម្លៀកបំពាក់ឯកសណ្ឋានគេហ្នឹងពណ៌ស្លែ ហើយមានសក្តិលើស្មាអ៊ីចឹង ហើយមានពាក់មួកគោក ហ្នឹង អាហ្នឹងកាលដែលខ្ញុំឃើញ ខ្ញុំសម្គាល់ ច្បាស់ជាទ័ពយួន ។ ដឹងតាមខ្ញុំដឹងឃើញប៉ុណ្ណឹងតាមការជាក់ស្តែងដែលខ្ញុំបានជួបប្រទះនៅពេលហ្នឹង ។ សូមចប់យោបល់ ។

**ស៖** ខ្ញុំសួរសំណួរនេះ វាហៅថា អាចនឹងមានលក្ខណៈសង្ស័យបន្តិចនៅក្នុងចម្លើយរបស់លោកដែលខ្ញុំយល់មិនទាន់ច្បាស់។ តើទាហានវៀតណាមទាំងអស់នេះ ជាកងទ័ពដែលនៅឯកសណ្ឋានរបស់គេ ឬក៏ជាកងទ័ពវៀតណាម ដែលថា អាចជាផ្នែកដែលគេ អ្នករៀបចំនៅក្នុងមន្ទីរស-២១នោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី! អានេះតាមខ្ញុំ ទស្សនៈខ្ញុំយល់ឃើញទេណា! មិនមែនជាគេក្លែងក្លាយទេ ក្រែងដូចពាក្យថាបារាំង ហ្សុីន អ៊ីចឹង អារបស់ ហ្សុីន ហ្នឹង វាសុទ្ធណា អាហ្សុីនហ្នឹង វាសុទ្ធហើយ វាមកពីនាយ គ្មានពីណាបំពាក់ គ្មានពីណាក្លែងក្លាយទេ គឺវាច្បាស់ត្រង់ថាខោអាវហ្នឹង វាស្ទើសស្អក មានចាស់ខ្លះ អីខ្លះ មានថ្មី មានចាស់អ៊ីចឹង ។ ច្រឡំគ្នាច្របូកច្របល់គ្នា ។ សូមបញ្ចប់ ។

**ស៖** អ៊ីចឹង លោកបញ្ជាក់ថា ទាហានទាំងអស់នោះ គឺមិនមានឋានៈជាអ្នកទោសទេ ឬយ៉ាងដូចម្តេចនោះ?

**ឆ៖** ខ្ញុំឆ្លល់ ធម្មតាដូចលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច អ៊ីចឹង លោកនិយាយថា តែមកកន្លែងហ្នឹងគឺវាសុទ្ធហើយ គ្មានស្អីប្រកែកទេ ។ ពាក្យថា ខ្មាំង មួយម៉ាត់ហ្នឹង សូម្បីតែខ្មាំងទ័ព ខ្មាំងខ្ញុំក៏ដោយ គឺថាខ្មាំងហើយ ។ អ៊ីចឹងវាពិបាកនឹងវែកញែកជូនលោកស្រីដែរ ។ សូមចប់ ។

**ស៖** លើសពីហ្នឹងទៅទៀត លោកបាននិយាយថា លោកបានឃើញអ្នកយាមមួយចំនួនដែលអាយុ១៥ ឬ១៦ឆ្នាំ តើលោកបានឃើញអ្នកយាម ដែលអាយុក្មេងជាងនោះទេ? ដែលថាអាយុពី១០ ឬក៏ ១២ឆ្នាំ?

**ឆ៖** ក្រោមអាយុ១៥ឆ្នាំចុះ ដូចជាមិនដែលឃើញទេ បើមានប្រហែលជាខ្ញុំភ្លេចភ្លាំងក៏មិនដឹង ប៉ុន្តែរឿងច្រើន ភាគច្រើនតែក្មេងអាយុ១៥ឆ្នាំ ១៦ឆ្នាំ ១៧, ២០ អីឡើងទៅ អាហ្នឹងមាន ។ អាហ្នឹងសូមបញ្ជាក់ប្រាប់តាមការឃើញហ្នឹងភ្នែករបស់ខ្ញុំនៅពេលនោះ ។ សូមចប់ ។

**សៈ** សូមអរគុណ ។ ហើយខ្ញុំមានសំណួរពីរទៀតដែលត្រូវសួរទៅលោកពេលនេះ ។ តើលោកមានអារម្មណ៍អាក្រក់ដែរឬទេ ដោយសារថា លោកបានចុះហត្ថលេខាលើចម្លើយសារភាពដែលមានការបង្ខិតបង្ខំ ដែលលោកដឹងថា ខ្លឹមសារនៃសេចក្តីសារភាពនោះមិនពិតនោះ?

**ឆៈ** ជម្រាបប្រសាសន៍លោកស្រីមេធាវី! គឺថាពេលនោះ ខ្ញុំមានអារម្មណ៍ច្របូកច្របល់ភ័យផងព្រួយផង ច្របូកច្របល់ណាស់ វារកស្មានមិនត្រូវ ។ អារម្មណ៍ខ្ញុំចេះតែធ្វើឲ្យរួចពីដៃ ពីជើងនោះទេ ។តែការពិតទៅ គឺខ្ញុំ វាគ្មានដូចថា វាគ្មាហេតុអេទអីគួរឲ្យគេសង្ស័យថា ជា *សេអ៊ីអា* ជា*ការហ្សេបេ* វាគ្មានសុខចិត្តបែកខ្ញង សុខចិត្តទារុណកម្ម ទទួលនូវទារុណកម្ម ដូចវាហួសប្រមាណហើយ ។ បើនិយាយឲ្យខ្លីទៅ អ្នកខ្លះគេវៃ គេសារភាព គេយកទៅកម្ទេចចោល ។ ប៉ុន្តែចំពោះខ្ញុំ គ្មានអីចឹងទេ ខ្ញុំវាទៅជាខុសគេ គេសរសេរស៊ីញេទទួល អឺ!ទៅក្រៅ គេហៅថា ក្រៅខ្លួនក្រៅចិត្ត តែក្នុងចិត្តហ្នឹង មិនមានអីយល់ស្របឯកភាពទៅតាមអាចម្លើយហ្នឹងទេ ។ សូមចប់ ។

**សៈ** មិនមានអ្នកណាម្នាក់នឹងដេញដោលពីគំនិតនោះទេ ។ សំណួរមួយទៀត នៅក្នុងរោងជាងនៅក្នុងចំណោមជាងគំនូរ ជាងចម្លាក់ទាំងអស់នោះ ក្នុងចំនួនអ្នកទាំងអស់នោះ តើលោកបាននិយាយគ្នាទៅវិញទៅមក អំពីរឿងទារុណកម្ម ឬក៏អំពីចម្លើយសារភាពប្រាប់អ្នកផ្សេងទៀតនៅក្នុងរោងជាងហ្នឹងដែរឬទេ?

**ឆៈ** សូមជម្រាបប្រសាសន៍លោកស្រី! ខ្ញុំពុំដែលនិយាយទេ បានថាមិនដែលនិយាយពីព្រោះខ្ញុំខ្លាច ។ ទីមួយ គឺឆ្មាំគុកនៅក្នុងហ្នឹងពីរ ឬបីនាក់ ចាក់សោរខាងក្នុងផង ខាងក្រៅផង ។ អ៊ីចឹងវាងាយណាស់រងទារុណកម្ម បើកាលណាយើងនិយាយកេះកៀវគ្នា ពីរឿងនេះពីរឿងនោះ ជជែកគ្នាអី ក៏មិនប៉ានដែរ ។ សូមចប់យោបល់ ។

**សៈ** សំណួរចុងក្រោយមួយ ថ្ងៃនេះតើលោកមានអារម្មណ៍ដូចម្តេចទេដែលថា លោកបានរួចរស់រានមានជីវិតហ្នឹង?

**ឆៈ** ជម្រាបប្រសាសន៍លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី! ខ្ញុំមានចិត្តត្រេកអរ ត្រេកអរយ៉ាងម៉េច? ត្រេកអរថា បានធូរទ្រូងខ្លះ នូវសំណួរចម្លើយដែលខ្ញុំឆ្លើយប្រាប់លោកចៅក្រម និងលោកស្រីមេធាវីនេះ គឺថាបានធូរច្រើនពីក្នុងខ្លួន ហើយខ្ញុំថា នៅពេលថ្ងៃក្រោយនេះ ខ្ញុំថានឹងមានសន្តិភាពពិតយុត្តិធម៌ពិតចំពោះអ្នកស្លាប់ជាងពីរលាននាក់ ឬបីលាននាក់នៅក្នុងរបបហ្នឹង ហើយរូបខ្ញុំក្នុងចំណោមនោះផង ដែលត្រូវទទួលទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។ បើនិយាយពីការវាស់ទំហំ សួរថា ទំហំប៉ុន្មានលោក?

ខ្ញុំក៏ប្រាប់លោក មិនកើត វាធំធេងពេក ។ ទារុណកម្មបែកខ្ទេចខ្ទាំងហើយ ចង់ស្លាប់ខ្លួនហើយ ថែមទាំងគួរគំនួរបានឲ្យអស់លោកប្រធានគុកទួលស្លែង សន្តិសុខស-២១ ហ្នឹងទៀត ។ ហើយមិនតែប៉ុណ្ណឹង មិនត្រឹមតែរួចខ្លួនមួយទេ សូម្បីតែជួយជីវិតប្រពន្ធក៏មិនបានផង សម័យនោះ ប្រពន្ធខ្ញុំត្រូវស្លាប់ដោយសារអី? អាហ្នឹងដោយសារកំហុសរបស់នាង ឬក៏ដោយសារកំហុសរបស់អ្នកណាឆ្លើយដាក់គាត់ ។ អានេះរឿងនេះគួរឲ្យសង្ស័យដែរ ។ អ៊ីចឹងហើយបានខ្ញុំចង់ឆ្លល់ ថាខ្ញុំចង់សួរទៅលោក ចំពោះលោកចុងចោទហ្នឹងពីរបីម៉ាត់ តើប្រពន្ធខ្ញុំស្លាប់នៅកន្លែងណា? ចង់យកដីហ្នឹង ដើម្បីយកមកជានិមិត្តរូបនៃការនឹកគុណនឹកដើម ធ្វើបុណ្យបញ្ជូនទៅឲ្យនាង ឲ្យនាងស្ងប់ចិត្ត ថាបងបានទទួលជំនុំជម្រះនៃតុលាការវិសាមញ្ញនៃតុលាការកម្ពុជា ហៅថា អ.វ.ត.ក នោះហើយ ។ អាហ្នឹងចង់អ៊ីចឹងហើយ ហើយចង់ធ្វើបុណ្យទានអីនិងរំឭកគុណ ដើម្បីមានតែព្រះធរណី ទឹកដីទេដែលលោកដឹង មនុស្សស្លាប់កន្លែងណា? ទារុណកម្មពីសោកសៅកន្លែងណា? កប់កន្លែងណា? មានតែដីទេ ទឹកដីទេ ដែលលោកដឹង ទឹកក៏លោកដឹង ដីក៏លោកដឹង ព្រះធរណី ភាសាពុទ្ធសាសនា គេថា ព្រះធរណី និងព្រះគង្គា គង្គា គឺទឹក ព្រះធរណី គឺដី ។ អ៊ីចឹងមានតែទឹកដីទេ ដែលអ្នកដឹង ។ អ្នកដែលវៃមនុស្សចោល ភរក៏បាន ឆ្លើយត្រង់ក៏បាន ឆ្លើយវៀចក៏បាន ប៉ុន្តែដីហ្នឹងដឹងៗថាប្រពន្ធខ្ញុំស្លាប់នៅហ្នឹង ។ អ៊ីចឹងយកដីកន្លែងហ្នឹង មកអធិដ្ឋាន អុជធូប នឹកគុណដល់វិញ្ញាណក្ខន្ធនាង ប្រហែលជាបានស្ងប់ចិត្ត ប្រហែលជាបាននឹកដល់គាត់ ។ សូមចប់ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណ លោកប៊ូ ម៉េង ។ លោកប្រធាន ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី ហើយមានសំណើមួយសួរ សុំដប់នាទីបន្ថែម គឺថាមានមេធាវីអាចនឹងតំណាងឲ្យជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ហើយជនរងគ្រោះទាំងអស់នេះ គឺសំខាន់ណាស់ គឺថាត្រឹមជនរងគ្រោះម្នាក់មួយនាទីកន្លះនោះ គឺថាយើងអាចនឹងបានពេលបន្ថែមទៀត ។ លោកប្រធានបានបង្ហាញអំពីគំនិតមួយដែលថាពិចារណាពេលនិងផ្តល់ ។ អ៊ីចឹងគឺថា យើងសូមអរគុណពីលក្ខណៈនេះ តើបើយើងចាំបាច់ដប់មីនុតថែមទៀត ប្រសិនជាអនុញ្ញាតគឺអាចធ្វើឲ្យយើងមានឱកាស និងធ្វើការជាមួយគ្នាកាន់តែរលូនទៅទៀត ។

[១៥:២៦:៣៤]

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកប្រធាន ប្រសិនបើផ្តល់ពេលបន្ថែមទៅឲ្យតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ ថាតើអាចផ្តល់ពេលបន្ថែមទេ បើចាំបាច់សម្រាប់មេធាវីការពារ ដើម្បីសួរសំណួរដែរនោះ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងដើម្បីកុំឲ្យវាស្មុគស្មាញ ហើយខាងមេធាវីការពារ ហើយជាការប្រើពេលវេលាហ្នឹង ដោយបាននិយាយច្បាស់លាស់ហើយថា ខ្លួនប្រើពេលវេលានៅក្នុងអំឡុងពេលសែសិបនាទី ហើយឲ្យអាទិភាពនៃមេធាវីតំណាងឲ្យកូនក្តីរបស់ខ្លួននិយាយមុន ហើយនិយាយច្រើន ។ អ៊ីចឹងបញ្ហានេះ យើងមិនអនុញ្ញាតឲ្យទេ ។ ហើយប្រកាសថា អស់នាទី អស់ម៉ោងសម្រាប់សួរហើយ ហើយឥឡូវនេះដល់សិទ្ធិរបស់អ្នករស់រានមានជីវិត អ៊ំ ប៊ូ ម៉េង ។ អ៊ំចង់តាំងសំណួរយ៉ាងដូចម្តេចជាក់លាក់ចំពោះជនជាប់ចោទនាពេលនេះ?

**លោក ប៊ូ ម៉េង៖**

បាទ, ខ្ញុំសូមជម្រាបប្រសាសន៍លោកចៅក្រម! ចង់សួរថា គាត់កម្ទេចប្រពន្ធខ្ញុំចោល សម្លាប់ប្រពន្ធខ្ញុំចោលនៅគុកទួលស្លែង ឬមួយក៏នៅជើងឯក ឬមួយនៅកន្លែងណាដទៃទៀតដែលលោកមានសិទ្ធិផ្លាស់ប្តូរនាង ឬក៏សម្លាប់នាង? ពីព្រោះអ៊ីចេះ វាយូរឆ្នាំហើយ ខ្ញុំបានទៅដល់ផ្ទះខ្ញុំនៅ ផ្ទះប្រពន្ធខ្ញុំបងប្អូនវា នៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ខ្ញុំទៅសួរបងថ្លៃខ្ញុំ នៅទេសព្វថ្ងៃ ។ ខ្ញុំថា មានដែលឃើញប្រពន្ធខ្ញុំមកហ្នឹងទេ ថាមិនដែរទេ បាត់ឈឹងសូន្យរហូតតាំងពីនុ៎ងមក ។ បើអ៊ីចឹងខ្ញុំសន្និដ្ឋានថា គេវ៉ៃចោលហើយ ជាប់គុកជាមួយខ្ញុំ ឥឡូវគេវ៉ៃចោលបាត់ហើយ ។ អ៊ីចឹងណ៎! ចំណុចហ្នឹងខ្ញុំចង់សួរ ថាវ៉ៃនៅកន្លែងណា? ខ្ញុំទៅយកដី ដើម្បីទៅយកដីហ្នឹងទេ មិនចង់ធ្វើអីទេ ប៉ុន្តែអានេះ វាមានឯកសារគ្រប់គ្រាន់ហើយ ពីព្រោះពាក្យបណ្តឹងមួយៗ សុទ្ធតែមានឯកសារដើមនៅទួលស្លែងហ្នឹងក៏មាន ឯកសាររបស់នាងហើយខ្ញុំក៏មានឯកសារដែរ តែវាបាត់រតាត់រតាយទៅ វាមិនដឹងយ៉ាងម៉េចទេ ។ អាហ្នឹងមិនដឹងជារកឃើញ មិនឃើញ អាហ្នឹងវានៅលើមន្ត្រីស៊ើបអង្កេតសាលាក្តី ស្រេចតែលោកមានឱកាសស៊ើបអង្កេតទេសព្វថ្ងៃ ខ្ញុំពឹងផ្អែកទៅលើច្បាប់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អ៊ំបញ្ជាក់ឡើងវិញថា ភរិយារបស់អ៊ំដែលជាប់នៅមន្ទីរស-២១ ជាមួយអ៊ំហ្នឹង ឈ្មោះ ម៉ា យឿន ហៅធី អ៊ីចឹងមែនទេ?

**លោក ប៊ូ ម៉េង៖**

បាទ, ពិតប្រាកដមែនហើយ លោកចៅក្រម ។ បាទ ឈ្មោះដូចជាលោកចៅក្រមបញ្ជាក់អំមិញអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច! សំណួរទីមួយ តើលោកស្គាល់ ម៉ា យឿន ហៅ ធី ដែរទេ? ហើយបើស្គាល់សំណួររបស់គាត់សួរថា តើក្នុងការចាត់ចែងនៅក្នុងអំឡុងពេលលោកជាប្រធានមន្ទីរសុខ ស-២១ហ្នឹង ការនាំប្រពន្ធគាត់ទៅកម្ទេច ទៅសម្លាប់ហ្នឹង សម្លាប់នៅឯណា? នៅជុំវិញបរិវេណនៃមន្ទីរសន្តិសុខមជ្ឈមណ្ឌលស-២១ មជ្ឈមណ្ឌលភ្នំពេញ ឬក៏នាំទៅសម្លាប់នៅវាលពិឃាតជើងឯក?

[១៥:៣០:២២]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! សូមអរគុណលោកប្រធានអនុញ្ញាត ឲ្យខ្ញុំឆ្លើយសំណួរនេះ ។ ជម្រាបប្រសាសន៍លោក ម៉េង ចំពោះរូបលោកម្នាក់ខ្ញុំក្តុកក្តួលណាស់ យើងធ្លាប់រស់នៅជាមួយគ្នា សុខភាពលោកល្អ ខ្ញុំតក់ស្លុតណាស់ នៅពេលដែលជួបលោកពីអង្កាល់ថ្ងៃ២៨ កុម្ភៈ ២០០៨ នៅមុខលោកចៅក្រមស៊ើបអង្កេត ។ ខ្ញុំចង់បំពេញបំណងរបស់លោកឲ្យច្បាស់ ក៏ប៉ុន្តែវាហួសសមត្ថភាពខ្ញុំ ។ ការងារជាក់ស្តែងបែបនេះ គេអ្នកធ្វើខាងក្រោម ។ ក៏ប៉ុន្តែ ខ្ញុំសុំសន្និដ្ឋានជូនលោកថា ប្រពន្ធលោកប្រហែលជាអាចទៅឯបឹងជើងឯកឯណោះ នេះគឺខ្ញុំសុំសន្និដ្ឋានប៉ុណ្ណឹង ។ ទន្ទឹមនេះខ្ញុំក៏ចង់ឲ្យកាន់តែច្បាស់ទៅទៀត សុំអង្វរកចិត្តលោកសាយសេចក្តីមេត្តាដល់ មិត្តហ៊ុយ ទៅសួរវា បើសិនជាវាអាចជួយលោកប្រហែលជាមានប្រសិទ្ធភាពជាងខ្ញុំនេះខ្ញុំសុំជម្រាបប៉ុណ្ណឹង ។ សូមលោកមេត្តាទទួលនូវសេចក្តីគោរពរបស់ខ្ញុំចំពោះវិញ្ញាណក្ខន្ធប្រពន្ធលោក ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទសូមជួយពង្រឹងនូវស្មារតីឲ្យបានរឹង នឹងនហើយរំងាប់អារម្មណ៍។ ឥឡូវនេះ វាដូចគ្នាទាំងអ្នករស់រានមានជីវិត ទាំងជនជាប់ចោទសុទ្ធតែមានការរន្ធត់នៅពេលដែលស្តាប់នូវព័ត៌មាននូវសក្ខីកម្មនានា ដែលឆ្លុះបញ្ចាំងពីអតីតកាល ។

អ៊ីចឹងអ៊ំ ប៊ូ ម៉េង ច្បាស់ហើយថា ទីមួយ គឺប្រពន្ធរបស់អ៊ំហ្នឹង គឺមិនច្បាស់លាស់ទេ គ្រាន់តែការសន្និដ្ឋានហ្នឹង គឺភាគច្រើនប្រហែលជាយកទៅសម្លាប់នៅឯវាលពិឃាតជើងឯកឯណោះ។ អានេះដោយសារការអំឡុងពេលទេ ដោយសារការចូលទៅតំបន់ហ្នឹងដល់ ហ្នឹងគឺក្នុងអំឡុង១៩៧៧ ដែលមានការវិវឌ្ឍន៍នៃដំណើរការសវនាការកន្លងមកនេះ គឺដំបូងឡើយ ដើមដំបូងគឺបានប្រព្រឹត្តក្នុងបរិវេណមន្ទីរសន្តិសុខស-២១ គុកទួលស្លែង ហើយក្រោយមកបានរាលដាលនៅ ក្នុងបរិវេណនៃតំបន់ជុំវិញទួលស្លែង

មជ្ឈមណ្ឌលស-២១ មជ្ឈមណ្ឌលភ្នំពេញនេះ ។ ហើយក្រោយមកទៀត ក្នុងអំឡុងពេល ៧៧-៧៨ នេះ គឺបានវិវឌ្ឍន៍នៃការផ្លាស់ប្តូរទីកន្លែងនេះទៅសម្លាប់នៅវាល ពិឃាតជើងឯក។

អ៊ីចឹងតាមការសន្និដ្ឋាននេះវាសមរម្យមួយគ្រាន់ថា កាលប្បវត្តិកាលៈទេសៈហ្នឹង គឺដល់ដំណាក់កាលដែលត្រូវប្តូរទីកន្លែងកម្ទេចហ្នឹងទៅជើងឯក ។ នេះតាមលទ្ធផលនៃការស្តាប់សក្ខីកម្មនានា តាំងពីធ្វើ តាំងពីបើកសវនាការរហូតដល់ពេលនេះ យើងទទួលព័ត៌មានប៉ុណ្ណេះ។ ហើយប្រហែលជាតាមការដែលចង់បានជាក់លាក់ច្បាស់លាស់នោះប្រហែលជាពិបាករកក្នុងការច្បាស់លាស់ ដោយសារហេតុជនរងគ្រោះដែលត្រូវសម្លាប់នោះគឺ អស់ជាងមួយម៉ឺននាក់ មួយម៉ឺនពីរពាន់ប្រាំបីរយជាងនាក់ គ្រាន់តែអ្នកដែលបានចុះបញ្ជីទេ ហើយអ្នកដែលអត់ចុះបញ្ជី ហើយនិងកុមារគឺមានចំនួនច្រើនទៀត ។

អ៊ីចឹង ហើយបានជាយើងប្រើភាសាមួយថា យ៉ាងតិចបំផុតគឺប្រហែលហ្នឹង ។ ហើយពីដើមឡើយគឺ មួយម៉ឺនបីពាន់ពីររយប៉ែតសិបប្រាំពីរ (១៣.២៨៧) ។ ប៉ុន្តែក្រោយមក គឺដោយសារមានការត្រួតពិនិត្យបញ្ជីឡើងវិញ មានបញ្ជីដែលសរសេរត្រួតគ្នារហូតដល់ទៅ១០៧ នាក់ អ៊ីចឹងហើយបានមានការដកទៅ គឺមានការថយ ចុះមកនៅត្រឹមមួយពាន់ពីររយជាង ។ នេះគឺជាចំនួនតិចបំផុត គឺមួយម៉ឺនពីរពាន់ជាង គឺចំនួនតិចបំផុត ប៉ុន្តែចំនួនអាចមានច្រើនជាងនេះ ។

ជាបន្តនេះជនជាប់ចោទ ក្រៅពីភាសាអំមិញដែលលោកបាននិយាយតប ឆ្លើយតបទៅនឹងអ៊ំ ប៊ូ ម៉េង ដែលជាអ្នករស់រានមានជីវិតគាត់ ហើយទទួលប្រពន្ធគាត់បានត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ សំណួរអង្គជំនុំជម្រះសួរថា តើក្រៅពីចំណុចនេះជនជាប់ចោទមានអ្វីធ្វើការកត់សម្គាល់ ឬក៏ចាប់អារម្មណ៍នូវការផ្តល់សក្ខីកម្ម សេចក្តីថ្លែងការណ៍របស់អ៊ំ ប៊ូ ម៉េង ក្នុងអំឡុងពេលកន្លងមកដែរឬទេ? បើមានការកត់សម្គាល់អង្គជំនុំជម្រះអនុញ្ញាត ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ដំបូងខ្ញុំសូមបញ្ជាក់ជូនលោក ប៊ូ ម៉េង ម្នាក់ក៏ដូចជាបញ្ជាក់ជូនជនរងគ្រោះទាំងអស់ ។ លោក ប៊ូ ម៉េង ចេះតែចោទបញ្ហាថាតើខ្ញុំខុសអី? ប្រពន្ធខ្ញុំខុសអី? នេះវាជាបញ្ហា ដែលខ្ញុំត្រូវតែបញ្ជាក់ដោយស្មោះត្រង់។

ជំនាន់នោះខ្ញុំបានឆ្លើយជម្រាបបងម៉ី ម្សិលមិញហើយ បញ្ហានេះអ្នកណាដែលប្រឆាំងនឹងគេ គេរើសឈ្មោះដាក់ *សេអ៊ីអា, កាហ្សេបេ* ភ្ជាក់ងារយួនលេបទឹកដីប្រល័យពូជសាសន៍តាមតែគោលបំណងរបស់គេ នេះខ្ញុំសូមបញ្ជាក់សាឡើងវិញប៉ុណ្ណេះ។ ដើម្បីឲ្យកាន់តែច្បាស់ទៅទៀត ខ្ញុំសូមជម្រាបថា

សម័យមហាបដិវត្តន៍វប្បធម៌ប្រទេសចិន គេចោទប្រកាន់អ្នកនេះមាន គំនិតដូច *លើនពីអូ* នេះកាលជំនាន់ពួកអាក្រុមបួននាក់។ ដូច្នេះ ខ្មែរយើងមិនយកតាមនោះទេ ប៉ុល ពត គាត់ដើរតួទៅផ្សេងទៅ ប៉ុន្តែទិសដៅកម្ទេចអ្នកប្រឆាំងដូចគ្នា ។ សរុបមកអាមនុស្សបែបនេះ ចុងបំផុត តើទៅជាអ្វី? ខ្ញុំបានជម្រាបជូនបងម៉ី ម្សិលមិញហើយ បងម៉ី គាត់សួរខ្ញុំថា តើអស់ហើយឬនៅ *សេអ៊ីអា, កាហ្សេបេ* នោះ?

[១៥:៣៧:៣៤]

ខ្ញុំឆ្លើយជម្រាប បងម៉ី ថា គឺអ្នកប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា អ្នកប្រឆាំងនឹង ប៉ុល ពត នេះឯង ដែលវៃវំលំ ប៉ុល ពត ឲ្យប៉ើងខ្ចាយពីភ្នំពេញនៅល្ងាចថ្ងៃ៦ មករា ១៩៧៩ ហើយរហូតចុងបញ្ចប់នៃជីវិតនយោបាយមួយដែលហ្វាស៊ីស គឺវាចប់នៅថ្ងៃ៦ មីនា ១៩៩៩ ។ ដូច្នេះ អាការចេះតែដើរចោទប្រកាន់ប្រជាជនខ្លួនឯងហ្នឹង ដែលធ្វើឲ្យបក្សកុម្មុយនីស្តអន្តរាយ លុះដល់ទីបញ្ចប់វាលេចទៅជារូបភាពកាប់ចាក់គ្នាឯងក្នុងចំណោមអ្នកដឹកនាំ។

នេះខ្ញុំសូមបញ្ជាក់ ជូនជាតិប្រជាជនកម្ពុជាថា ឧក្រិដ្ឋកម្មនេះធ្ងន់ធ្ងរណាស់ វាជាឧក្រិដ្ឋកម្មរបស់អ្នកខាងលើក៏ពិតមែន ក៏ប៉ុន្តែ កម្លាំងអ្នកខាងក្រោមដែលជាបក្ខជនវានៅមានក្នុងនុ៎ង ក្នុងទូទាំងប្រទេសមនុស្សអស់ជាងមួយលាននាក់ ។ ខ្ញុំក្នុងឋានៈជាបក្ខជនមួយរូបខ្ញុំអត់គេចទេ សុំទទួលខុសត្រូវចំពោះខាងផ្លូវចិត្តចំពោះវិញ្ញាណក្ខន្ធទាំងអស់ ។

ដោយឡែកនៅមន្ទីរស-២១ ជីវិតមនុស្សជាងមួយម៉ឺននាក់ ខ្ញុំទទួលខុសត្រូវខាងផ្លូវច្បាប់ ឱនក្បាលជូន អ.វ.ត.ក ជំនុំជម្រះខ្ញុំតែម្នាក់ឯង ក្នុងក្របខ័ណ្ឌមន្ទីរស-២១ គ្មានឲ្យទាក់ទងដល់កូនចៅណាទេ ។ នេះខ្ញុំទទួលប៉ុណ្ណឹងទាំងស្រុង ។

ហើយវិញ្ញាណក្ខន្ធអ្នកទាំងអស់នោះបានអធិដ្ឋានជូនគេជាប់លាប់ជាប្រចាំខ្ញុំអត់ភ្លេចទេ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។ និយាយនេះ ដើម្បីមិនមែនគេចកែអំពីទារុណកម្ម អំពីឧក្រិដ្ឋកម្មរបស់ខ្លួនទេ និយាយលាតត្រដាងឲ្យវាឃើញថា ទទួលស្គាល់ឧក្រិដ្ឋកម្មត្រឹមកម្រិតណា? ហើយនេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះសូមប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរសំណួរដល់អ៊ំ ប៊ូ ម៉េង ដែលជាអ្នករស់រានមានជីវិតនៅមន្ទីរសន្តិសុខស-២១ មួយរូបក្នុងចំណោមអ្នករស់រានមានជីវិតដទៃទៀត។ សូមអញ្ជើញលោកមេធាវីការពារក្តី បើសិនជាមានសំណួរ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោក លោកស្រីចៅក្រម ទាំងអស់ជាទីគោរព ។ សំណួររបស់ខ្ញុំគឺសុំឲ្យលោក ប៊ូ ម៉េង បញ្ជាក់ពីព្រោះការឆ្លើយរបស់លោក ខ្ញុំស្តាប់ទៅកន្លែងខ្លះហាក់ដូចជាមិនទាន់ច្បាស់ ខ្ញុំមិនទាន់ច្បាស់ ។ ពេលលោកជាប់នៅស-២១ តើមានឮសូរសំឡេងស្រែក សំឡេងយំមែនឬទេ? ពីព្រោះដល់ពេលជិតបញ្ចប់ព្រឹកមិញនេះ ជិតបញ្ចប់លោកបានថា ណែនៗបន្ទប់ មនុស្សទាំងអស់ហ្នឹងពេញៗអគារ គឺស្ងាត់ឈឹងអត់មានអ្នកណាប៉ានមាត់ ប៉ានកអីទេ តែខ្សឹបគ្នាហ្នឹងមិនប៉ានឲ្យឮផង ។ អ៊ីចឹងវាហាក់ដូចជាចម្លើយរបស់លោកពីព្រឹក និងជិតថ្ងៃត្រង់ហ្នឹងហាក់ដូចជាផ្ទុយគ្នា ។ នេះសូមលោកបញ្ជាក់ឡើងវិញ តើវាយ៉ាងម៉េចចម្លើយរបស់លោកទាំងពីរហ្នឹង?

[១៥:៤១:២៥]

**ឆ៖** ខ្ញុំសូមឆ្លើយបញ្ជាក់ប្រាប់លោកមេធាវីការពារក្តី ។ ពាក្យថាស្ងាត់ជ្រងំហ្នឹង ត្រង់ថា គេបិទទ្វារជិតអាពេលគេជម្លៀសខ្ញុំចេញនេះ ខ្ញុំមិនអាចនឹងប៉ានមើលតាមបន្ទប់ទេ បើមិនអ៊ីចឹងទេកាំភ្លើងនៅលើស្មាគេ ដឹងគេយ៉ាងម៉េច? ខ្ញុំជាខ្មាំង ខ្ញុំជាជនរងគ្រោះ អ៊ីចឹងខ្ញុំនិយាយថាឃើញយ៉ាងម៉េច? ហើយពេលដែលខ្ញុំឮ ខ្ញុំឮនឹងត្រចៀកពិតប្រាកដមែន ។ ការស្រែក ទោះបីបិទទ្វារយ៉ាងម៉េចក៏នៅតែឮដែរ ។ ស្រែកមិនឮម៉េច បើគេវៃជិតងាប់ហើយ រឿងអីមិនស្រែក? ស្រែកឡើងរំពងចង់បែកក្រដាសត្រចៀកកាលនោះត្រចៀកខ្ញុំមិនមែនអន់អ៊ីចឹងណា! ត្រចៀកខ្ញុំនៅខ្លាំង ភ្នែកខ្ញុំនៅខ្លាំងណាស់។ ភ្នែកមនុស្សខ្ញុំគ្រាន់តែមើលអ៊ីចឹងខ្ញុំគួរដូច មិននិយាយអួតទេ បើមិនជឿសួរលោកឌុច ទៅ! កូនក្តីរបស់លោកស្រាប់ហើយ ។ យោបល់របស់ខ្ញុំចប់ត្រឹមហ្នឹង ។

**ស៖** សូមអរគុណ សូមលោកបញ្ជាក់ឡើងវិញ ពីព្រោះព្រឹកមិញអាជិតថ្ងៃត្រង់នេះ លោកថាណែនៗពេញអគារ មនុស្សពេញអគារ មិនមែនពេលលោករត់ទេ? ពេលលោករត់វាអស់មនុស្សទៅហើយ ។ អាពេលថាពេញៗអគារមនុស្សពេញអគារនេះ ឲ្យស្ងាត់ឈឹងអត់មានអ្នកណាប៉ានមាត់ ប៉ានស្រែកអីទេ ពេលដែលសួរគ្នាក៏អត់ប៉ានសួរខ្លាំងសុទ្ធតែខ្សឹបហ្នឹងខ្លាចអាអ្នកដើរឮទៀតនេះ ។ ហើយចុះហេតុអីលោកពីព្រឹកស្រែកថា វាមានឮសូរសំឡេងស្រែក សំឡេងយំ វាហាក់ដូចជាផ្ទុយគ្នា ។ អ៊ីចឹងបានខ្ញុំចង់ឲ្យលោកបញ្ជាក់ហ្នឹង មិនមែនឲ្យបញ្ជាក់អារៀបចេញទៅទេ ។

**ឆ៖** សូមបញ្ជាក់ប្រាប់លោកមេធាវីការពារក្តី។ រឿងនេះខ្ញុំចង់បញ្ជាក់និយាយប្រាប់អ៊ីចេះ ពេលដែលខ្ញុំនៅក្នុងមន្ទីរឃុំឃាំង ខ្ញុំឮសំឡេងស្រែកអ៊ីចឹងមែន ជុំវិញហ្នឹងសុទ្ធតែផ្ទះវៃសួរចម្លើយអ្នកទោស ។

ហើយអ្នកទោសនៅក្នុងអគារហ្នឹងមិនឲ្យមានសំឡេងស្រែកមែន តែអាណាប៊ានគឺគេធ្វើទារុណកម្ម ហើយគេវ៉ៃហើយ ។ ប៉ុនដល់គេយកទៅវ៉ៃសួរចម្លើយនៅខាងក្រៅគេបិទទ្វារ គេវ៉ៃ អ្នកស្រែកចេះតែស្រែកចេះតែឮសូរអ៊ីចឹង ។ អាហ្នឹងខ្ញុំឮតាមត្រចៀកខ្ញុំឮសូរទេ ។ មិនមែនខ្ញុំចង់ដាក់ទម្ងន់ទៅលើលោកណាក៏ខ្ញុំមិនទេ ខ្ញុំនិយាយតាមភាពយុត្តិធម៌ ។ មានអ្នកតាដំបងដែកជាប្រធាន បើខ្ញុំនិយាយមិនពិត ចេញទៅឡានបុកងាប់ទៅ ។

[១៥:៤៤:១៥]

**ស៖** សូមអរគុណ ខ្ញុំគ្រាន់តែចង់ដឹងសូមឲ្យលោកបញ្ជាក់ដើម្បីឲ្យបានច្បាស់ប៉ុណ្ណោះទេ។ ទីពីរក៏សុំឲ្យលោកបញ្ជាក់ដែរ លោកថា ពួកកូនចៅ តាឌុច ពេលទ័ពវៀតណាមដែលភូតភរថាចេះសូនរូបម្តង លោកថា តាឌុច បញ្ជាឲ្យទាត់ ស៊ិតម្នាក់មួយជើង ។ ដល់លោកប្រធានសួរបញ្ជាក់ម្តងទៀត លោកថា តាឌុចអត់បានបញ្ជាទេ តាឌុច ទៅបាត់ទៅហើយ។ អ៊ីចឹង សូមលោកបញ្ជាក់ឡើងវិញ តើ តាឌុច បានបញ្ជាឲ្យគេទាត់ ឬក៏អត់ដែលពិតប្រាកដនោះ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវីការពារក្តី! ពីព្រោះថាការដែលខ្ញុំនិយាយមានការភ្លេចភ្លាំងក៏មូលហេតុមកពីទារុណកម្មហ្នឹង វាធ្ងន់ធ្ងរពេក ។ ខ្ញុំនិយាយ មិនមែននិយាយបង្វែះបង្វៀងពាក្យសម្តីរបស់ខ្លួនទេ បើលោកឮយ៉ាងណាគឺវាយ៉ាងនោះហើយ ។ ប៉ុន្តែ ការភ្លេចភ្លាំងរបស់ខ្ញុំ វាជារឿងធម្មតា មនុស្សទទួលទារុណកម្មធ្ងន់ធ្ងរ វាតែងតែភ្លេចភ្លាំង ស្មារតីមិនពេញលេញទេ ដប់ភាគរយនៅសល់តែប្រាំមួយភាគរយអីប៉ុននុ៎ង ។ ហ្នឹងផ្នែកអារម្មណ៍របស់ខ្ញុំ វាទ្រុឌទ្រោមតាំងពីរាងកាយឡើង ខូចអស់ហើយ សុខភាពផ្លូវចិត្តក៏ដោយ ផ្លូវកាយក៏ដោយវាខ្ទេចខ្ទាំអស់ហើយ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំៗម៉េង អ៊ំធ្វើអារម្មណ៍ឲ្យនឹងន អ៊ំអាចមានការលំបាកដែរ ដោយសារមានមនុស្សច្រើននាក់សួរអ៊ំ តែម្នាក់ ហើយអំឡុងពេលនៃការសួរសំណួរហ្នឹង គឺពេលមួយថ្ងៃហើយ ។ អ៊ីចឹងជាការលំបាកដែរ ប៉ុន្តែនៅអំឡុងពេលខ្លីដែរទេ អ៊ំ ។ អ៊ីចឹង អ៊ំធ្វើការសម្របសម្រួលអារម្មណ៍ឡើងវិញ ។ ហើយនៅក្នុងសំណួរនេះជាការបញ្ជាក់មានអត្ថន័យថា តើអ៊ំបានឮ ឌុច ដែលជាជនជាប់ហ្នឹង បញ្ជាឲ្យកូនចៅរបស់គាត់ បញ្ជាអ្នកក្រោមឱវាទរបស់គាត់ឲ្យវាយទៅលើជនជាតិវៀតណាមម្នាក់ ឬក៏អ្នកខ្លះថាជាខ្មែរកម្ពុជាក្រោមម្នាក់ដែលអះអាងថាខ្លួនជាវិចិត្រករ ហើយចេះគូរ ចេះសូនរូបនោះ ហើយធ្វើមិនកើត ថាតើគាត់ ឌុច បញ្ជាឲ្យវ៉ៃ ឬក៏អត់ទេ? បានន័យថា ឌុច ចាកចេញទៅហើយ ទើបកូនចៅក្រោម

ឱវាទដែលនាំមនុស្សហ្នឹងមកហ្នឹង គឺធ្វើដោយចិត្តឯង ។ វាមានលក្ខណៈខុសគ្នាបន្តិចទេ ថាមួយមានការបញ្ជា ឬក៏មួយគឺអ្នកនាំមកទុំង គឺមុននាំទៅវិញ គេធ្វើទារុណកម្ម គេវ៉ៃដំទៅលើមនុស្សនោះដោយខ្លួនឯង តែប៉ុណ្ណឹងទេ ។ អ៊ីចឹង មានសំណួរតែពីរទេ អាចជ្រើសរើសមួយណាដែលជាក់លាក់ ។

[១៥:៤៧:២៧]

**ឆ៖** អានេះវាមិនឃើញ សូមជម្រាបប្រសាសន៍លោកចៅក្រម ខ្ញុំវាមិនឃើញ ហើយក៏មិនឮនឹងត្រចៀក ដល់អ៊ីចឹងខ្ញុំមិនសន្និដ្ឋានថា គាត់បញ្ជា ឬក៏មួយគាត់មិនបញ្ជា ឬក៏កូនចៅគាត់ធ្វើដោយខ្លួនគាត់ ក៏មិនដឹងដែរ ។ អាហ្នឹងខ្ញុំចង់និយាយអ៊ីចេះ ធម្មតាបើគ្មានបញ្ជាពីមេកើយ ពីម៉ែឪ គឺកូនហ្នឹងមិនប៊ានទេ ពួកហ្នឹងខ្លាចណាស់ ។ បើពួកគ្នាគាត់ជាប់គុក ខ្ញុំឃើញទទួលភ្ជួយ អត់ឲ្យអ្នកធ្វើការនៅក្នុងទុំងដឹងស្គាល់ថាមិត្ត“ក” ឬ មិត្ត “ខ” ទេ ។ ឃើញតែជើង ឃើញតែត្រឹមគន្លាក់អាចម៍ចុះក្រោម ទទួលភ្ជួយធំគ្របជិតស្អុប នេះបណ្តើរកាត់តាមហ្នឹង ។ អាហ្នឹងខ្ញុំជឿថា ប្រហែលជាគ្នាគាត់ក៏មិនដឹង ។ អានេះគ្រាន់តែសន្និដ្ឋានរបស់ខ្ញុំ ក៏មិនដឹងច្បាស់ទេ ពីព្រោះរឿងរបស់ខាងលើក្រែងខាងលើគេសារភាព គេនិយាយយ៉ាងម៉េច អាហ្នឹងជារឿងរបស់គេទេ ។ តែតាមសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំឃើញអ៊ីចឹង ។

**ស៖** អ៊ំ អ៊ីចេះអ៊ំណា អាបញ្ហានេះអ៊ំអាចមានការច្រលំបន្តិច ក្នុងនាមអ៊ំជាអ្នករស់រានមានជីវិត ការដែលសួរនេះគឺ ព័ត៌មានដែលអ៊ំឆ្លើយ ទីមួយ គឺឆ្លុះបញ្ចាំងអំពីជីវិតរបស់អ៊ំដែលទុក្ខសោកវេទនារបស់អ៊ំ ហើយនិងតំណាងឲ្យប្រពន្ធរបស់អ៊ំ ជំនួសឲ្យគ្រួសាររបស់អ៊ំ រឿងតតាំងអំពីរឿងហេតុដែលប្រព្រឹត្តកម្មទៅលើប្រពន្ធរបស់អ៊ំ ។ ប៉ុន្តែឥឡូវនេះ ព័ត៌មានសួរទាក់ទិនជាមួយនឹងរឿងពិតប្រាកដថាកើតមាននៅទីទុំង វាមានរឿងផ្សេងទៀត វាទាក់ទិន្នជាមួយនឹងជនជាប់ចោទ ។ អ៊ីចឹង បញ្ហាអង្គសវនាការ មិនចង់បាន ឬក៏ជាសាក្សីមិនអាចឆ្លើយបែបសន្និដ្ឋានបានទេ ។ ការសន្និដ្ឋានជាភាគី ហើយសន្និដ្ឋានចុងក្រោយវិភាគសម្រេចត្រឹមត្រូវ ឬមិនត្រូវ គឺជារឿងរបស់អង្គជំនុំជម្រះ ។ អ៊ីចឹង គឺក្នុងនាមជាសាក្សីគឺគ្រាន់បើគេសួរថា ឃើញពិត ឬក៏មិនពិត គឺឆ្លើយឲ្យបានច្បាស់លាស់តែប៉ុណ្ណឹង មិនអាចយកសន្និដ្ឋានទេ ។ អ៊ំយល់ទេ? អត់ឲ្យសន្និដ្ឋានទេ បើអ៊ំថាមិនដឹង គឺមិនដឹងទេ ។ បើអ៊ំដឹង អាហ្នឹងអ៊ំឆ្លើយថាដឹងអ៊ីចឹង មិនអាចធ្វើសន្នដ្ឋានទេ ព្រោះសន្និដ្ឋានមិនមែនសម្រាប់តួសាក្សីសម្រាប់ធ្វើទេ ។

**ឆ៖** អ៊ីចឹងពេលហ្នឹងក៏ខ្ញុំមិនបានច្បាស់លាស់ដែរ ខ្ញុំឆ្លើយថាខ្ញុំមិនបានដឹងទេ ប៉ុន្តែឃើញៗទាត់ធាក់អ៊ីចឹងមែន ។ ប៉ុន្តែគ្រាន់តែបញ្ជាពីណា ឬក៏គេធ្វើខ្លួនគេថា អ្នកធ្វើទារុណកម្មហ្នឹង អាហ្នឹងក៏ខ្ញុំមិនដឹងដែរ ។ នេះខ្ញុំសូមអគុណ ឆ្លើយប៉ុណ្ណឹង ។

[១៥:៥០:២៤]

**ប្រធានអង្គជំនុំ៖**

សូមមេធាវីបន្តសំណួរផ្សេងទៀត សំណួរនេះ គឺមិនបាច់សួរទៀតទេ ចម្លើយប៉ុណ្ណេះសមរម្យអាចទទួលយកបានហើយ ។

**សួរដោយ លោក ការ សាវុត្ថ៖**

**ស៖** សូមអរគុណលោក ប៊ូ ម៉េង ។ សំណួរទីបី ពេលចាប់លោកពីសហករណ៍មកទាំងប្ដីទាំងប្រពន្ធលោកមកស-២១ មកដាក់នៅផ្ទះឈើមុខ ស-២១ ។ តើមានដាក់ខ្នោះជើង ឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវីការពារក្ដី គឺពេលនោះ គេធ្វើនយោបាយជាមួយនឹងខ្ញុំល្អណាស់ ។ អ្នកដែលគេយកខ្ញុំមកចាប់ខ្ញុំមក គឺគេចាប់ដោយត្រជាក់ វិធីត្រជាក់ ។ បានថាត្រជាក់ ខ្ញុំនិយាយលើកឡើងថា វាគ្មានខ្នោះ វាគ្មានច្រវាក់ចងអីខ្ញុំទេ។ និយាយភរខ្ញុំអ៊ីចេះ បានខ្ញុំថាភរពីព្រោះវាមិនឃើញបានទៅសាលារចនាឯណា បែរជាសាលារចនាទួលស្លែង គុកទួលស្លែងទៅវិញ។ អាហ្នឹងហើយដែលថាភរខ្ញុំ ។ អ៊ីចឹង បានថាពាក្យដែលភរខ្ញុំ គេចាប់ស្រួលណាស់ ។ ខ្ញុំឡើងជិះឡានដោយខ្លួនឯង ដោយគេថា នំ! ឡើងជិះឡានទៅសាលារចនាទៅធ្វើការនៅនុំងពីរនាក់ប្ដីប្រពន្ធ ។ វាមិនចូលទួលស្លែង ចូលគុកទួលស្លែង ។ អើ! មិនចូលសាលារចនា ចូលគុគទួលស្លែងវិញ ន៎ែ! អាហ្នឹងហើយដែលខ្ញុំចោទថា ភរខ្ញុំពីសម័យនុំង ។

**ស៖** សូមអរគុណ ។ បានជាខ្ញុំសួរលោកឲ្យលោកបញ្ជាក់ហ្នឹង ពីព្រោះចម្លើយរបស់លោកនៅសហព្រះរាជអាជ្ញាកាលពីថ្ងៃទី២៩ ខែ៨ ឆ្នាំ២០០៦ នេះនៅក្នុងឯកសារ ERN00145528 ដល់ 00145538 លោកបានបញ្ជាក់ថាមានការដាក់ខ្នោះទាំងប្ដីទាំងប្រពន្ធទាំងជើងទាំងដៃ ។ ហើយមកដល់ព្រឹកនេះ ឮថាដាក់ខ្នោះតែដៃទេ អត់មានដាក់ជើងទេ ។ អ៊ីចឹង បានជាខ្ញុំសូមសួរបញ្ជាក់លោកក្រែងលោលោកភ្លេចភ្លាំង ពីព្រោះថាធម្មតាដូចលោកមានប្រសាសន៍អំមិញអ៊ីចឹងថា ចាស់ហើយ ហើយទៅទទួលរងទារុណកម្មច្រើន វាមានការភ្លេចភ្លាំង ពីព្រោះការភ្លេចនេះវាមិនមែនតែលោកទេ អ្នកណាក៏ចេះភ្លេច លើកលែងតែអទិទេពទេដែលមិនចេះភ្លេច ឲ្យមនុស្សលោកអ្នកណាក៏ចេះតែភ្លេចដែរ ។ ហ្នឹងបានជាខ្ញុំសួរឲ្យលោកបញ្ជាក់ ។ សូមអរគុណ ។

សំណួរទីបួន ចម្លើយនៅសហព្រះរាជអាជ្ញា លោកថា “តែក្រោយមកទើបខ្ញុំដឹងថា ដឹកទៅសម្លាប់ចោលនៅជើងឯក គេដឹករាល់ថ្ងៃទាំងយប់ទាំងថ្ងៃ ។ នេះ! គេដឹកទាំងយប់ទាំងថ្ងៃ ។” តើលោក

នៅរក្សាចម្លើយនេះដដែល ឬយ៉ាងណា?

[១៥:៥៤:១៧]

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវីការពារក្តី! ពេលដែលថាដឹកចេញដឹកចូល ខ្ញុំនិយាយ ប៉ុន្តែដឹកយកទៅសម្លាប់នោះខ្ញុំមិននិយាយទេ ។ ខ្ញុំគ្រាន់តែឡានចេញឡានចូល ដឹកចេញដឹកចូល ប៉ុន្តែមិនដឹងយកទៅណា អាហ្នឹងខ្ញុំនិយាយមែន ។ ត្រង់ថា យកទៅសម្លាប់ យកទៅកម្ទេច ខ្ញុំអត់ដែលនិយាយទេ ។

**លោក ហុង គីមសួន៖**

សូមៗឲ្យលោកមេធាវីជួយបញ្ជាក់លេខ ERN ឬក៏លេខឯកសារឲ្យយើងទាំងអស់គ្នាបានចាប់ទាន់ផង ។

**លោក ការ សាវុត្ថ៖**

**ស៖** លេខឯកសារ ERN 00145533 បន្ទាត់ទីបួនពីក្រោមឡើងលើៗ ។ ឃើញថា "តែក្រោយមកទើបគេមានប្រាប់គាត់(ខ្សឹបប្រាប់គាត់) តែក្រោយមកទើបខ្ញុំដឹងថា ដឹកទៅសម្លាប់ចោលនៅជើងឯក គេដឹករាល់ថ្ងៃ (ដឹង) គេដឹករាល់ថ្ងៃទាំងយប់ទាំងថ្ងៃ" តែប៉ុណ្ណឹងទេ ។ អ៊ីចឹង បានខ្ញុំសូមឲ្យ-- តើលោកនៅរក្សាចម្លើយនេះនៅដដែល ឬយ៉ាងណា? មូលហេតុដែលខ្ញុំសួរនេះ ពីព្រោះមានសាក្សីមួយចំនួនថាដឹកតែយប់ៗទេ ថ្ងៃគេមិនដែលដឹកទេ ។ ន៎! ខ្ញុំចង់អ៊ីចឹង វាខ្វែងគំនិតគ្នា ។ សូមអរគុណ ។

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោក ពីព្រោះអារឿងដែលខ្ញុំវាជាប់នៅលើអគារ "គ" ហ្នឹង នៅជាន់ខាងលើហ្នឹង ខ្ញុំឮសូរសំឡេងឡានទាំងយប់ទាំងថ្ងៃ ប៉ុន្តែ ត្រង់តែថាអ្នកដែលគេដឹង គេឆ្លើយយ៉ាងណា អាហ្នឹងត្រចៀករបស់គេឮ តែត្រចៀករបស់ខ្ញុំ គឺខ្ញុំឮអ៊ីចឹង ។ ពីព្រោះឡាននឹងមានចេញចូល តែមិនដឹងដឹកមនុស្សទៅណា យកទៅណា ខ្ញុំគ្រាន់តែឮសូរទេ ត្រចៀកឮសូរ ។ ប៉ុន្តែគ្រាន់ឃើញឡានហ្នឹង មិនឃើញទេ ប៉ុន្តែដឹកថាឡានឈប់នៅមាត់ច្រកហ្នឹង នៅក្បែរមាត់ច្រកនៅខាងកើតគុកទួលស្លែងហ្នឹង ។ ខាងកើតទេ ខាងលិច? ។ ធ្វើការនឹងមួយរយៈមិនដឹងថា បែរមុខទៅណាទៀត គុកទួលស្លែង វាវង្វេង ជើង ត្បូង កើត លិច ។ នៅផ្លូវខាងមុខផ្ទះឈើហ្នឹង ឈប់ហ្នឹង ខាងជើងដែលខ្ញុំមកចូលដល់គុកទួលស្លែងដំបូង ខ្ញុំចូលផ្ទះឈើហ្នឹងហើយគេដាក់ខ្នោះនៅនឹងផ្លូវហ្នឹង (ស្តាប់មិនច្បាស់) អត់ឮសូរចេញចូលនៅឈប់តែហ្នឹងមែនឡាន ។ ត្រង់ថាដឹកមនុស្សយកទៅវាយចោល ដឹកមនុស្សមកចូលគុក អាហ្នឹងវាមិនដឹងទេ គ្រាន់តែឮសំឡេងឡានចុះឡើង ឮអ៊ីចឹងមែន ។

[១៥:៥៧:២៥]

**ស៖** សូមអរគុណ ខ្ញុំចង់ឲ្យលោកបញ្ជាក់កន្លែងហ្នឹងទេ ។ សំណួរទីប្រាំ ពេលចេញពីស-២១ ចេញទៅជាមួយលោក វ៉ាន់ ណាត, លោក ជុំ ម៉ី ដែរឬទេ? ដែលលោកចេញទៅពី ស-២១ លោកចេញទៅអ្នកណាខ្លះជាមួយលោក?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវីការពារក្តី គឺបានទៅចេញទៅអ្នកដែលរស់រានមានជីវិតទាំងប៉ុន្មាននៅធ្វើការនៅកន្លែងគូររូបហ្នឹង ជាងចម្លាក់ក្តី ខ្ញុំក្តី ជាងគំនូរ វាមានពីរនាក់ ណាត ហើយខ្ញុំ ។ ខ្ញុំគូរគំនូរស-ខ្មៅ ។ ណាត គូរគំនូរពណ៌ ។ ហើយចំណែក អៀម ចាន់ ហ្នឹង ជាជាងចំលាក់ឈើ ។ ហើយ ជាងទូច គឺជាងសូនរូប ។ គេចេញទាំងអស់គ្នា ។ ផា ថនចាន់ ក៏ចេញ អ៊ឹង ប៊ុច ហ្នឹងក៏ចេញទាំងអស់គ្នាវាមានគ្នា ទាំងអស់ជាងដប់នាក់ ថ្ងៃនុំង ប៉ុន្តែខ្ញុំភ្លេច ។ ប៉ុន្តែ ពួកអស់នុំង ងាប់អស់ហើយមិនឃើញទេ ។ តាទួន តាអីបាត់អស់ហើយ មិនដឹងទៅណាបាត់អស់ទេ ។ តាហ្នឹងធ្វើជាងនាឡិកា ។

អ៊ីចឹងវាការពិតដែលខ្ញុំឃើញដូចខ្ញុំនិយាយហ្នឹង ទៅជាមួយពួកអស់ហ្នឹងអ៊ីចឹងមែន ។ វ៉ាន់ ណាត ក៏មាន ជាមួយនឹងខ្ញុំហ្នឹងដែរ ទៅជាមួយគ្នាហ្នឹង គ្រាន់ថា ទៅដល់ផ្លូវមួយនៅអង្គស្នួលនោះ វាបែកគ្នាចំផ្លូវឆ្លងកាត់ហ្នឹង ផ្លូវជាតិ៤ហ្នឹង វាឮសូរឡានសន្ទឹកកងទ័ពរំដោះរណសិរ្សរួមរួបជាតិកម្ពុជាហ្នឹង គេមករំដោះ គេចូលមកក្រុងភ្នំពេញជួបគ្នាត្រង់ហ្នឹង ក៏វ៉ាកអើត្រង់ហ្នឹង ក៏ពួកដែលនាំខ្ញុំទៅហ្នឹង វារតាត់រតាយបាត់អស់ទៅ ហើយខ្ញុំក៏ចេះតែឆ្លងទៅពីរនាក់កាត់តាមជាតិលេខជាតិ៤ ទៅរហូតដល់អមលាំង កាត់ព្រៃជ្រៅ ។

**ស៖** សូមអរគុណលោក ។ ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ចង់ដឹងថាតើលោកចេញទៅមាន វ៉ាន់ ណាត មាន ជុំ ម៉ី អីទៅជាមួយលោកឬទេ? លោកឆ្លើយថាទៅជាមួយ វ៉ាន់ ណាត ដែរ ។ បើទៅជាមួយ វ៉ាន់ ណាត ដែរ ខ្ញុំសួរតទៅទៀត ។ ខ្ញុំសួរតទៅទៀត ពីព្រោះខ្ញុំសូមឲ្យលោកបញ្ជាក់ទេ ពីព្រោះព្រឹកមិញនេះ លោកថា រត់ពីចេញស-២១ ទៅនេះ ម្តងលោកថា ម៉ោងប្រាំមួយល្ងាច ម្តងទៀតលោកថា ម៉ោងប្រាំបួនព្រឹក ប្រហែលម៉ោងប្រាំបួនព្រឹក។ ហើយអំមិញនេះ កញ្ញាមេធាវី ទី ស្រ៊ុនណា សួរលោកថាទៅយប់ដែរ ម៉ោងប្រាំមួយ ម៉ោងប្រាំពីរយប់ ល្ងាចទៀត ។ ដូច្នេះ តើលោកចេញពីស-២១ នេះម៉ោងប៉ុន្មានពិតប្រាកដខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ?

**ឆ៖** សូមជម្រាបលោកប្រសាសន៍-- ប្រសាសន៍លោកមេធាវីការពារក្តី ចេញពីគុកទួលស្លែងហ្នឹង ពេលម៉ោងប្រាំបួន ម៉ោងប្រាំបួនហ្នឹងគឺចេញពីមន្ទីរកន្លែងគូររូបមែន ។ ចេញទៅគេឲ្យដើរត្រង់ផ្លូវ

កុំឱ្យអាណាងាកចេញពីជួរ តែចេញពីជួរវ៉ៃបាញ់បំបាក់ជើង ហើយខ្លាចណាស់ដើរត្រង់ ដើរតាមគេដល់កន្លែងមួយស្តុកនៅក្នុងផ្ទះមួយនោះមិនដឹងកន្លែងណា ខ្ញុំមិនបានចាំទេ! នៅត្រង់កន្លែងប៉ុស្តិ៍វិទ្យុសំបុកឃ្មុំនុ៎ងមិនដឹងអីមិនដឹង ផ្ទះមួយ ។

**ស៖** បាទៗ សូមអរគុណ ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ។ ចង់ដឹងថា ចេញម៉ោងប៉ុន្មាន? ប៉ុណ្ណឹងទេ ។ ឥឡូវលោកបានប្រាប់ហើយថាម៉ោងប្រាំបួនព្រឹក ។ ឥឡូវសំណួរទីប្រាំពីរ ជាសំណួរចុងក្រោយពេលលោកកំពុងគូររូប តើលោកមានដែលឃើញ ខៀវ សំផន ចូលទៅដែរ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវីការពារក្តី! អារឿង ខៀវ សំផន នេះខ្ញុំមិនដែលឃើញទេ មិនដែលឃើញទៅទេ លោក អស់លោកធំៗហ្នឹង មិនដែលឃើញសោះបាទ ។ សូម្បីតែ-- និយាយទៅវាចូលដល់រូប ប៉ុល ពត ខ្ញុំបានឃើញតែរូបថតទេ តែរូបមែនទែនមិនដែលឃើញទេ ។ មានអ្នកខ្លះថាដែលឃើញទេ? គូររូបថត ប៉ុល ពត ខ្ញុំថា មិនដែលទេ ឃើញតែរូបថតទេ ។ រូបថតនុ៎ងគឺគេយកឱ្យនុ៎ងគឺ ថតនៅស្រុកចិនទៀត ថតនៅ សៀងហៃ ខេត្តសៀងហៃ ប្រទេសចិន ។ គេដាក់ឈ្មោះហាងគេច្បាស់ក្រឡែតនៅនឹងស្រោមរូបថតហ្នឹង ដាក់ថា "ហាងថតរូបរដូវផ្ការីក" នៅខេត្តសៀងហៃ នៅប្រទេសចិនហ្នឹងគេដាក់អ៊ីចឹង ។

**ស៖** សូមអរគុណ ដែលខ្ញុំសួរនេះវាអាចច្រឡំ ។ អ៊ីចឹង លោកពេលដែលលោកកាលនៅសាលាស្ទី? ពហុបច្ចេកទេសនោះ មាន ខៀវ សំផន អញ្ជើញទៅនុ៎ងយ៉ាង?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវីការពារក្តី! បើសួរចំណុចនេះ គឺខ្ញុំនៅចាំ ខ្ញុំនៅធ្វើការកន្លែងនុ៎ង ។ ខ្ញុំកំពុងរៀបទំព័រសៀវភៅឯកសារ ស្រាប់តែលោក ខៀវ សំផន សួរខ្ញុំៗថា មានទូរស័ព្ទទេ? ខ្ញុំថានោះទូរស័ព្ទនៅកៀនជញ្ជាំង ។ ខ្ញុំមិនទាំងដឹងលោក ខៀវ សំផន ផង ប៉ុន្តែ ដល់ចេញទៅមានអ្នកធ្វើការជាមួយខ្ញុំបុគ្គលិកដូចគ្នា គេថាលោក ខៀវ សំផន តើ? បង ខៀវ សំផន តើ? បានខ្ញុំថា អ៎! ខ្ញុំវាស្រពេចស្រពិលត្រង់ហ្នឹង ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេលោកបាទ ។ សូមអស់សំណួរលោកប្រធាន ។

[១៦:០៣:១៥]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តីអន្តរជាតិមានសំណួរអ្វីត្រូវសួរដល់អ៊ំ ប៊ូ ម៉េង ដែរទេ?

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

**ស៖** សូមអរគុណលោកប្រធាន សូមគោរពនិងសួស្ដីលោក ប៊ូ ម៉េង ។ ចៅក្រម ឡាវ៉ែន៍ បាន លើកឡើងអំពីករណីនិងអង្គហេតុ ដែលលោកធ្វើការងារនៅក្នុងការងារឃោសនានៅឫស្សីកែវលោក គឺ ជាមនុស្សដែលមានការគោរពណាស់ ។ ហើយប្រសិនបើ ខ្ញុំយល់ត្រឹមត្រូវនោះលោកបានបង្ហាញថា លោកអនុវត្តការងារតាមការងាររបស់លោក ថាតើលោកអាចពន្យល់ទៅលើចំណុចនេះបានដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកស្រីមេធាវីការពារក្ដី! ការងារដែលខ្ញុំគេចាត់តាំង ហាក់ ចាត់តាំងឲ្យខ្ញុំគូររូបខ្មៅខ្លងគ្រឿងម៉ាស៊ីន ម៉ាស៊ីនពុះ ម៉ាស៊ីនទាំងមូល ម៉ាស៊ីនឡាន ម៉ាស៊ីនកាណូត អ៎! ច្រឡំ ម៉ាស៊ីនឡាន ឲ្យតែគ្រឿងម៉ាស៊ីន គ្រឿងម៉ាស៊ីនសព្វគ្រប់ទ៉ុង ។ ខ្ញុំតែងតែគូរសព្វបែបយ៉ាងដាក់ក្នុង សៀវភៅឯកសារ ហើយរៀបជា១១សៀវភៅដើម្បីឲ្យពួកកូនសិស្សជំនាន់នោះគេរៀន ។

អ៊ីចឹង ការចងចាំរបស់ខ្ញុំដែលធ្វើឯកសារ ធ្វើជាការពន្យល់របស់សិក្ខាកាមដែលមករៀនពីបច្ចេកទេសគ្រឿងម៉ាស៊ីនហ្នឹង គឺខ្ញុំបានធ្វើអ៊ីចឹងមែន គោរពតាមបទបញ្ជាថ្នាក់លើ ពីព្រោះថ្នាក់លើ ប្រធាន ហាក់ ហ្នឹងគេចាត់តាំងឲ្យខ្ញុំរៀបចំធ្វើឯកសារ ធ្វើសៀវភៅហ្នឹងអ៊ីចឹងមែន ។ ខ្ញុំគោរពបានហ្មត់ចត់ ។ សូមអស់យោបល់ ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ? ហេតុអ្វីបានជាលោកនិយាយថា លោកមិនបានគោរព និងធ្វើតាមទាំងអស់ពីកម្លាំងចិត្តនោះទេ? ហើយលោកធ្វើការអស់ពីកម្លាំងកាយ ហេតុអ្វីបានជាលោក និយាយថា លោកមិនគោរពតាមផ្លូវចិត្តរបស់លោក គឺលោកមិនធ្វើឲ្យអស់ពីកម្លាំងផ្លូវចិត្តនោះទេ?

**ឆ៖** អានេះ ខ្ញុំសូមជម្រាបប្រសាសន៍លោកមេធាវីការពារក្ដី! ពីព្រោះថា រូបកាយខាងក្រៅគឺខ្ញុំ ធ្វើតាមការចាត់តាំងរបស់គេ មុខងាររបស់ខ្ញុំខាងផ្នែកគំនូរ ។ អ៊ីចឹង ខ្ញុំត្រូវតាមការងារមុខងាររបស់ខ្ញុំ ហ្នឹង ប៉ុន្តែ ចិត្តរបស់ខ្ញុំនោះមិនបាញ់កំណត់មួយរយភាគរយទៅលើអ្នកដឹកនាំទេ ។ ដោយហេតុអ្វី? ដោយហេតុខ្ញុំគេការជម្លៀសអ្នកស្រុកចេញពីទីក្រុង។ ទីក្រុងភ្នំពេញពីដើមស្ងាត់ជ្រងំដូចព្រៃខ្មោចអ៊ីចឹង។ ខ្ញុំហួសចិត្តខ្ញុំអស់ជំនឿត្រឹមនុ៎ងហើយ សូមជម្រាបប្រសាសន៍លោកយោបាល់ខ្ញុំមានប៉ុណ្ណឹង ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ។ ដូច្នេះ ហេតុអ្វីបានជាលោកនៅតែបន្តគោរពការងារនោះអស់ ពីកម្លាំងចិត្ត? (សូមកែតម្រូវ) គឺហេតុអ្វីបានជាលោកធ្វើការងារនោះអស់ពីកម្លាំងកាយ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកមេធាវីការពារក្ដី! រឿងមុខការរបស់ខ្ញុំខាងផ្នែកគំនូរ ខ្ញុំត្រូវតែ ធ្វើគេប្រាប់ឲ្យធ្វើខ្ញុំត្រូវតែធ្វើទៅតាមត្រូវតែបំពេញ ។ បំពេញប៉ុណ្ណឹងហើយ នៅតែគេផ្លាស់ខ្ញុំសហករណ៍

តាឡីហ្នឹងទៀត ។ ហេតុតែខ្ញុំ គេថាខ្ញុំអនុធនផ្នែកខាងជាងផ្នែកខាងគ្រូបង្រៀនក្ដីផ្នែកខាងស័ក្តិប្រាំ ស័ក្តិប្រាំមួយអីហ្នឹង សម័យនោះគេនិយាយអ៊ីចឹង បាទសុទ្ធតែអ្នកមិនស្គាល់ពលកម្ម ។ អ៊ីចឹងគេផ្លាស់ខ្ញុំមកសហករណ៍តាឡី ត្រង់ហ្នឹងហើយដែលធ្វើឲ្យខ្ញុំគ្មានជំនឿនៅលើរបបនុ៎ង ។ ហ្នឹងសូមអស់យោបល់ ។

[១៦:០៨:២៩]

**ស៖** ដូច្នេះ សូមលោកផ្តល់ចម្លើយរបស់លោក គឺដោយសារតែលោកមានការភ័យខ្លាចនូវការគោរពក្នុងការងារនោះនៅលើកម្លាំងកាយរបស់លោក?

**ឆ៖** ខ្ញុំមិនទាន់យល់ទេ ។ សូមឲ្យលោកបញ្ជាក់មួយសាថ្មីឡើងម្តងទៀត ។

**ស៖** លោកបានជម្រាបយើងខ្ញុំថា ប្រសិនបើលោកមិនអនុវត្តតាមបញ្ជានោះមួយរយភាគរយនោះទេ លោកនឹងត្រូវគេបញ្ជូនចេញ ។ ដូច្នេះខ្ញុំអាចសន្និដ្ឋានថា គឺលោកមានការភ័យខ្លាចនូវការមិនគោរពនូវបញ្ជាមួយរយភាគរយនោះហើយ ដូច្នេះ លោកមានការភ័យខ្លាចទៅលើចំណុចហ្នឹង ?

**ឆ៖** សូមជម្រាបប្រសាសន៍ការពិត គឺអ៊ីចឹងមែន ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ខ្ញុំអស់មានសំណួរទៀតនោះទេ ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ការស្តាប់ចម្លើយសក្ខីកម្មសេចក្តីថ្លែងការណ៍របស់អ្នករស់រានមានជីវិតលោក ប៊ូ ម៉េង ដែលយើងធ្វើសវនាការពេញមួយថ្ងៃនេះ ឃើញថាដល់ទីបញ្ចប់ហើយ ។ ហើយមុននឹងផ្អាកសវនាការអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីទាំងអស់ដែលបានជ្រាបអំពីការដែលអង្គជំនុំជម្រះមានផែនការក្នុងការកំណត់ធ្វើសវនាការសម្រាប់ថ្ងៃស្អែក ។ ថ្ងៃស្អែកនេះ តាមកម្មវិធីដែលបានគ្រោងទុកគឺយើងអង្គសវនាការបានកំណត់ធ្វើសវនាការអ្នករស់រានមានជីវិតមួយរូប គឺ CP1/6 ប៉ុន្តែ ដោយសារការគណនាពេលវេលានិងធៀបនឹងអង្គហេតុដែលអ្នករស់រានមានជីវិតរូបនោះបានចូលរួមនឹងបានដឹងឮនោះប្រហែលជាអំឡុងពេលធ្វើមិនច្រើនពេកទេ ប្រហែលជាអាចមួយព្រឹក ឬក៏លើសបន្តិចបន្តួចនោះគឺនឹងអាចចប់ហើយ ។

[១៦:១១:៣៤]

អ៊ីចឹងទេ អង្គជំនុំជម្រះសម្រេចដាក់អញ្ជើញនៅអ្នករស់រានមានជីវិតមួយរូបទៀតគឺ E2/80 ដើម្បីត្រៀមបម្រុងប្រសិនបើមានសល់ពេលវេលា គឺនឹងស្តាប់សក្ខីរបស់អ្នករស់រានមានជីវិត E2/80

ដែលគាត់នៅក្នុងក្រុមទីបី ហើយការដែលមានការប្រែប្រួលនេះ ដោយមូលហេតុដូចខ្ញុំបានជម្រាបអ៊ីចឹង ដើម្បីសន្សំសំចៃពេលវេលា ។ ហើយមួយទៀតបើតាមលំដាប់នុំងគឺត្រូវ E2/61 ទេ ប៉ុន្តែ ស្ថានភាព E2/61 គាត់មានទីលំនៅ នៅឆ្ងាយប្រសិនបើធ្វើសវនាការមិនចប់នោះវាការលំបាកនៅក្នុងការគ្រប់គ្រង ក្នុងការជូនគាត់ទៅវិញទៅមកនៅក្នុងអំឡុងពេលនៃការថ្ងៃការមិនធ្វើសវនាការថ្ងៃ ថ្ងៃសុក្រ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យនោះ ។

ដោយឡែកគឺ E2/80នេះគាត់មានទីលំនៅ នៅជិតនៅក្នុងភ្នំពេញអ៊ីចឹងមានការប្រែប្រួលបន្តិច ។ អ៊ីចឹងសូមភាគីទាំងអស់ជ្រាបអំពីបញ្ហានេះ ហើយក៏ដល់ទីបញ្ចប់ហើយអង្គជំនុំជម្រះ សូមប្រកាសផ្អាក សវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ។ ហើយអង្គសវនាការនឹងចាប់ផ្តើមបន្តធ្វើនៅថ្ងៃស្អែក នៅវេលាព្រឹក ចាប់ពីម៉ោងប្រាំបួនទៅដូចសព្វដងអ៊ីចឹង ។ សូមភាគីជ្រាបនឹងអញ្ជើញចូលរួម ។

មន្ត្រីតុលាការសម្របសម្រួលដល់លោក ប៊ូ ម៉េង ដើម្បីឲ្យគាត់បានត្រលប់ទៅលំនៅដ្ឋានវិញ បានស្រួលបួលដោយទាក់ទងជាមួយហ្នឹងខាងអង្គភាព *វីស៊ូ* ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ព្រឹក ។

*[សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី]*